ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ
លេខ.....៤០៩១.........អពដ

ថ្ងៃ អង្គារ ០៤រោច ខែ ផល្គុន ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ មីនា ឆ្នាំ២០២១

# សេចក្តីណែនាំ

## ស្តីពី

## ការដាក់ឱ្យប្រើប្រាស់សេចក្តីណែនាំសម្រាប់បំពេញលិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ

អនុលោមតាមច្បាប់ស្តីពីសារពើពន្ធដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខនស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ និងវិសោធនកម្មបន្តបន្ទាប់ និងប្រកាសលេខ០៩៨ សហវ.ប្រក ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០២០ ស្តីពីពន្ធលើប្រាក់ចំណូល អគ្គនាយកដ្ឋានពន្ធដារ មានកិត្តិយសសូមជម្រាបជូនដំណឹងដល់ស្ថាប័នពាក់ព័ន្ធ លោក-លោកស្រីជាអភិបាល បណ្ណាធិការ កម្មសិទ្ធិករសហគ្រាស ភ្នាក់ងារសេវាកម្មពន្ធដារ និងប្រធានសមាគមនិងអង្គការក្រៅរដ្ឋាភិបាលទាំងអស់ឱ្យបានជ្រាបថា ថ្មីៗនេះអគ្គនាយកដ្ឋានពន្ធដារបានធ្វើការកែសម្រួលទម្រង់លិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ និងបានដាក់ឱ្យប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងការដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំតាមអនឡាញ (Tax on Income - ToI E-Filing)។ ស្របពេលជាមួយគ្នានេះដែរ ក្នុងគោលដៅជាជំនួយដល់អ្នកជាប់ពន្ធក្នុងការរៀបចំលិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំឱ្យបានត្រឹមត្រូវ និងស្របតាមច្បាប់និងបទប្បញ្ញត្តិស្តីពីពន្ធដារ អគ្គនាយកដ្ឋានពន្ធដារ បានធ្វើបច្ចុប្បន្នភាព**សេចក្តីណែនាំសម្រាប់បំពេញលិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ**ផងដែរ **(ដូចមានភ្ជាប់មកជាមួយនូវសេចក្តីណែនាំនេះ)** ដែលមានខ្លឹមសារចែកចេញជា ៥ផ្នែកសំខាន់ៗដូចខាងក្រោម÷

១). របៀបបំពេញលិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ

២). ព័ត៌មានត្រូវបំពេញនៅក្នុងលិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ

៣). ព័ត៌មានត្រូវបំពេញក្នុងតារាងកែតម្រូវក្រៅគណនេយ្យ

៤). ព័ត៌មានត្រូវបំពេញក្នុងឧបសម្ព័ន្ធ

៥). ការប្រើប្រាស់អត្រាប្តូរប្រាក់ក្នុងការរៀបចំលិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ។

អគ្គនាយកដ្ឋានពន្ធដារ សង្ឃឹមជឿជាក់ថាសេចក្តីណែនាំសម្រាប់បំពេញលិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំនេះ នឹងជួយលោក-លោកស្រីជាអភិបាល បណ្ណាធិការ កម្មសិទ្ធិករសហគ្រាស ភ្នាក់ងារសេវាកម្មពន្ធដារ និងប្រធានសមាគមនិងអង្គការក្រៅរដ្ឋាភិបាល ដែលជាអ្នកជាប់ពន្ធធំ និងមធ្យម អាចបំពេញលិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំបានត្រឹមត្រូវជាក់ជាមិនខានឡើយ។

រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី
ប្រតិភូរាជរដ្ឋាភិបាល
ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ

គង់ វិបុល

អាគារកែងមហាវិថី សហព័ន្ធរុស្ស៊ី(១១០)និង ម៉ៅសេទុង(២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ (+855) 23 886 708 ទូរសារ: (+855)23 886 700, Email: gdt@tax.gov.kh, Website: www.tax.gov.kh

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

អគ្គនាយកដ្ឋានពន្ធដារ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# សេចក្តីណែនាំ

# សម្រាប់បំពេញ

# លិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ

រក្សាសិទ្ធិដោយ អគ្គនាយកដ្ឋានពន្ធដារ

ឆ្នាំ ២០២១

# មាតិកា

ទំព័រ


**សេចក្តីណែនាំសម្រាប់បំពេញលិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ** ........ 1-3

**ហេតុអ្វីអ្នកជាប់ពន្ធត្រូវដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណូល?** ........ 4

**ព័ត៌មានត្រូវបំពេញនៅក្នុងលិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ** ........ 5-60

ទំព័រទី១ (TOI 01/I) ÷ ព័ត៌មានទូទៅរបស់សហគ្រាស ........ 5-8

ទំព័រទី២ (TOI 01/II) ÷ ព័ត៌មានទូទៅរបស់សហគ្រាស ........ 9-12

*ការចូលរួមមូលធនគិតត្រឹមការិយបរិច្ឆេទ* ........ *9-10*

*ព័ត៌មានអំពីនិយោជិតសហគ្រាសនៅក្នុងការិយបរិច្ឆេទ* ........ *11-12*

ទំព័រទី៣ និងទី៤ (TOI 01/III) ÷ តារាងតុល្យការ ........ 13-17

ទំព័រទី៥ និងទី៦ (TOI 01/IV) ÷ របាយការណ៍លទ្ធផល ........ 18-21

ទំព័រទី៧ (TOI 01/V) ÷ ថ្លៃដើមផលិតផលបានលក់ (សហគ្រាសផលិតកម្ម) ........ 22-24

ទំព័រទី៨ (TOI 01/VI) ÷ ថ្លៃដើមទំនិញបានលក់ (សហគ្រាសក្រៅពីផលិតកម្ម) ........ 25

ទំព័រទី៩ និងទី១០ (TOI 01/VII) ÷ តារាងគណនាពន្ធលើប្រាក់ចំណូល ........ 26-33

ទំព័រទី១១ និងទី១២ (TOI 01/VIII) ÷ តារាងគណនាវិភាគទានសប្បុរសធម៌ ការប្រាក់អាចកាត់កងបាន និងឥណទានខាតយោងទៅមុខ 34-43

*ក- ការគណនាវិភាគទានសប្បុរសធម៌* ........ *34*

*ខ- ការគណនាចំណាយការប្រាក់* ........ *35*

*ខ.១- តារាងតាមដានចំណាយការប្រាក់យោងទៅមុខ* ........ *36-40*

*គ- តារាងតាមដានលទ្ធផលសារពើពន្ធខាតយោងទៅមុខ* ........ *41-43*

ទំព័រទី១៣ (TOI 01/IX) ÷ តារាងគណនារំលស់តាមច្បាប់ស្តីពីសារពើពន្ធ ........ 44-48

ទំព័រទី១៤ (TOI 01/X) ÷ តារាងគណនារំលស់ពិសេសតាមច្បាប់ស្តីពីសារពើពន្ធ ........ 49

ទំព័រទី១៥ (TOI 01/XI) ÷ តារាងតម្លៃលើសឬខ្វះពីការលក់ ឬដកចេញនូវទ្រព្យសកម្មរយៈពេលវែងតាមច្បាប់ស្តីពីសារពើពន្ធ ........ 50

ទំព័រទី១៦ (TOI 01/XII) ÷ តារាងគណនាសំវិធានធន ........ 51

ឧបសម្ព័ន្ធ ១÷ តារាងប្រតិបត្តិការជាមួយបុគ្គលទាក់ទិន ........ 52

ឧបសម្ព័ន្ធ ២÷ បញ្ជីឈ្មោះនៃទ្រព្យសកម្មរយៈពេលវែង ........ 53

ឧបសម្ព័ន្ធ ៣÷ ឧបសម្ព័ន្ធភ្ជាប់ជាមួយលិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ (សាខាសហគ្រាសក្នុងស្រុក) ........ 54-57

ឧបសម្ព័ន្ធ ៤÷ ពន្ធលើប្រាក់ចំណូលលើសកម្រិតលើប្រតិបត្តិការធនធានរ៉ែ / ប្រេងកាត ........ 58-60

**ការប្រើប្រាស់អត្រាប្តូរប្រាក់ក្នុងការរៀបចំលិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ** ........ 61

# សេចក្ដីណែនាំសម្រាប់បំពេញលិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ

ដើម្បីឱ្យការបំពេញលិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំមានភាពងាយស្រួល អ្នកជាប់ពន្ធគួរអនុវត្តតាមជំហានបន្តបន្ទាប់ដូចខាងក្រោម÷

**ជំហានគួរអនុវត្ត÷**

១- **ទំព័រទី១ (ស្ដីពីព័ត៌មានទូទៅរបស់សហគ្រាស)** ÷ ត្រូវបំពេញប្រអប់នីមួយៗក្នុងទំព័រនេះ ដោយឡែកប្រអប់ "**ប្រអប់ 17: ពន្ធលើប្រាក់ចំណូលត្រូវបង់**" ឬ "**ប្រអប់ 18: ឥណទានពន្ធយោងទៅមុខ**" ត្រូវបំពេញក្រោយគេបង្អស់នៅពេលដែលប្រាក់ចំណូលជាប់ពន្ធត្រូវបានគណនា។

២- **ទំព័រទី២ (ស្ដីពីព័ត៌មានទូទៅរបស់សហគ្រាស)** ÷ ត្រូវបំពេញព័ត៌មានដែលតម្រូវ។

៣- **ទំព័រទី៣ និងទី៤ (តារាងតុល្យការ)** ÷ ត្រូវបំពេញព័ត៌មានដែលតម្រូវ។ ប្រសិនបើព័ត៌មានកត់ត្រាចូលបានត្រឹមត្រូវនោះ "**A0: ទ្រព្យសកម្ម** " ត្រូវស្មើនឹង "**A28: មូលនិធិ/ទុនម្ចាស់ទ្រព្យ និងបំណុល**"។

៤- **ទំព័រទី៧ (ថ្លៃដើមផលិតផលបានលក់ "សហគ្រាសផលិតកម្ម")** ÷ ត្រូវបំពេញព័ត៌មានដែលតម្រូវ ប្រសិនបើជាសហគ្រាសផលិតកម្ម។

**ទំព័រទី៨ (ថ្លៃដើមទំនិញបានលក់សហគ្រាសក្រៅពីផលិតកម្ម)** ÷ ត្រូវបំពេញព័ត៌មានដែលតម្រូវ ប្រសិនបើមិនមែនជាសហគ្រាសផលិតកម្ម។

**កំណត់សម្គាល់÷** ប្រសិនបើសកម្មភាពអាជីវកម្មរបស់សហគ្រាសមានសកម្មភាពផលិតកម្ម និងសកម្មភាពក្រៅពីផលិតកម្ម ត្រូវតែបំពេញព័ត៌មាននៅក្នុងទំព័រទាំងពីរ (ទំព័រទី៧ និងទី៨)។

៥- **ទំព័រទី៥ និងទី៦ (របាយការណ៍លទ្ធផល)** ÷ ត្រូវបំពេញព័ត៌មានដែលតម្រូវ។

៦- **ទំព័រទី១៤ (តារាងរំលស់ពិសេសតាមច្បាប់ស្ដីពីសារពើពន្ធ)** ÷

- សូមរក្សាទុកឱ្យនៅទំនេរ ប្រសិនបើសហគ្រាសមិនមែនជាគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ (គ.ល.គ.)។
- សូមរក្សាទុកឱ្យនៅទំនេរ ប្រសិនបើសហគ្រាសជា **គ.ល.គ.** ដែលមិនជ្រើសយកការប្រើប្រាស់រំលស់ពិសេស (សហគ្រាសជ្រើសរើសយកការលើកលែងពន្ធ)។
- ត្រូវបំពេញព័ត៌មានដែលតម្រូវ ប្រសិនបើសហគ្រាសជា **គ.ល.គ.** ដែលជ្រើសយកការប្រើប្រាស់រំលស់ពិសេស។

៧- **ទំព័រទី១៥ (តារាងតម្លៃលើសឬខ្វះពីការលក់ ឬដកចេញនូវទ្រព្យសកម្មរយៈពេលវែងតាមច្បាប់ស្ដីពីសារពើពន្ធ)** ÷

- សូមរក្សាទុកឱ្យនៅទំនេរ ប្រសិនបើគ្មានការលក់ ឬគ្មានការដកចេញនូវទ្រព្យសកម្មរយៈពេលវែងក្នុងឆ្នាំជាប់ពន្ធ។
- ត្រូវបំពេញព័ត៌មានដែលតម្រូវ ប្រសិនបើទ្រព្យសកម្មរយៈពេលវែងត្រូវបានលក់ ឬបានដកចេញក្នុងឆ្នាំជាប់ពន្ធ។

៨- **ទំព័រទី១៣ (តារាងរំលស់តាមច្បាប់ស្ដីពីសារពើពន្ធ)** ÷បំពេញព័ត៌មានដែលតម្រូវ។

**កំណត់សម្គាល់÷** ត្រូវបំពេញព័ត៌មាននៃទ្រព្យសកម្មដែលអស់រំលស់ផងដែរ (អស់រំលស់តាមច្បាប់ស្ដីពីសារពើពន្ធ) នៅក្នុងតារាងនេះ ប្រសិនបើទ្រព្យនេះមិនបានលក់ ឬដកចេញ។

**៩- ទំព័រទី១៦ (តារាងគណនាសំវិធានធន)** ÷ ត្រូវបំពេញព័ត៌មានលម្អិតដែលតម្រូវ។

**១០- ឧបសម្ព័ន្ធ៤ ពន្ធលើប្រាក់ចំណូលលើសកម្រិតលើប្រតិបត្តិការធនធានរ៉ែ/ប្រេងកាត** ÷ ត្រូវគណនាតាមរូបមន្តដែលបញ្ជាក់ក្នុងតារាងគណនាពន្ធលើប្រាក់ចំណូលលើសកម្រិត។

- សូមរក្សាទុកឱ្យនៅទំនេរ ប្រសិនបើមិនមែនជាសហគ្រាសមានប្រតិបត្តិការធនធានរ៉ែ/ប្រេងកាត។
- បំពេញព័ត៌មានដែលតម្រូវ ប្រសិនបើជាសហគ្រាសមានប្រតិបត្តិការធនធានរ៉ែ/ប្រេងកាត។

**១១- ទំព័រទី៩ និងទី១០ (តារាងគណនាពន្ធលើប្រាក់ចំណូល)** ÷ ត្រូវបំពេញតួលេខចាប់ពីប្រអប់ **"E1: ប្រាក់ចំណេញ/(ខាត) មុនបង់ពន្ធ/ លទ្ធផលគណនេយ្យចំណេញ/(ខាត)"** ដល់ប្រអប់ **"E36: ប្រាក់ចំណូលសុទ្ធ/(ខាត) ក្រោយនិយតកម្ម"** ។

**១២- ទំព័រទី១១ (តារាងគណនាវិភាគទានសប្បុរសធម៌ ការប្រាក់អាចកាត់កងបាន និងឥណទានខាតយោងទៅមុខ)** ÷

**ចំណុច ក- ការគណនាវិភាគទានសប្បុរសធម៌÷**

- សូមរក្សាទុកឱ្យនៅទំនេរ ប្រសិនបើសហគ្រាសមិនបានបរិច្ចាគវិភាគទានសប្បុរសធម៌ក្នុងការិយបរិច្ឆេទ។
- ត្រូវបំពេញព័ត៌មានក្នុង "តារាងគណនាវិភាគទានសប្បុរសធម៌" ប្រសិនបើសហគ្រាសបានបរិច្ចាគវិភាគទានសប្បុរសធម៌ក្នុងការិយបរិច្ឆេទ។

**កំណត់សម្គាល់÷** វិភាគទានសប្បុរសធម៌ដែលសហគ្រាសបានបរិច្ចាគ ហើយយកមកបំពេញក្នុងតារាងនេះ (TOI 01/VIII) ត្រូវបំពេញលក្ខណវិនិច្ឆ័យជាចំណាយអាចកាត់កងបានដូចមានចែងក្នុងកថាខណ្ឌ២ ប្រការ៣៣ នៃប្រកាសស្តីពីពន្ធលើប្រាក់ចំណូល។

**១៣- ទំព័រទី១០÷** ត្រូវបំពេញប្រអប់ **"E37: ចំណាយសប្បុរសធម៌ដែលមិនអាចកាត់កង"** បន្ទាប់មកគណនា **"E38: ប្រាក់ចំណូលសុទ្ធ/(ខាត) មុននិយតកម្មលើការប្រាក់"** ។

**១៤- ទំព័រទី១១ និងទំព័រទី១២÷**

**ចំណុច ខ- ការគណនាចំណាយការប្រាក់÷**

- សូមរក្សាទុកឱ្យនៅទំនេរ ប្រសិនបើមានចំណាយការប្រាក់យោងពីមុនស្មើសូន្យ ហើយគ្មានចំណាយការប្រាក់កើតមាននៅក្នុងឆ្នាំជាប់ពន្ធ។
- ត្រូវបំពេញព័ត៌មានដែលតម្រូវ ប្រសិនបើមានចំណាយការប្រាក់យោងពីមុន ហើយមានចំណូល និងចំណាយការប្រាក់កើតមាននៅក្នុងឆ្នាំជាប់ពន្ធ។

**១៥- ទំព័រទី១០÷** ត្រូវបំពេញតួលេខចាប់ពីប្រអប់ **"E39: និយតកម្មលើការប្រាក់"** ដល់ **"E59: ពន្ធលើប្រាក់ចំណូលត្រូវបង់/ត្រូវយោងទៅឆ្នាំបន្ទាប់"** ។

**កំណត់សម្គាល់÷**

- **"E41: ខាតយោងពីឆ្នាំមុនអនុញ្ញាត"** ត្រូវបំពេញប្រអប់នេះដោយប្រើប្រាស់តួលេខយកពីលិខិតប្រកាសពន្ធលើប្រាក់ចំណូលឆ្នាំមុន (N-1) ។
- **"E44: ពន្ធលើប្រាក់ចំណូលលើសកម្រិត"** ត្រូវបំពេញប្រអប់នេះដោយប្រើប្រាស់តួលេខយកពី X5 នៃឧបសម្ព័ន្ធ៤

**១៦- ទំព័រទី១២ (តារាងតាមដានលទ្ធផលសារពើពន្ធខាតយោងទៅមុខ)** ÷ ត្រូវបំពេញព័ត៌មានលម្អិតដែលតម្រូវ។

**១៧- ទំព័រទី១÷** ត្រូវបំពេញតែមួយប្រអប់ **"ប្រអប់ 17: ពន្ធលើប្រាក់ចំណូលត្រូវបង់"** ឬ **"ប្រអប់ 18: ឥណទានពន្ធយោងទៅមុខ"** ។

**១៨- ឧបសម្ព័ន្ធ១ តារាងប្រតិបត្តិការជាមួយបុគ្គលទាក់ទិន÷** ត្រូវបំពេញព័ត៌មានលម្អិតដែលតម្រូវ។

**១៩- ឧបសម្ព័ន្ធ២ បញ្ជីឈ្មោះនៃទ្រព្យសកម្មរយៈពេលវែង÷** ត្រូវបំពេញព័ត៌មានលម្អិតដែលតម្រូវ។

**២០- ឧបសម្ព័ន្ធ៣ ឧបសម្ព័ន្ធភ្ជាប់ជាមួយលិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ "សាខាសហគ្រាសក្នុងស្រុក"÷** ត្រូវបំពេញព័ត៌មានលម្អិតដែលតម្រូវ។

**សេចក្តីបញ្ជាក់÷**

សេចក្តីណែនាំនេះ មិនបានផ្តល់ព័ត៌មានលម្អិតស្តីពីច្បាប់ស្តីពីសារពើពន្ធទេ ហើយក៏មិនបានពន្យល់បកស្រាយច្បាប់ស្តីពីសារពើពន្ធឱ្យបានស៊ីជម្រៅដែរ។ ប្រសិនបើមានសំណួរផ្សេងៗពាក់ព័ន្ធនឹងលិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ សូមទាក់ទងមក÷

- ការិយាល័យសេវាអ្នកជាប់ពន្ធ នៃនាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ
- ការិយាល័យសេវាអ្នកជាប់ពន្ធ នៃនាយកដ្ឋានគ្រប់គ្រងអ្នកជាប់តូច និងមធ្យម
- ការិយាល័យសេវាអ្នកជាប់ពន្ធ នៃសាខាពន្ធដារខេត្ត-ខណ្ឌនានា

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងមកអគ្គនាយកដ្ឋានពន្ធដារ ដែលមានអាសយដ្ឋាន÷ អគារឡូតិ៍លេខ ៥២២-៥២៤ កែងមហាវិថីសហព័ន្ធរុស្ស៊ី(១១០) និងម៉ៅសេទុង(២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ លេខទូរស័ព្ទ ០២៣ ៨៨៦ ៧០៨ និងសារអេឡិចត្រូនិច gdt@tax.gov.kh ឬតាមរយៈ Call Center (១២៧៧) ឬតាមរយៈ GDT Live Chat។

# ហេតុអ្វីអ្នកជាប់ពន្ធត្រូវដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណូល?

### ❖ តើនរណាចាំបាច់ត្រូវដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ?

មាត្រា២៩ នៃច្បាប់ស្តីពីសារពើពន្ធ បានកំណត់ឱ្យអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ។

លក្ខណវិនិច្ឆ័យនៃអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស ត្រូវផ្អែកលើ÷

១- ទ្រង់ទ្រាយគតិយុត្តិរបស់សហគ្រាស ឬ

២- កម្រិតនៃផលរបរ ឬ

៣- ប្រភេទនៃសកម្មភាពអាជីវកម្ម។

### ❖ នៅពេលណាដែលអ្នកជាប់ពន្ធត្រូវដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណូលជូនរដ្ឋបាលសារពើពន្ធ?

អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស ត្រូវដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណូលជូនរដ្ឋបាលសារពើពន្ធក្នុងរយៈពេលមិនលើសពី ៣ខែ ក្រោយពីដំណាច់ឆ្នាំជាប់ពន្ធ ទោះបីមានលទ្ធផលខាត ឬគ្មានសកម្មភាពអាជីវកម្មក៏ដោយ។ ឆ្នាំជាប់ពន្ធត្រូវតែបញ្ចប់នៅថ្ងៃទី៣១ ខែធ្នូ ហើយលិខិតប្រកាសពន្ធលើប្រាក់ចំណូលត្រូវដាក់យ៉ាងយឺតបំផុតត្រឹមថ្ងៃទី ៣១ ខែមីនា នៃឆ្នាំបន្ទាប់ (មាត្រា២៩ និង ១០៤ថ្មី នៃច្បាប់ស្តីពីសារពើពន្ធ)។ ក្នុងករណីអ្នកជាប់ពន្ធមានឆ្នាំជាប់ពន្ធខុសពីឆ្នាំប្រតិទិន អ្នកជាប់ពន្ធត្រូវដាក់លិខិតប្រកាសនិងបង់ប្រាក់ពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំយ៉ាងយឺតបំផុតក្នុងរយៈពេល ០៣ខែ ក្រោយពីដំណាច់ឆ្នាំជាប់ពន្ធ។

### ❖ តើព័ត៌មានអ្វីខ្លះត្រូវដាក់បញ្ចូលក្នុងលិខិតប្រកាសពន្ធលើប្រាក់ចំណូល?

អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសត្រូវដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ ជូនរដ្ឋបាលសារពើពន្ធដោយភ្ជាប់មកជាមួយនូវ÷

១- តារាងតុល្យការ

២- គណនីលទ្ធផល និង

៣- តារាងព័ត៌មានបន្ថែម។

### ❖ តើពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំត្រូវបង់មានចំនួនប៉ុន្មាន?

អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស ត្រូវគណនាប្រាក់ចំណូលជាប់ពន្ធដោយខ្លួនឯង ដោយការបំពេញលិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ ហើយបន្ទាប់មកត្រូវគណនាពន្ធលើប្រាក់ចំណូលដោយយកប្រាក់ចំណូលជាប់ពន្ធគុណនឹងអត្រាពន្ធ។

ពន្ធលើប្រាក់ចំណូលត្រូវបង់/ត្រូវយោងទៅឆ្នាំបន្ទាប់÷ ត្រូវគណនាដោយយកពន្ធលើប្រាក់ចំណូល ដក ឥណទានពន្ធបរទេស ឥណទានពន្ធបង់មុនលើការបែងចែកភាគលាភ ឥណទានពន្ធកាត់ទុក ប្រាក់រំដោះពន្ធលើប្រាក់ចំណូល និងឥណទានពន្ធលើប្រាក់ចំណូលយោងពីឆ្នាំមុន (មាត្រា៣៧ និង៣៨ នៃច្បាប់ស្តីពីសារពើពន្ធ)។

### ❖ តើពន្ធលើប្រាក់ចំណូលត្រូវបង់នៅពេលណា?

ពន្ធលើប្រាក់ចំណូលត្រូវដល់កំណត់ និងត្រូវបង់នៅពេលដែលអ្នកជាប់ពន្ធត្រូវដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណូល (មាត្រា ១០៧ នៃច្បាប់ស្តីពីសារពើពន្ធ) មានន័យថាត្រូវបង់យ៉ាងយឺតបំផុតក្នុងរយៈពេល ០៣ខែ ក្រោយពីដំណាច់ឆ្នាំជាប់ពន្ធ។

# ព័ត៌មានត្រូវបំពេញនៅក្នុងលិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ

## ទំព័រទី១ (TOI 01/I)÷ ព័ត៌មានទូទៅរបស់សហគ្រាស

| ខ្លឹមសារនៅក្នុងលិខិតប្រកាស | សេចក្តីពន្យល់ |
|---|---|
| **ការិយបរិច្ឆេទសារពើពន្ធ÷** | ការិយបរិច្ឆេទសារពើពន្ធ គឺជាឆ្នាំជាប់ពន្ធ ដែលមានរយៈពេល ១២ខែ ចាប់ផ្តើមពីថ្ងៃទី០១ ខែមករា ឆ្នាំ២០២x ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២x។<br>❖ ចំពោះសហគ្រាសដែលមានឆ្នាំជាប់ពន្ធស្របនឹងឆ្នាំប្រតិទិន នោះឆ្នាំជាប់ពន្ធត្រូវ“គិតចាប់ពីថ្ងៃទី” ០១ ខែមករា ឆ្នាំ២០២x “ដល់ថ្ងៃទី” ៣១ ខែធ្នូ ឆ្នាំ២០២x។<br>❖ ចំពោះសហគ្រាសដែលត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ឆ្នាំជាប់ពន្ធខុសពីឆ្នាំប្រតិទិន ត្រូវដាក់លិខិតប្រកាសនិងបង់ប្រាក់ពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំយ៉ាងយឺតបំផុតក្នុងរយៈពេល ០៣ខែ ក្រោយពីដំណាច់ឆ្នាំជាប់ពន្ធ។<br>**ឧទាហរណ៍÷** សហគ្រាសប្រើប្រាស់ឆ្នាំជាប់ពន្ធពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០២០ ដល់ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១ ត្រូវដាក់លិខិតប្រកាសនិងបង់ប្រាក់ពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំយ៉ាងយឺតបំផុតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១។<br>❖ ចំពោះសហគ្រាសចាប់ផ្តើមអាជីវកម្មដំបូងនៅក្នុងខែណាមួយនៃឆ្នាំនោះ “ចំនួនខែ” គឺរាប់គិតពីកាលបរិច្ឆេទចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធ ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២x។<br>**ឧទាហរណ៍÷** សហគ្រាសចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធនៅថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២០ “**ចំនួនខែ**” គឺ ៦ខែ ហើយ “**គិតចាប់ពីថ្ងៃទី**” គឺគិតពីថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០២០ “**ដល់ថ្ងៃទី**” គឺដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០។<br>❖ ចំពោះសហគ្រាសបញ្ឈប់សកម្មភាពអាជីវកម្ម ក្នុងការិយបរិច្ឆេទ “**ចំនួនខែ**” គឺរាប់គិតពីដើមការិយបរិច្ឆេទនោះ ដល់កាលបរិច្ឆេទដែលសហគ្រាសនោះបានបញ្ឈប់សកម្មភាពអាជីវកម្មរបស់ខ្លួនជាស្ថាពរ។<br>**ឧទាហរណ៍÷** សហគ្រាស ក បានបញ្ឈប់សកម្មភាពអាជីវកម្មនៅថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ២០២០ “**ចំនួនខែ**” គឺ ៩ខែ ហើយ “**គិតចាប់ពីថ្ងៃទី**” គឺគិតពីថ្ងៃទី០១ ខែមករា ឆ្នាំ២០២០ “**ដល់ថ្ងៃទី**” គឺដល់ថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២០។ |
| **1-លេខអត្តសញ្ញាណកម្មសារពើពន្ធ (TIN)÷** | គឺជាលេខអត្តសញ្ញាណកម្មសារពើពន្ធ (TIN) របស់សហគ្រាសដែលមាននៅលើវិញ្ញាបនបត្រចុះបញ្ជីពន្ធដារចេញដោយរដ្ឋបាលសារពើពន្ធ។ |

| | |
|---|---|
| **2-ឈ្មោះសហគ្រាស÷** | គឺជាឈ្មោះរបស់សហគ្រាស ដែលបង្ហាញនៅលើវិញ្ញាបនបត្រចុះបញ្ជីពន្ធដារ (TIN) ចេញដោយរដ្ឋបាលសារពើពន្ធ។ |
| **3-ចំនួនសាខាសហគ្រាស÷** | គឺជាចំនួនសាខាដែលសហគ្រាសបានចុះបញ្ជីពន្ធដារនៅរដ្ឋបាលសារពើពន្ធ។ |
| **4-កាលបរិច្ឆេទចុះបញ្ជីពន្ធដារ÷** | គឺជាថ្ងៃខែឆ្នាំដែលបង្ហាញនៅលើវិញ្ញាបនបត្រចុះបញ្ជីពន្ធដារ (TIN) ចេញដោយរដ្ឋបាលសារពើពន្ធ។ |
| **5-ឈ្មោះអភិបាល/ បណ្ណាធិការ/ កម្មសិទ្ធិករ÷** | គឺជាឈ្មោះអ្នកគ្រប់គ្រង ឬអ្នកតំណាងរបស់សហគ្រាសដែលបង្ហាញលើប័ណ្ណពន្ធប៉ាតង់។ |
| **6-សកម្មភាពអាជីវកម្មចម្បង÷** | គឺជាឈ្មោះសកម្មភាពអាជីវកម្មចម្បងរបស់សហគ្រាស ដែលបង្ហាញនៅលើប័ណ្ណពន្ធប៉ាតង់។ |
| **7-ឈ្មោះគណនេយ្យករ/ភ្នាក់ងារសេវាកម្មពន្ធដារ÷** | គឺជាឈ្មោះបុគ្គលរៀបចំលិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំនេះ ដែលអាចជាគណនេយ្យករផ្ទាល់របស់សហគ្រាស ឬទីប្រឹក្សា ឬភ្នាក់ងារសេវាកម្មពន្ធដារ។ ប្រសិនបើជាភ្នាក់ងារសេវាកម្មពន្ធដារ ត្រូវបំពេញលេខសម្គាល់។ |
| **8-អាសយដ្ឋានទីស្នាក់ការសហគ្រាសបច្ចុប្បន្ន÷** | គឺជាអាសយដ្ឋានបច្ចុប្បន្ន ដែលសហគ្រាសបានចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធ ជាទីកន្លែងសម្រាប់ទំនាក់ទំនងជាផ្លូវការជាមួយរដ្ឋបាលសារពើពន្ធ ហើយជាទីកន្លែងដែលអ្នកគ្រប់គ្រងបំពេញការងារ និងរក្សាទុកបញ្ជិកាគណនេយ្យរបស់សហគ្រាស (ជាទីចាត់ការរបស់សហគ្រាស)។ |
| **9-អាសយដ្ឋានគ្រឹះស្ថានជាគោលដើមបច្ចុប្បន្ន÷** | អាសយដ្ឋានជាគោលដើមបច្ចុប្បន្ន គឺជាទីកន្លែងដែលសកម្មភាពអាជីវកម្មចម្បងកើតឡើងជាក់ស្តែង។ |

ប្រសិនបើសហគ្រាសមានគ្រឹះស្ថានអាជីវកម្មច្រើន អាសយដ្ឋានជាគោលដើម គឺជាអាសយដ្ឋានរបស់គ្រឹះស្ថាន ដែលមានសកម្មភាពអាជីវកម្មចម្បងរបស់សហគ្រាស។

**ឧទាហរណ៍÷** សហគ្រាសផលិតសម្លៀកបំពាក់មួយ មានអាសយដ្ឋានទីស្នាក់ការសហគ្រាស "អាសយដ្ឋានទីស្នាក់ការចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធ" នៅផ្ទះលេខ៣០០ ផ្លូវ៣១០ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ប៉ុន្តែរោងចក្រផលិតសម្លៀកបំពាក់របស់សហគ្រាសនេះស្ថិតនៅផ្ទះលេខ១០ ផ្លូវវេងស្រេង សង្កាត់កាកាប ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។

**ឧទាហរណ៍÷** សហគ្រាសផលិតសម្លៀកបំពាក់មួយ មានអាសយដ្ឋានទីស្នាក់ការសហគ្រាស "អាសយដ្ឋានទីស្នាក់ការចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធ" នៅផ្ទះលេខ៣០០ ផ្លូវ៣១០ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ប៉ុន្តែរោងចក្រផលិតសម្លៀកបំពាក់របស់

សហគ្រាសនេះស្ថិតនៅផ្ទះលេខ១០ ផ្លូវវេងស្រេង សង្កាត់កាកាប ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។ ដូច្នេះ អាសយដ្ឋានជាគោលដើមបច្ចុប្បន្នរបស់សហគ្រាសនេះគឺ ផ្ទះលេខ១០ ផ្លូវវេងស្រេង សង្កាត់កាកាប ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។

**10-អាសយដ្ឋានឃ្លាំងបច្ចុប្បន្ន÷** គឺជាអាសយដ្ឋានឃ្លាំងស្តុកវត្ថុធាតុដើម ឬទំនិញសំខាន់ៗរបស់សហគ្រាស។

**11-ការកត់ត្រាបញ្ជីកាគណនេយ្យ÷** បើសហគ្រាសប្រើប្រាស់ប្រព័ន្ធគណនេយ្យកុំព្យូទ័រ សូមគូស √ នៅក្នុងប្រអប់ ☐ "ប្រើប្រាស់កម្មវិធីគណនេយ្យកុំព្យូទ័រ(ឈ្មោះកម្មវិធី)" និងបំពេញឈ្មោះកម្មវិធី។

បើសហគ្រាសមិនបានប្រើប្រាស់ប្រព័ន្ធគណនេយ្យកុំព្យូទ័រសូមគូស √ នៅក្នុងប្រអប់ ☐ "មិនប្រើប្រាស់កម្មវិធីគណនេយ្យកុំព្យូទ័រ"។

**12-កម្រិតអនុលោមភាពសារពើពន្ធ÷** បើសហគ្រាសបានទទួលវិញ្ញាបនបត្រអនុលោមភាពសារពើពន្ធ សូមគូសសញ្ញា √ នៅក្នុងប្រអប់ ☐ តាមកម្រិតអនុលោមភាពសារពើពន្ធដែលទទួលបានមានដូចជា មាស ប្រាក់ និងសំរិទ្ធ។ បើសហគ្រាសមិនទទួលបានវិញ្ញាបនបត្រអនុលោមភាពសារពើពន្ធទេ សហគ្រាសមិនត្រូវគូសសញ្ញា √ នៅក្នុងប្រអប់ ☐ ណាមួយនោះទេ។

**13-សវនកម្មឯករាជ្យដែលតម្រូវដោយច្បាប់÷** បើសហគ្រាសត្រូវបានតម្រូវឱ្យមានការធ្វើសវនកម្ម ស្ថិតក្រោមច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម សហគ្រាសត្រូវគូសសញ្ញា √ នៅក្នុងប្រអប់ ☐ "មានការតម្រូវ"។ បើសហគ្រាសត្រូវបានតម្រូវឱ្យមានការធ្វើសវនកម្មដោយច្បាប់ ហើយបានគូសសញ្ញា √ នៅក្នុងប្រអប់ ☐ "មានការតម្រូវ" នោះសហគ្រាសត្រូវដាក់ជូនរដ្ឋបាលសារពើពន្ធ នូវរបាយការណ៍សវនកម្មតាមកាលបរិច្ឆេទកំណត់ដោយច្បាប់ និងបទប្បញ្ញត្តិស្តីពីសារពើពន្ធ។ ផ្ទុយទៅវិញ បើសហគ្រាសមិនត្រូវបានតម្រូវឱ្យមានការធ្វើសវនកម្មក្រោមច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម សហគ្រាសត្រូវគូសសញ្ញា √ នៅក្នុងប្រអប់ ☐ "គ្មានការតម្រូវ"។

**14-ទ្រង់ទ្រាយគតិយុត្តិ/ទម្រង់នៃប្រតិបត្តិការអាជីវកម្ម÷** សហគ្រាសភាគច្រើនទ្រង់ទ្រាយគតិយុត្តិមានបញ្ជាក់នៅក្នុងវិញ្ញាបនបត្រ ចុះបញ្ជីដែលចេញដោយក្រសួងពាណិជ្ជកម្ម។ សូមគូសសញ្ញា √ នៅក្នុងប្រអប់ ☐ ដែលស្របនឹងទ្រង់ទ្រាយគតិយុត្តិ ដូចមានបញ្ជាក់នៅវិញ្ញាបនបត្រនេះ។

**15-លើកលែងពន្ធលើប្រាក់ចំណូល÷** គម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ ដែលបានទទួលការលើកលែងពន្ធលើប្រាក់ចំណូល ត្រូវបញ្ជាក់រយៈពេលលើកលែងពន្ធ ឱ្យបានត្រឹមត្រូវតាមវិញ្ញាបនបត្រផ្តល់ដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។

**16- អត្រាពន្ធលើប្រាក់ចំណូល÷** សូមគូសសញ្ញា √ នៅក្នុងប្រអប់ ☐ ស្របតាមអត្រាពន្ធលើប្រាក់ចំណូលមានដូចខាងក្រោម ÷

**អត្រា ៣០ ភាគរយ÷** ចំពោះប្រាក់ចំណូលជាប់ពន្ធសម្រេចបាន ក្រោមកិច្ចសន្យាបែងចែកផលិតផលប្រេងកាត និងឧស្ម័នធម្មជាតិ ឬសម្រេចបានពីការធ្វើអាជីវកម្មលើធនធានធម្មជាតិ រួមទាំងព្រៃឈើ រ៉ែ មាស ឬត្បូងថ្មមានតម្លៃនានា។

**អត្រា ២០ ភាគរយ÷** ចំពោះប្រាក់ចំណូលជាប់ពន្ធដែលសម្រេចបានដោយនីតិបុគ្គល។

**អត្រា ៥ ភាគរយ÷** ចំពោះសហគ្រាសធានារ៉ាប់រង ចំពោះបុព្វលាភដុលដែលទទួលបាននៅក្នុងឆ្នាំជាប់ពន្ធ ចំពោះការធានារ៉ាប់រងលើទ្រព្យសម្បត្តិឬហានិភ័យផ្សេងៗនៅកម្ពុជា។

**អត្រា 0 ភាគរយ÷** ចំពោះប្រាក់ចំណូលរបស់គម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ដែលស្ថិតនៅក្នុងរយៈពេលលើកលែងពន្ធលើប្រាក់ចំណូល ដែលកំណត់ដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។

**អត្រាកំណើនតាមថ្នាក់ ពី 0 ដល់ ២០ ភាគរយ÷** ចំពោះប្រាក់ចំណូលជាប់ពន្ធដែលសម្រេចបានដោយរូបវន្តបុគ្គល សហគ្រាសឯកបុគ្គល និងសមាជិកម្នាក់ៗរបស់ក្រុមហ៊ុនសហកម្មសិទ្ធិ ដែលមិនត្រូវបានចាត់ទុកជានីតិបុគ្គល ។

**17-ពន្ធលើប្រាក់ចំណូលត្រូវបង់÷** គឺជាចំនួនទឹកប្រាក់ពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំត្រូវបង់ ដែលបានគណនា និងកត់ត្រានៅក្នុងប្រអប់ E59 នៃតារាង TOI 01/VII (ទំព័រ ១០/១៦ នៃលិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ)។

**18-ឥណទានពន្ធយោងទៅមុខ÷** គឺជាចំនួនទឹកប្រាក់ឥណទានពន្ធដែលបានគណនា និងកត់ត្រានៅក្នុងប្រអប់ E59 នៃតារាង TOI 01/VII (ទំព័រ១០/១៦ នៃលិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ)។

**កំណត់សម្គាល់÷** ត្រូវបំពេញតែមួយប្រអប់ គឺប្រអប់ទី 17 “**ពន្ធលើប្រាក់ចំណូលត្រូវបង់**” ឬប្រអប់ទី 18 “**ឥណទានពន្ធយោងទៅមុខ**”។

**ការប្រកាសអះអាងរបស់អ្នកជាប់ពន្ធ÷** លិខិតប្រកាសពន្ធលើប្រាក់ចំណូលនេះ ត្រូវតែចុះហត្ថលេខាដោយអភិបាល ឬបណ្ណាធិការ ឬកម្មសិទ្ធិករសហគ្រាស ឬភ្នាក់ងារសេវាកម្មពន្ធដារនៅទំព័រទី១ ហើយត្រូវបោះត្រារបស់សហគ្រាសគ្រប់ទំព័រ។ លិខិតប្រកាសនេះត្រូវចុះកាលបរិច្ឆេទនៅថ្ងៃចុះហត្ថលេខា ហើយត្រូវប្រកាសនៅទីកន្លែងដែលចុះហត្ថលេខានោះ។

# ទំព័រទី២ (TOI 01/II)÷ ព័ត៌មានទូទៅរបស់សហគ្រាស

## ការចូលរួមមូលធនគិតត្រឹមការិយបរិច្ឆេទ

| ខ្លឹមសារនៅក្នុងលិខិតប្រកាស | សេចក្តីពន្យល់ |
|---|---|
| **ក. មូលធន/មូលធនភាគហ៊ុនចុះបញ្ជី** | |
| **ឈ្មោះអ្នកចូលហ៊ុន (ឈ្មោះរូបវន្តបុគ្គល/នីតិបុគ្គល)÷** | ផ្នែកនេះត្រូវបំពេញឈ្មោះអ្នកចូលហ៊ុនឱ្យបានត្រឹមត្រូវ។ បើអ្នកចូលហ៊ុនជានីតិបុគ្គល ឈ្មោះអ្នកចូលហ៊ុន គឺជាឈ្មោះដែលបញ្ជាក់នៅក្នុងអនុសារណៈ និងលក្ខន្តិកៈរបស់ក្រុមហ៊ុន។ ចំពោះក្រុមហ៊ុនសហកម្មសិទ្ធិ ឈ្មោះអ្នកចូលហ៊ុន គឺជាឈ្មោះដែលមានបញ្ជាក់នៅក្នុងកិច្ចព្រមព្រៀងក្រុមហ៊ុនសហកម្មសិទ្ធិ។ ចំពោះសហគ្រាសឯកកម្មសិទ្ធិ (សហគ្រាសឯកបុគ្គល/រូបវន្តបុគ្គល) ឈ្មោះអ្នកចូលហ៊ុន គឺជាឈ្មោះរបស់ម្ចាស់សហគ្រាស។ |
| **អាសយដ្ឋានបច្ចុប្បន្នរបស់ម្ចាស់ភាគហ៊ុន÷** | ចំពោះម្ចាស់ភាគហ៊ុនដែលជានីតិបុគ្គល អាសយដ្ឋានបច្ចុប្បន្នរបស់ម្ចាស់ភាគហ៊ុន គឺជាអាសយដ្ឋានទីស្នាក់ការសហគ្រាសបច្ចុប្បន្នដូចបានពន្យល់នៅក្នុងប្រអប់ 8 ខាងលើ។ ដោយឡែក ចំពោះអ្នកចូលហ៊ុនជានីតិបុគ្គលបរទេស អាសយដ្ឋានបច្ចុប្បន្នរបស់អ្នកចូលហ៊ុន គឺជាអាសយដ្ឋានដែលចុះបញ្ជីជាមួយអាជ្ញាធរមានសមត្ថកិច្ចរបស់ប្រទេសនោះ។ |
| **មុខងារក្នុងសហគ្រាស÷** | បើម្ចាស់ភាគហ៊ុនជាបុគ្គលម្នាក់ ហើយទទួលខុសត្រូវនៅក្នុងសហគ្រាស នោះមុខងាររបស់ម្ចាស់ភាគហ៊ុននោះត្រូវបង្ហាញនៅក្នុងកូឡោននេះ។<br>**ឧទាហរណ៍÷** បើម្ចាស់ភាគហ៊ុនម្នាក់មានមុខងារជានាយកគ្រប់គ្រងនៅក្នុងសហគ្រាសនោះមុខងារជា "នាយកគ្រប់គ្រង" ត្រូវដាក់នៅក្នុងកូឡោននេះ។ |
| **ភាគហ៊ុន ឬ ចំណែកដែលមាន÷** | |
| **ដើមការិយបរិច្ឆេទ% និងទឹកប្រាក់÷** | ត្រូវកត់ត្រាក្នុងកូឡោននេះនូវចំនួនទាំងពីរ គឺចំនួនភាគរយ និងចំនួនទឹកប្រាក់នៃភាគហ៊ុនដែលកាន់កាប់ទាំងអស់នៅដើមការិយបរិច្ឆេទ។ |
| **ចុងការិយបរិច្ឆេទ% និងទឹកប្រាក់÷** | ត្រូវកត់ត្រាក្នុងកូឡោននេះនូវចំនួនទាំងពីរ គឺចំនួនភាគរយ និងចំនួនទឹកប្រាក់នៃភាគហ៊ុនដែលកាន់កាប់ទាំងអស់នៅការិយបរិច្ឆេទ។<br>**កំណត់សម្គាល់÷** ជាទូទៅកាលបរិច្ឆេទចុងគ្រាគឺថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២x លើកលែងតែ សហគ្រាសមានការិយបរិច្ឆេទគណនេយ្យខុសពីការិយបរិច្ឆេទសារពើពន្ធ (សហគ្រាសបានដាក់ពាក្យស្នើសុំ ហើយត្រូវបានអនុញ្ញាតដោយអគ្គនាយកដ្ឋានពន្ធដារ)។ |

**ខ. មូលធន/មូលធនភាគហ៊ុន (បានបង់)**

**ឈ្មោះអ្នកចូលហ៊ុន (ឈ្មោះរូបវន្តបុគ្គល/នីតិបុគ្គល)÷** ផ្នែកនេះត្រូវបំពេញឈ្មោះអ្នកចូលហ៊ុនឱ្យបានត្រឹមត្រូវ។ បើអ្នកចូលហ៊ុនជានីតិបុគ្គល ឈ្មោះអ្នកចូលហ៊ុន គឺជាឈ្មោះដែលបញ្ជាក់នៅក្នុងអនុសារណៈ និងលក្ខន្តិកៈរបស់ក្រុមហ៊ុន។ ចំពោះក្រុមហ៊ុនសហកម្មសិទ្ធិ ឈ្មោះអ្នកចូលហ៊ុន គឺជាឈ្មោះដែលមានបញ្ជាក់នៅក្នុងកិច្ចព្រមព្រៀងក្រុមហ៊ុនសហកម្មសិទ្ធិ។ ចំពោះសហគ្រាសឯកកម្មសិទ្ធិ (សហគ្រាសរូបវន្តបុគ្គល) ឈ្មោះអ្នកចូលហ៊ុន គឺជាឈ្មោះរបស់ម្ចាស់សហគ្រាស។

**អាសយដ្ឋានបច្ចុប្បន្នរបស់ម្ចាស់ភាគហ៊ុន÷** ចំពោះម្ចាស់ភាគហ៊ុនដែលជានីតិបុគ្គល អាសយដ្ឋានបច្ចុប្បន្នរបស់ម្ចាស់ភាគហ៊ុន គឺជាអាសយដ្ឋានទីស្នាក់សហគ្រាសបច្ចុប្បន្នដូចបានពន្យល់នៅក្នុងប្រអប់ 8 ខាងលើ។ ដោយឡែក ចំពោះអ្នកចូលហ៊ុនជានីតិបុគ្គលបរទេស អាសយដ្ឋានបច្ចុប្បន្នរបស់អ្នកចូលហ៊ុន គឺជាអាសយដ្ឋានដែលចុះបញ្ជីជាមួយអាជ្ញាធរមានសមត្ថកិច្ចរបស់ប្រទេសនោះ។

**មុខងារក្នុងសហគ្រាស÷** បើម្ចាស់ភាគហ៊ុនជាបុគ្គលម្នាក់ ហើយទទួលខុសត្រូវនៅក្នុងសហគ្រាស នោះមុខងាររបស់ម្ចាស់ភាគហ៊ុននោះត្រូវបង្ហាញនៅក្នុងក្លោននេះ។

**ឧទាហរណ៍÷** បើម្ចាស់ភាគហ៊ុនម្នាក់មានមុខងារជានាយកគ្រប់គ្រងនៅក្នុងសហគ្រាសនោះមុខងារជា "នាយកគ្រប់គ្រង" ត្រូវដាក់នៅក្នុងក្លោននេះ។

**ភាគហ៊ុន ឬ ចំណែកដែលមាន÷**

**ដើមការិយបរិច្ឆេទ% និងទឹកប្រាក់÷** ត្រូវកត់ត្រាក្នុងក្លោននេះនូវចំនួនទាំងពីរ គឺចំនួនភាគរយ និងចំនួនទឹកប្រាក់នៃភាគហ៊ុនដែលបានបង់ទាំងអស់នៅដើមការិយបរិច្ឆេទ។

**ចំនួនភាគរយ** គឺជាផលធៀបរវាងទឹកប្រាក់ដែលបានបង់ដើមការិយបរិច្ឆេទធៀបជាមួយដើមទុនចុះបញ្ជីសរុប។

**ចំនួនទឹកប្រាក់** គឺស្មើនឹងទឹកប្រាក់សម្រាប់ឆ្នាំ N-1 នៃ **"A30: មូលធន/មូលធនភាគហ៊ុន/មូលនិធិសាខាក្រុមហ៊ុនបរទេស ឬការិយាល័យតំណាង"** នៃតារាង TOI 01/III។

**ចុងការិយបរិច្ឆេទ% និងទឹកប្រាក់÷** ត្រូវកត់ត្រាក្នុងក្លោននេះនូវចំនួនទាំងពីរ គឺចំនួនភាគរយ និងចំនួនទឹកប្រាក់នៃភាគហ៊ុនដែលបានបង់ទាំងអស់នៅចុងការិយបរិច្ឆេទ។

**ចំនួនភាគរយ** គឺជាផលធៀបរវាងទឹកប្រាក់ដែលបានបង់ចុងការិយបរិច្ឆេទធៀបជាមួយដើមទុនចុះបញ្ជីសរុប។

**ចំនួនទឹកប្រាក់** គឺស្មើនឹងទឹកប្រាក់សម្រាប់ឆ្នាំ N នៃ **"A30: មូលធន/មូលធនភាគហ៊ុន/មូលនិធិសាខាក្រុមហ៊ុនបរទេស ឬការិយាល័យតំណាង"** នៃតារាង TOI 01/III។

## ព័ត៌មានអំពីនិយោជិតសហគ្រាសនៅក្នុងការិយបរិច្ឆេទ

| <u>**ខ្លឹមសារនៅក្នុងលិខិតប្រកាស**</u> | <u>**សេចក្តីពន្យល់**</u> |
|---|---|
| **1-អ្នកគ្រប់គ្រងជាអ្នកចូលហ៊ុន÷** | ត្រូវកត់ត្រាឈ្មោះអ្នកចូលហ៊ុនទាំងអស់ ដែលមានមុខងារជាអ្នកគ្រប់គ្រងនៅក្នុងសហគ្រាស។ |
| **2-អ្នកគ្រប់គ្រងមិនមែនជាអ្នកចូលហ៊ុន÷** | ត្រូវកត់ត្រាឈ្មោះបុគ្គលិក មានមុខងារជាអ្នកគ្រប់គ្រងនៅក្នុងសហគ្រាស ប៉ុន្តែមិនមែនជាអ្នកចូលហ៊ុន។ |
| **3-សរុបបុគ្គលិក-កម្មករ÷** | ត្រូវកត់ត្រាចំនួនបុគ្គលិក-កម្មករសរុបដែលនៅបន្តបម្រើការងារឱ្យសហគ្រាសនៅចុងឆ្នាំជាប់ពន្ធ ហើយមិនមានមុខងារជាអ្នកគ្រប់គ្រងនៅក្នុងសហគ្រាស។ |
| **4-បុគ្គលិក-កម្មករជាប់ពន្ធលើប្រាក់បៀវត្ស÷** | ត្រូវកត់ត្រាចំនួនបុគ្គលិក-កម្មករ ដែលមិនមានមុខងារជាអ្នកគ្រប់គ្រងនៅក្នុងសហគ្រាស ដែលមានមូលដ្ឋានប្រាក់បៀវត្សប្រចាំខែដល់កម្រិតជាប់ពន្ធលើប្រាក់បៀវត្សក្នុងឆ្នាំជាប់ពន្ធ។ ចំនួននៅក្នុងផ្នែកនេះ គឺជាចំនួនដែលបំបែកចេញពីចំនួនសរុបបុគ្គលិក-កម្មករបញ្ជាក់ខាងលើ។ |
| **តួនាទី÷** | ត្រូវកត់ត្រានូវមុខងាររបស់អ្នកគ្រប់គ្រងម្នាក់ៗ ដែលបានរាយលម្អិតនៅចំណុច “**1-អ្នកគ្រប់គ្រងជាអ្នកចូលហ៊ុន**” និងចំណុច “**2-អ្នកគ្រប់គ្រងមិនមែនជាអ្នកចូលហ៊ុន**”។ |
| **ចំនួន÷** | - **សរុបបុគ្គលិក-កម្មករ** ត្រូវកត់ត្រាចំនួនបុគ្គលិក-កម្មករទាំងអស់ដែលមានមុខងារមិនមែនជាអ្នកគ្រប់គ្រងនៅក្នុងសហគ្រាស ហើយដែលមានប្រាក់បៀវត្សជាប់ពន្ធ និងមិនត្រូវជាប់ពន្ធលើប្រាក់បៀវត្ស។<br>- **បុគ្គលិក-កម្មករជាប់ពន្ធលើប្រាក់បៀវត្ស** ត្រូវកត់ត្រាចំនួនសរុបបុគ្គលិកទាំងអស់ ដែលមិនមែនជាអ្នកគ្រប់គ្រងនៅក្នុងសហគ្រាសហើយដែលមានប្រាក់បៀវត្សត្រូវជាប់ពន្ធលើប្រាក់បៀវត្សក្នុងឆ្នាំជាប់ពន្ធ។ |
| **ប្រាក់បៀវត្សក្រៅពីអត្ថប្រយោជន៍បន្ថែម÷** | - **អ្នកគ្រប់គ្រងជាអ្នកចូលហ៊ុន និងអ្នកគ្រប់គ្រងមិនមែនជាអ្នកចូលហ៊ុន** ត្រូវកត់ត្រាចំនួនទឹកប្រាក់សរុបដែលបានបើកឱ្យអ្នកគ្រប់គ្រងម្នាក់ៗ។<br>- **សរុបបុគ្គលិក-កម្មករ** ត្រូវកត់ត្រាចូលចំនួនទឹកប្រាក់បៀវត្សសរុបបានបើកឱ្យបុគ្គលិក-កម្មករទាំងអស់ ដែលមានមុខងារមិនមែនជាអ្នកគ្រប់គ្រងនៅក្នុងសហគ្រាស។<br>- **បុគ្គលិក-កម្មករជាប់ពន្ធលើប្រាក់បៀវត្ស** ត្រូវកត់ត្រាចូលចំនួនទឹកប្រាក់បៀវត្សសរុបបានបើកឱ្យបុគ្គលិកទាំងអស់ ដែលមិនមែនជាអ្នកគ្រប់គ្រងនៅក្នុងសហគ្រាស ហើយដែលមានប្រាក់បៀវត្សត្រូវជាប់ពន្ធលើប្រាក់បៀវត្សក្នុងឆ្នាំជាប់ពន្ធ។ |

**អត្ថប្រយោជន៍បន្ថែម៖**

- **អ្នកគ្រប់គ្រងជាអ្នកចូលហ៊ុន និងអ្នកគ្រប់គ្រងមិនមែនជាអ្នកចូលហ៊ុន** ត្រូវកត់ត្រាចូលអត្ថប្រយោជន៍បន្ថែម ដែលបានផ្តល់ជូនអ្នកគ្រប់គ្រងម្នាក់ៗនៅក្នុងឆ្នាំជាប់ពន្ធ។
- **សរុបបុគ្គលិក-កម្មករ** ត្រូវកត់ត្រាអត្ថប្រយោជន៍បន្ថែមសរុបដែលបានបើកឱ្យបុគ្គលិក-កម្មករ ទាំងអស់ដែលមានមុខងារមិនមែនជាអ្នកគ្រប់គ្រងនៅក្នុងសហគ្រាស។
- **បុគ្គលិក-កម្មករជាប់ពន្ធលើប្រាក់បៀវត្ស** ត្រូវកត់ត្រាអត្ថប្រយោជន៍បន្ថែមសរុបដែលបានបើកឱ្យបុគ្គលិក-កម្មករទាំងអស់ ដែលមិនមែនជាអ្នកគ្រប់គ្រងនៅក្នុងសហគ្រាស ហើយដែលមានប្រាក់បៀវត្សត្រូវជាប់ពន្ធលើប្រាក់បៀវត្សក្នុងឆ្នាំជាប់ពន្ធ។

# ទំព័រទី៣ និងទី៤ (TOI 01/III)÷ តារាងតុល្យការ

| <u>**ខ្លឹមសារនៅក្នុងលិខិតប្រកាស**</u> | <u>**សេចក្ដីពន្យល់**</u> |
|---|---|
| **ការិយបរិច្ឆេទនេះ÷** | ត្រូវកត់ត្រាចំនួនទឹកប្រាក់ឆ្នាំជាប់ពន្ធចរន្ត ស្រង់ចេញពីរបាយការណ៍ហិរញ្ញវត្ថុរបស់សហគ្រាស។ |
| **ការិយបរិច្ឆេទមុន÷** | ត្រូវកត់ត្រាចំនួនទឹកប្រាក់ឆ្នាំជាប់ពន្ធមុន ស្រង់ចេញពីលិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំរបស់សហគ្រាស។ |
| **A0-ទ្រព្យសកម្ម÷** | ត្រូវកត់ត្រាតួលេខសរុបនៅក្នុងប្រអប់ **"A1: ទ្រព្យសកម្មរយៈពេលវែង"** និងប្រអប់ **"A13: ទ្រព្យសកម្មរយៈពេលខ្លី"**។ |
| **A1-ទ្រព្យសកម្មរយៈពេលវែង÷** | ត្រូវកត់ត្រាតម្លៃសរុបនៃទ្រព្យសកម្មរយៈពេលវែងពីប្រអប់ **"A2: ដីធ្លីរបស់សហគ្រាស"** ដល់ប្រអប់ **"A12: ទ្រព្យសកម្មរយៈពេលវែងផ្សេងៗ"**។ |
| **A2-ដីធ្លីរបស់សហគ្រាស÷** | គឺជាដីដែលជាកម្មសិទ្ធិរបស់សហគ្រាស។ |
| **A3-ការរៀបចំតុបតែងលម្អដីធ្លីរបស់សហគ្រាស÷** | គឺជាចំណាយមូលធនកើតឡើង ដើម្បីអភិវឌ្ឍដីធ្លីដែលជាកម្មសិទ្ធិរបស់សហគ្រាស។ |
| **A4-សំណង់អគាររបស់សហគ្រាស÷** | គឺជាសំណង់ និងហេដ្ឋារចនាសម្ព័ន្ធសំណង់ ដែលជាកម្មសិទ្ធិរបស់សហគ្រាស ហើយដែលបានសាងសង់ឡើងនៅលើដីជាកម្មសិទ្ធិរបស់សហគ្រាស។ |
| **A5-សំណង់អគារលើដីធ្លីក្រោមភតិសន្យា÷** | គឺជាសំណង់ និងហេដ្ឋារចនាសម្ព័ន្ធសំណង់ ដែលជាកម្មសិទ្ធិរបស់សហគ្រាស ហើយដែលបានសាងសង់ឡើងនៅលើដីធ្លីក្រោមភតិសន្យា។ |
| **A6-ទ្រព្យសកម្មរយៈពេលវែងកំពុងដំណើរការ÷** | ត្រូវបង្ហាញអំពីចំណាយមូលធនលើប្រតិបត្តិការសាងសង់ ឬផ្គុំតម្លើងមិនទាន់រួច ហើយទ្រព្យសកម្មនេះមិនទាន់ដាក់ប្រើប្រាស់នៅឡើយ។ |
| **A7-រោងចក្រ (ក្រៅពីអគារ) និងបរិក្ខារ÷** | ត្រូវកត់ត្រាតម្លៃនៃរោងចក្រ និងគ្រឿងបរិក្ខាររបស់រោងចក្រ ប៉ុន្តែត្រូវដកចេញតម្លៃនៃអគាររបស់រោងចក្រ។ |
| **A8-កេរ្តិ៍ឈ្មោះ/មូលនិធិពាណិជ្ជកម្ម÷** | ត្រូវកត់ត្រាតម្លៃលើសដែលកើតពីលម្អៀងរវាងតម្លៃទិញ និងតម្លៃទ្រព្យសកម្មសុទ្ធដែលបានទិញ ឬលទ្ធកម្ម។ |
| **A9-ចំណាយបង្កើតសហគ្រាសដំបូង÷** | គឺជាចំណាយកើតឡើងនៅពេលបង្កើតសហគ្រាស មុនពេលសហគ្រាសចាប់ផ្ដើមប្រតិបត្តិការអាជីវកម្ម ហើយចំណាយនេះមិនអាចយកទៅបញ្ចូលក្នុងទ្រព្យសកម្មណាមួយបាន។<br>**កំណត់សម្គាល់÷** ចំណាយបង្កើតសហគ្រាស អាចកត់ត្រាចូលជាចំណាយបែងចែកមិនឱ្យលើសពីរយៈពេល ២ឆ្នាំ។ |
| **A10-ទ្រព្យសកម្មក្រោមភតិសន្យា និងបុព្វលាភនៃការប្រើប្រាស់÷** | ត្រូវបង្ហាញតម្លៃនៃទ្រព្យសកម្មរយៈពេលវែង ដែលសហគ្រាសទទួលបានក្រោមភតិសន្យា។ |

| | |
|---|---|
| **A11-វិនិយោគក្នុងសហគ្រាសដទៃ÷** | ត្រូវបង្ហាញនូវផលប្រយោជន៍របស់សហគ្រាសដែលមាននៅក្នុងសហគ្រាសដទៃ ហើយដែលជាទូទៅផលប្រយោជន៍នេះបង្ហាញដោយភាគហ៊ុនកាន់កាប់ដោយសហគ្រាស។ |
| **A12-ទ្រព្យសកម្មរយៈពេលវែងផ្សេងៗ÷** | ត្រូវកត់ត្រាតម្លៃនៃទ្រព្យសកម្មរយៈពេលវែងដទៃទៀតទាំងអស់។ |
| **A13-ទ្រព្យសកម្មរយៈពេលខ្លី÷** | ត្រូវកត់ត្រាតម្លៃសរុបនៃទ្រព្យសកម្មរយៈពេលខ្លីយកចេញពីប្រអប់ **"A14: ស្តុកវត្ថុធាតុដើម និងសម្ភារផ្គត់ផ្គង់"** ដល់ប្រអប់ **"A27: លម្អៀងពីការប្តូរប្រាក់នៃទ្រព្យសកម្ម"**។ |
| **A14-ស្តុកវត្ថុធាតុដើម និងសម្ភារផ្គត់ផ្គង់÷** | ត្រូវកត់ត្រាតម្លៃនៃស្តុកវត្ថុធាតុដើម និងសម្ភារផ្គត់ផ្គង់ផ្សេងៗដែលប្រើប្រាស់នៅក្នុងការផលិត និងស្តុកដែលសហគ្រាសនៅសល់នៅចុងការិយបរិច្ឆេទ។ ចំនួននៅប្រអប់នេះត្រូវស្មើទៅនឹង **"C5: ស្តុកវត្ថុធាតុដើម និងសម្ភារផ្គត់ផ្គង់ចុងគ្រា"**។ |
| **A15-ស្តុកទំនិញ÷** | គឺជាតម្លៃនៃស្តុកទំនិញ ឬទំនិញទិញទុកសម្រាប់លក់ចេញវិញក្នុងលក្ខណៈជាការធ្វើសកម្មភាពផ្នែកពាណិជ្ជកម្ម ដែលសហគ្រាសនៅសល់នៅចុងការិយបរិច្ឆេទហើយចំនួននេះត្រូវស្មើទៅនឹង **"D8: ស្តុកទំនិញនៅចុងគ្រា"**។ |
| **A16-ស្តុកផលិតផលសម្រេច÷** | គឺជាតម្លៃនៃស្តុកផលិតផលសម្រេច ដែលផលិតបាននៅសល់ចុងការិយបរិច្ឆេទ ហើយចំនួននេះត្រូវស្មើទៅនឹង **"C19: ស្តុកផលិតផលសម្រេចនៅចុងគ្រា"**។ |
| **A17-ផលិតផលកំពុងផលិត÷** | គឺជាតម្លៃនៃផលិតផលកំពុងដំណើរការ ឬផលិតផលមិនទាន់សម្រេច ឬការងារមិនទាន់បានបញ្ចប់នៅចុងការិយបរិច្ឆេទ ហើយចំនួននេះត្រូវស្មើទៅនឹង **"C16: ការងារកំពុងដំណើរការ ឬស្តុកកំពុងផលិតនៅចុងគ្រា"**។ |
| **A18-គណនីត្រូវទទួល/អតិថិជន÷** | គឺជាចំនួនទឹកប្រាក់ដែលអតិថិជនជំពាក់សហគ្រាស។ |
| **A19-គណនីត្រូវទទួលផ្សេងៗ÷** | គឺជាចំនួនទឹកប្រាក់ដែលរូបវន្តបុគ្គល ឬអង្គភាពដទៃទៀតក្រៅពីអតិថិជនធម្មតាជំពាក់សហគ្រាស។<br><br>**ឧទាហរណ៍÷** កម្ចីដែលបានផ្តល់ឱ្យភាគីទី៣ (ភាគីតតិយជន) ឬទឹកប្រាក់ដែលម្ចាស់ភាគហ៊ុនជំពាក់សហគ្រាស។ |
| **A20-ចំណាយបានកត់ត្រាមុន÷** | គឺជាចំនួនទឹកប្រាក់ដែលបានចំណាយ ប៉ុន្តែមិនត្រូវបានទទួលស្គាល់ជាចំណាយទាំងស្រុងក្នុងឆ្នាំជាប់ពន្ធ គឺត្រូវទទួលស្គាល់ជាចំណាយតាមរយៈការកាត់បន្ថយបន្តិចម្តងៗ ឬដាក់ជាចំណាយច្រើនការិយបរិច្ឆេទ។<br><br>**ឧទាហរណ៍÷** ចំណាយធានារ៉ាប់រង ចំណាយជួលបង់មុន ...។ |
| **A21-សាច់ប្រាក់នៅក្នុងបេឡា÷** | ត្រូវកត់ត្រាចំនួនសាច់ប្រាក់សរុបដែលសហគ្រាសមាននៅក្នុងដៃ។ |
| **A22-សាច់ប្រាក់នៅធនាគារ÷** | ត្រូវកត់ត្រាចំនួនសាច់ប្រាក់សរុបដែលសហគ្រាសមាននៅក្នុងធនាគារ។ |

**A23- ឥណទានប្រាក់រំដោះពន្ធលើប្រាក់ចំណូល÷** គឺត្រូវបង្ហាញចំនួនទឹកប្រាក់រំដោះពន្ធលើប្រាក់ចំណូល ដែលបានបង់ហើយ ដែលត្រូវបានអនុញ្ញាតជាឥណទានពន្ធសម្រាប់យោងទៅកាត់កងឆ្នាំជាប់ពន្ធបន្ទាប់។

**A24- ឥណទានអាករលើតម្លៃបន្ថែម÷** ត្រូវបង្ហាញចំនួនទឹកប្រាក់លើសនៃឥណទានអាករលើធាតុចូល និងអាករលើធាតុចេញ។

**A25- ឥណទានពន្ធ-អាករដទៃទៀត÷** គឺត្រូវបង្ហាញតួលេខឥណទានពន្ធ-អាករដទៃទៀត ក្រៅពីឥណទានប្រាក់រំដោះពន្ធលើប្រាក់ចំណូល និងឥណទានអាករលើតម្លៃបន្ថែម។

**A26- ទ្រព្យសកម្មរយៈពេលខ្លីផ្សេងៗ÷** ត្រូវកត់ត្រាតម្លៃនៃទ្រព្យសកម្មរយៈពេលខ្លីដទៃទៀតទាំងអស់។

**A27- លម្អៀងពីការប្តូរប្រាក់នៃទ្រព្យសកម្ម÷** ជាចំនួនទឹកប្រាក់លម្អៀងកើនឡើង ដែលកើតមានឡើងពីការដាក់បញ្ចូលគ្នានូវរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ហើយក្រុមហ៊ុនទាំងនោះប្រើប្រាស់រូបិយប័ណ្ណសម្រាប់កត់ត្រាខុសពីរូបិយវត្ថុរបាយការណ៍។ ម្យ៉ាងទៀត លម្អៀងពីអត្រាប្តូរប្រាក់នេះកើតឡើងរវាងរូបិយប័ណ្ណកត់ត្រា និងរូបិយវត្ថុរបាយការណ៍។

**A28- មូលនិធិ/ទុនម្ចាស់ទ្រព្យនិងបំណុល÷** តួលេខប្រអប់នេះបានពីការគណនាដោយយក **“A29: មូលនិធិ/ទុនម្ចាស់ទ្រព្យ”** បូក **“A37: បំណុលរយៈពេលវែង”** បូក **“A42: បំណុលរយៈពេលខ្លី”**។

**កំណត់សម្គាល់÷ “A0: ទ្រព្យសកម្ម”** ត្រូវស្មើ **“A28: មូលនិធិ/ទុនម្ចាស់ទ្រព្យនិងបំណុល”**។

**A29- មូលនិធិ/ទុនម្ចាស់ទ្រព្យ÷** ត្រូវកត់ត្រាចំនួនសរុបពីប្រអប់ **“A30: មូលធន/មូលធនភាគហ៊ុន/មូលនិធិសាខាក្រុមហ៊ុនបរទេស ឬការិយាល័យតំណាង”** ដល់ប្រអប់ **“A36: លទ្ធផលចំណេញ /(ខាត) នៃការិយបរិច្ឆេទនេះ”**។

**A30- មូលធន/មូលធនភាគហ៊ុន/មូលនិធិសាខាក្រុមហ៊ុនបរទេស ឬការិយាល័យតំណាង÷** គឺជាតម្លៃនៃភាគហ៊ុន ឬតម្លៃមូលធនដែលបានបង់ចូលសហគ្រាសសម្រាប់ជាចំណែកហ៊ុនរបស់ម្ចាស់ភាគហ៊ុន ឬមូលនិធិដែលក្រុមហ៊ុនបរទេសបានផ្តល់ឱ្យសាខាក្រុមហ៊ុនបរទេស ឬការិយាល័យតំណាង។

**A31- តម្លៃលើសនៃការលក់ប័ណ្ណភាគហ៊ុន÷** គឺជាតម្លៃលើសពីតម្លៃចារឹកលើប័ណ្ណភាគហ៊ុន ដែលសហគ្រាសទទួលបានពីការលក់ប័ណ្ណភាគហ៊ុនទាំងនោះ។

**A32- មូលធនបម្រុងតាមច្បាប់÷** គឺជាតួលេខមូលធនបម្រុងទាំងឡាយណាដែលតម្រូវដោយលក្ខន្តិកៈ ឬអនុស្សរណៈរបស់សហគ្រាសដែលកំណត់ដោយច្បាប់ពាណិជ្ជកម្ម និងច្បាប់ដទៃទៀត។

**A33- លម្អៀងលើសនៃការវាយតម្លៃឡើងវិញនូវទ្រព្យសកម្ម÷** គឺជាតម្លៃលើសទទួលបានពីការវាយតម្លៃឡើងវិញ នូវទ្រព្យសកម្មរបស់សហគ្រាស។

**A34- មូលធនបម្រុងផ្សេងៗ÷** ត្រូវកត់ត្រាតួលេខមូលធនបម្រុងផ្សេងៗទាំងអស់ ដែលសម្រេចដោយក្រុមប្រឹក្សាភិបាលក្រុមហ៊ុន ឬដោយកាតព្វកិច្ចណាមួយ ក្រៅពីមូលធនបម្រុងតាមច្បាប់។

**A35- លទ្ធផលចំណេញ/(ខាត) យោងពីមុន (+ ឬ -)÷** គឺជាចំនួនទឹកប្រាក់ចំណេញ ឬខាតដែលយោងពីឆ្នាំជាប់ពន្ធមុនៗ។

| | |
|---|---|
| **A36-លទ្ធផលចំណេញ/(ខាត) ក្នុងការិយបរិច្ឆេទ (+ ឬ -)៖** | គឺជាចំនួនទឹកប្រាក់ចំណេញ ឬខាតក្នុងឆ្នាំជាប់ពន្ធចរន្ត ហើយចំនួននេះត្រូវស្មើទៅនឹង **"B48: ប្រាក់ចំណេញក្រោយបង់ពន្ធ"**។ |
| **A37-បំណុលរយៈពេលវែង៖** | ត្រូវកត់ត្រាតម្លៃសរុបនៃបំណុលរយៈពេលវែង យកចេញពីប្រអប់ **"A38: បំណុលភាគីជាប់ទាក់ទិន"** ដល់ប្រអប់ **"A41: បំណុលរយៈពេលវែងផ្សេងៗ"**។ |
| **A38-បំណុលភាគីជាប់ទាក់ទិន៖** | គឺជាចំនួនទឹកប្រាក់បំណុលរយៈពេលវែងដែលបានខ្ចីពីម្ចាស់ភាគហ៊ុន ឬអង្គភាពដទៃទៀត ដែលជាបុគ្គលជាប់ទាក់ទិនជាមួយសហគ្រាស។ |
| **A39-បំណុលធនាគារ និងបំណុលភាគីមិនជាប់ទាក់ទិនផ្សេងៗ៖** | គឺជាចំនួនទឹកប្រាក់បំណុលដែលបានខ្ចីពីធនាគារ ឬស្ថាប័នហិរញ្ញវត្ថុ និងបុគ្គលមិនជាប់ទាក់ទិនដទៃទៀត។ |
| **A40-សំវិធានធន៖** | គឺជាចំនួនទឹកប្រាក់បំណុលរយៈពេលវែង សម្រាប់រ៉ាប់រងបន្ទុកចំណាយ ឬការខាតបង់នានាដែលមិនទាន់កើតឡើងជាក់ស្តែង។ |
| **A41-បំណុលរយៈពេលវែងផ្សេងៗ៖** | ត្រូវកត់ត្រាចំនួនទឹកប្រាក់បំណុលរយៈពេលវែងផ្សេងៗទៀតទាំងអស់។ |
| **A42-បំណុលរយៈពេលខ្លី៖** | ត្រូវកត់ត្រាតម្លៃសរុបបំណុលរយៈពេលខ្លីទាំងអស់ ដោយសរុបពីប្រអប់ **"A43: សាច់ប្រាក់ដកពីធនាគារលើសប្រាក់បញ្ញើ (ឥណទានវិបារូប៍រ)"** ដល់ប្រអប់ **"A52: លម្អៀងពីការប្តូរប្រាក់នៃទ្រព្យអកម្ម"**។ |
| **A43-សាច់ប្រាក់ដកពីធនាគារលើសប្រាក់បញ្ញើ (ឥណទានវិបារូប៍រ)៖** | គឺជាគណនីចរន្តរបស់សហគ្រាសនៅធនាគារមានសមតុល្យអវិជ្ជមាន។ |
| **A44-ចំណែកចរន្តនៃបំណុលមានការប្រាក់៖** | គឺជាចំនួនទឹកប្រាក់នៃចំណែកប្រាក់កម្ចីមានការប្រាក់ដែលមានរយៈពេលមិនលើសពី ១២ខែ។ |
| **A45-គណនីត្រូវសងបុគ្គលជាប់ទាក់ទិន (ភាគសម្ព័ន្ធញាតិ)៖** | គឺជាចំនួនទឹកប្រាក់បំណុលដែលជំពាក់ម្ចាស់ភាគហ៊ុន ឬបុគ្គលជាប់ទាក់ទិនដទៃទៀត ដែលត្រូវទូទាត់ក្នុងរយៈពេលមិនលើសពី ១២ខែ។ |
| **A46-គណនីត្រូវសងផ្សេងៗ៖** | គឺជាចំនួនទឹកប្រាក់ដែលជំពាក់អ្នកផ្គត់ផ្គង់ ឬភាគីទី៣ (តតិយជន) ចំពោះការទិញជឿនូវទំនិញ និងសេវា និងការខ្ចីផ្សេងៗពីភាគីមិនជាប់ទាក់ទិន។ |
| **A47-ចំណូលកត់មុន៖** | គឺជាចំនួនទឹកប្រាក់ដែលបានទទួលពីអតិថិជន ប៉ុន្តែមិនទាន់បានផ្គត់ផ្គង់ទំនិញឬសេវានៅឡើយ។ |
| **A48-គណនីចំណាយបង្គរ និងបំណុលរយៈពេលខ្លីផ្សេងៗ៖** | គឺជាចំណាយបានកត់ត្រាបង្គរតាមគោលការណ៍គណនេយ្យ និងបំណុលរយៈពេលខ្លីដទៃផ្សេងៗទៀតទាំងអស់។ |
| **A49-សំវិធានធន៖** | គឺជាបំណុលរយៈពេលខ្លី សម្រាប់រ៉ាប់រងបន្ទុកចំណាយ ឬការខាតបង់នានាដែលមិនទាន់កើតឡើងជាក់ស្តែង។<br>**ឧទាហរណ៍៖** សំវិធានធនសម្រាប់ប្រាក់ប៉ះប៉ូវបន្ថែម លើកទឹកចិត្តបុគ្គលិក និងអ្នកគ្រប់គ្រង ឬសំវិធានធនលើការជួសជុលពន្យារពេល...។ |

**A50-ពន្ធលើប្រាក់ចំណូលត្រូវបង់÷** គឺជាចំនួនប្រាក់ពន្ធលើប្រាក់ចំណូល ដែលត្រូវបង់ជូនរដ្ឋបាលសារពើពន្ធ។ ចំនួននេះអាចជាចំនួនកត់ត្រាក្នុងប្រអប់ E59 បូកបញ្ចូលបំណុលពន្ធលើប្រាក់ចំណូលពីឆ្នាំជាប់ពន្ធមុនៗ ប្រសិនបើមាន។

**A51-ពន្ធ-អាករផ្សេងៗត្រូវបង់÷** គឺជាចំនួនទឹកប្រាក់បំណុលពន្ធ-អាករដទៃទៀតរួមមាន÷ អាករលើតម្លៃបន្ថែមត្រូវបង់ ពន្ធលើប្រាក់បៀវត្ស ពន្ធកាត់ទុក ប្រាក់រំដោះពន្ធលើប្រាក់ចំណូល ... ដែលសហគ្រាសត្រូវបង់ជូនរដ្ឋបាលសារពើពន្ធ។

**A52-លម្អៀងពីការប្តូរប្រាក់នៃទ្រព្យអកម្ម÷** គឺជាចំនួនទឹកប្រាក់លម្អៀងថយចុះ ដែលកើតមានឡើងពីការដាក់បញ្ចូលគ្នានូវរបាយការណ៍ហិរញ្ញវត្ថុរួមរបស់ក្រុមហ៊ុន ហើយក្រុមហ៊ុនទាំងនោះប្រើប្រាស់រូបិយប័ណ្ណសម្រាប់កត់ត្រាខុសពីរូបិយវត្ថុរាយការណ៍។ ម្យ៉ាងទៀត លម្អៀងពីអត្រាប្តូរប្រាក់នេះកើតឡើងរវាងរូបិយប័ណ្ណកត់ត្រា និងរូបិយវត្ថុរាយការណ៍។

## ទំព័រទី៥ និងទី៦ (TOI 01/IV)÷ របាយការណ៍លទ្ធផល

| ខ្លឹមសារនៅក្នុងលិខិតប្រកាស | សេចក្ដីពន្យល់ |
|---|---|
| **B0- ចំណូលប្រតិបត្តិការ÷** | គឺជាចំនួនសរុបនៃចំណូលពីសកម្មភាពអាជីវកម្ម ដែលបានមកពីការផ្គត់ផ្គង់ទំនិញឬសេវា ដែលមានបញ្ជាក់លើប័ណ្ណពន្ធប៉ាតង់របស់សហគ្រាស។ សរុបប្រអប់ "**B1: ការលក់ផលិតផល**" ដល់ប្រអប់ "**B3: ការផ្គត់ផ្គង់សេវា**" ។ |
| **B1- ការលក់ផលិតផល÷** | ត្រូវកត់ត្រាចំណូលសរុប ពីការលក់ផលិតផលសម្រេចក្នុងការិយបរិច្ឆេទ។ |
| **B2- ការលក់ទំនិញ÷** | ត្រូវកត់ត្រាចំណូលសរុប ពីការលក់ទំនិញក្នុងការិយបរិច្ឆេទ។ |
| **B3- ការផ្គត់ផ្គង់សេវា÷** | គឺជាតម្លៃសរុប នៃការផ្គត់ផ្គង់សេវាជូនអតិថិជនក្នុងការិយបរិច្ឆេទ។ |
| **B4- ថ្លៃដើមផលិតផលបានលក់របស់សហគ្រាសផលិតកម្ម (TOI 01/V, C20) ÷** | ត្រូវកត់ត្រាចំនួនទឹកប្រាក់យកចេញពីប្រអប់ "**C20: ថ្លៃដើមផលិតផលសម្រេចបានលក់**" នៅក្នុង TOI 01/V។ |
| **B5- ថ្លៃដើមទំនិញបានលក់របស់សហគ្រាសក្រៅពីផលិតកម្ម (TOI 01/VI, D9) ÷** | ត្រូវកត់ត្រាចំនួនទឹកប្រាក់យកចេញពីប្រអប់ "**D9: ថ្លៃដើមទំនិញដែលបានលក់**" នៅក្នុង TOI 01/VI។ |
| **B6- ថ្លៃដើមសេវាបានផ្គត់ផ្គង់÷** | ត្រូវកត់ត្រាចំនួនទឹកប្រាក់ថ្លៃដើម នៃសេវាដែលបានផ្គត់ផ្គង់ក្នុងការិយបរិច្ឆេទ។ |
| **B7- ចំណេញដុល÷** | ប្រាក់ចំណេញដុលត្រូវគណនាដោយយកប្រអប់ "**B0: ចំណូលប្រតិបត្តិការ**" ដក "**B4: ថ្លៃដើមផលិតផលបានលក់របស់សហគ្រាសផលិតកម្ម**" ដក "**B5: ថ្លៃដើមទំនិញរបស់សហគ្រាសក្រៅពីផលិតកម្ម**" ដក "**B6: ថ្លៃដើមសេវាបានផ្គត់ផ្គង់**" ។ |
| **B8- ចំណូលបន្ទាប់បន្សំ÷** | ត្រូវកត់ត្រាតម្លៃសរុបពីប្រអប់ "**B9: ចំណូលពីការជួលបានទទួល ឬត្រូវទទួល**" ដល់ប្រអប់ "**B11: ចំណូលបន្ទាប់បន្សំដទៃទៀត**" ។ |
| **B9- ចំណូលពីការជួលបានទទួល ឬត្រូវទទួល÷** | គឺជាចំណូលបានទទួល ឬត្រូវទទួលពីការជួល ឬភតិសន្យានៃទ្រព្យសកម្មរយៈពេលវែង។ |
| **B10- ចំណូលពីសួយសារបានទទួល ឬត្រូវទទួល÷** | គឺជាចំណូលបានទទួល ឬត្រូវទទួលពីការឱ្យប្រើប្រាស់ទ្រព្យសកម្មអរូបី របស់សហគ្រាសដូចជា ប្រកាសនីយបត្រតក្កកម្ម សិទ្ធិចម្លង គំនូរ គំរូ ប្លង់ សិទ្ធិអាជីវកម្ម សញ្ញាផលិត វិធីធ្វើ ...។ |
| **B11- ចំណូលបន្ទាប់បន្សំដទៃទៀត÷** | គឺជាចំណូលដទៃទៀត ដែលសហគ្រាសបានទទួល ឬត្រូវទទួលក្នុងការិយបរិច្ឆេទជាបន្ទាប់បន្សំ។ |
| **B12- ចំណូលផ្សេងៗ÷** | ត្រូវកត់ត្រាតម្លៃសរុបពីប្រអប់ "**B13: ឧបត្ថម្ភកធន**" ដល់ប្រអប់ "**B21: ចំណូលដទៃទៀត**" ។ |
| **B13- ឧបត្ថម្ភកធន÷** | គឺជាចំណូលទទួលបានពីការឧបត្ថម្ភផ្សេងៗ ពីសហគ្រាសដទៃ ឬរដ្ឋាភិបាល។ |
| **B14- ចំណូលពីភាគលាភបានទទួល ឬត្រូវទទួល÷** | គឺជាចំណូលភាគលាភបានទទួល ឬត្រូវទទួលពីការវិនិយោគនៅក្នុងសហគ្រាសដទៃទៀត។ |

| | |
|---|---|
| **B15-ចំណូលពីការប្រាក់បានទទួល ឬត្រូវទទួល÷** | គឺជាចំណូលការប្រាក់បានទទួល ឬត្រូវទទួលពីឥណទេយ្យ ប្រាក់ធានា គណនីសន្សំ គណនីចរន្ត...។ |
| **B16-ផលចំណេញ/តម្លៃលើសពីការលក់ទ្រព្យសកម្មរយៈពេលវែង÷** | គឺជាប្រាក់ចំណេញទទួលបានពីការលក់ទ្រព្យសកម្មរយៈពេលវែង ដែលជាកម្មសិទ្ធិរបស់សហគ្រាស ហើយជាលទ្ធផលបានពីការគណនាដោយយកតម្លៃលក់ដកតម្លៃនៅសល់មិនទាន់រំលស់ (តាមគណនេយ្យ)។ ក្នុងករណីនេះ តម្លៃលក់ធំជាងតម្លៃនៅសល់មិនទាន់រំលស់តាមគណនេយ្យ។ |
| **B17-ផលចំណេញពីការលក់មូលបត្រ/សញ្ញាប័ណ្ណ÷** | គឺជាប្រាក់ចំណេញទទួលបានពីការលក់មូលបត្រ/ សញ្ញាប័ណ្ណ ដែលសហគ្រាសវិនិយោគនៅក្នុងសហគ្រាសដទៃទៀត ហើយការគណនាប្រាក់ចំណេញនេះត្រូវយកតម្លៃលក់ ដកថ្លៃដើម (លទ្ធកម្ម) របស់មូលបត្រ/ សញ្ញាប័ណ្ណ។ |
| **B18-ភាគចំណេញពីប្រតិបត្តិការរួមគ្នា÷** | គឺជាប្រាក់ចំណេញទទួលបានពីសកម្មភាពអាជីវកម្ម ដែលសហគ្រាសគ្រប់គ្រងរួមគ្នាជាមួយសហគ្រាសដទៃ (Jointly controlled entities)។ |
| **B19-ផលចំណេញពីការប្តូរប្រាក់សម្រេចបាន÷** | គឺជាផលចំណេញហិរញ្ញវត្ថុ ដែលទទួលបានពីអត្រាប្តូរប្រាក់រវាងរូបិយប័ណ្ណប្រតិបត្តិការ និងរូបិយវត្ថុកត់ត្រាក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់សហគ្រាស។ |
| **B20-ផលចំណេញពីការប្តូរប្រាក់មិនទាន់សម្រេចបាន÷** | គឺជាផលចំណេញពីការប្តូរប្រាក់មិនទាន់សម្រេចបាន ចំពោះទ្រព្យសកម្មដែលគ្រប់គ្រងដោយសហគ្រាស ឬបំណុលត្រូវទូទាត់ដោយសហគ្រាស។ |
| **B21-ចំណូលដទៃទៀត÷** | គឺជាចំណូលដទៃទៀត ដែលសហគ្រាសទទួលបានក្នុងការិយបរិច្ឆេទ។ |
| **B22-ចំណាយប្រតិបត្តិការ÷** | ត្រូវកត់ត្រាតម្លៃសរុបនៃចំណាយប្រតិបត្តិការពីប្រអប់ “**B23: ចំណាយបៀវត្ស**” ដល់ប្រអប់ “**B41: ចំណាយផ្សេងៗ**” ។ |
| **B23-ចំណាយបៀវត្ស÷** | គឺជាចំណាយបៀវត្សសរុបដែលបានទូទាត់ និងត្រូវទូទាត់ឱ្យដល់អ្នកគ្រប់គ្រង និងបុគ្គលិក-កម្មករ ដែលបម្រើការងារឱ្យសហគ្រាស រួមទាំងចំណាយលើអត្ថប្រយោជន៍បន្ថែម។ ចំណាយនេះមិនគិតបញ្ចូលចំណាយលើអ្នកគ្រប់គ្រង និងកម្មករ បម្រើការងារផ្នែកផលិតកម្មទេ (ចំណាយលើអ្នកគ្រប់គ្រង និងកម្មករបម្រើការងារផ្នែកផលិតកម្ម ត្រូវដាក់បញ្ចូលទៅក្នុងថ្លៃដើមផលិតផលនៅប្រអប់ “**C8: ប្រាក់បៀវត្សអ្នកគ្រប់គ្រង និងកម្មករសម្រាប់ការផលិត**”)។ |
| **B24-ចំណាយប្រេង ឧស្ម័ន អគ្គិសនី និងទឹក÷** | ត្រូវកត់ត្រាចំណាយប្រេង ឧស្ម័ន ថ្លៃអគ្គិសនី ថាមពលផ្សេងៗ និងទឹក លើកលែងតែចំណាយថ្លៃប្រេងឥន្ធនៈ ទឹក និងថាមពលផ្សេងៗ ដែលបានកត់ត្រាក្នុង TOI 01/V ប្រអប់ “**C10: ប្រេងឥន្ធនៈ ទឹក និងថាមពល**” ។ |
| **B25-ចំណាយធ្វើដំណើរ និងចំណាយស្នាក់នៅ÷** | ត្រូវកត់ត្រាចំណាយលើការធ្វើដំណើរ និងចំណាយស្នាក់នៅ ដែលសហគ្រាសបានចំណាយក្នុងសកម្មភាពបម្រើការងារដើម្បីជាប្រយោជន៍សហគ្រាស។ |
| **B26-ចំណាយដឹកជញ្ជូន÷** | ត្រូវកត់ត្រាចំណាយដឹកជញ្ជូនទាំងអស់ លើកលែងតែចំណាយដឹកជញ្ជូនដែលបានគិតបញ្ចូលក្នុងថ្លៃដើមផលិតផល ឬទំនិញ/សេវា។ |
| **B27-ចំណាយលើការជួល÷** | ត្រូវកត់ត្រាចំណាយជួលទ្រព្យសកម្មទាំងអស់ ដែលកើតមានឡើងក្នុងការិយបរិច្ឆេទ។ |

| | |
|---|---|
| **B28-ចំណាយលើការថែទាំ និងជួសជុល÷** | ត្រូវកត់ត្រាចំណាយថែទាំ និងជួសជុលទាំងអស់ដែលកើតមានឡើងក្នុងការិយបរិច្ឆេទ។ ចំណាយទាំងនេះរួមបញ្ចូលទាំងសម្ភារបន្ទាប់បន្សំគ្រឿងបន្លាស់ និងសេវាកម្មផ្សេងៗ។ |
| **B29-ចំណាយលើការកម្សាន្តសប្បាយ÷** | ត្រូវកត់ត្រាចំណាយទទួលភ្ញៀវ បដិសណ្ឋារកិច្ច កម្សាន្ត សម្រាកលំហែផ្សេងៗទាំងអស់ ដែលកើតមានឡើងក្នុងការិយបរិច្ឆេទ។ |
| **B30-ចំណាយកម្រៃជើងសា ផ្សាយពាណិជ្ជកម្ម និងចំណាយលើការលក់÷** | ត្រូវកត់ត្រាចំណាយទាំងឡាយ ដែលកើតមានឡើងសម្រាប់គោលដៅបង្កើនកម្រិតនៃការលក់ផលិតផល ទំនិញ និងសេវា។ |
| **B31-ចំណាយបង់ពន្ធ និងអាករផ្សេងៗ÷** | ចំណាយទាំងនេះរួមបញ្ចូលទាំង ពន្ធប៉ាតង់ អាករសម្រាប់បំភ្លឺសាធារណៈ អាករពិសេសលើទំនិញនិងសេវាមួយចំនួន ពន្ធតែមប្រិ៍សារពើពន្ធ ពន្ធប្រថាប់ត្រា។ល។<br><br>**កំណត់សម្គាល់÷** សម្រាប់សហគ្រាសផលិតកម្ម និងទំនិញទិញដើម្បីលក់ចេញវិញ តួលេខចំណាយបង់ពន្ធក្នុងប្រអប់នេះមិនរួមបញ្ចូលពន្ធផ្សេងៗ ដែលបានកត់ត្រានៅក្នុង TOI 01/VI "**D5: ពន្ធគយនាំចូល និងពន្ធដទៃទៀតដែលជាបន្ទុករបស់សហគ្រាស**" និង TOI 01/V "**C3: ចំណាយផ្សេងៗទាក់ទិនដល់ការទិញវត្ថុធាតុដើម ឬសម្ភារផ្គត់ផ្គង់**" ទេ។ |
| **B32-ចំណាយលើអំណោយ÷** | ត្រូវកត់ត្រាចំណាយលើអំណោយទាំងឡាយដែលបានផ្តល់ឱ្យបុគ្គល ឬអង្គភាពដទៃនៅក្នុងការិយបរិច្ឆេទ។ |
| **B33-ចំណាយសេវាគ្រប់គ្រង ពិគ្រោះយោបល់ បច្ចេកទេស និងសេវាប្រហាក់ប្រហែល÷** | ត្រូវកត់ត្រាចំណាយទាំងអស់ដែលបានផ្តល់ទៅឱ្យទីប្រឹក្សាពិគ្រោះយោបល់ បច្ចេកទេស សេវាគ្រប់គ្រង និងសេវាប្រហាក់ប្រហែល ។ល។ ដែលបានកើតឡើងនៅក្នុងការិយបរិច្ឆេទ។ |
| **B34-ចំណាយលើសួយសារ÷** | ត្រូវកត់ត្រាចំណាយលើសួយសារទាំងអស់ ដែលបានបង់ទៅឱ្យនិវាសនជន និងអនិវាសនជន។ |
| **B35-ចំណាយលើបំណុលទារមិនបាន÷** | ត្រូវកត់ត្រាបំណុលទារមិនបានពិតប្រាកដ ដែលបានលុបចេញពីបញ្ជីគណនេយ្យ។ ប្រអប់នេះ មិនត្រូវកត់ត្រាការកើនឡើងសំវិធានធនបំណុលទារមិនបានទេ។ |
| **B36-ចំណាយរំលស់÷** | ត្រូវកត់ត្រារំលស់ទ្រព្យសកម្មរយៈពេលវែង រួមបញ្ចូលទាំងរំលស់ទ្រព្យសកម្មអរូបីរយៈពេលវែង និងរំលស់លើទ្រព្យសកម្មធនធានធម្មជាតិ ប៉ុន្តែមិនត្រូវរួមបញ្ចូលរំលស់ដាក់ជាថ្លៃដើមផលិតផលនៅក្នុង TOI 01/V "**C9: រំលស់ទ្រព្យសកម្មអរូបីរយៈពេលវែង**" និង "**C12: រំលស់រោងចក្រគ្រឿងម៉ាស៊ីន និងបរិក្ខារផ្សេងៗក្នុងផលិតកម្ម**"។ |
| **B37-ការកើនឡើង/ថយចុះនូវសំវិធានធន÷** | ត្រូវកត់ត្រាចំនួនកើនឡើងនូវសំវិធានធន (បង្កើនចំណាយ) ឬការថយចុះនូវសំវិធានធន (បន្ថយចំណាយ)។<br><br>**កំណត់សម្គាល់÷** ការកើនឡើង ឬថយចុះសំវិធានធន គឺជាលម្អៀងរវាងតម្លៃនៃសំវិធានធនសមតុល្យដើមគ្រា និងសមតុល្យចុងគ្រាដែលបាន |

បង្ហាញនៅក្នុងតារាងតុល្យការ។ សញ្ញាវិជ្ជមាន គឺការកើនឡើងសំវិធានធន រីឯសញ្ញាអវិជ្ជមាន គឺការថយចុះសំវិធានធន។

**B38- ខាតពីការលក់ទ្រព្យសកម្មរយៈពេលវែង÷** គឺជាចំនួនទឹកប្រាក់ខាតពីការលក់ទ្រព្យសកម្មរយៈពេលវែង របស់សហគ្រាស ដែលជាលទ្ធផលបានមកពីការយកតម្លៃលក់ទ្រព្យសកម្មរយៈពេលវែង ដកតម្លៃនៅសល់មិនទាន់រំលស់ (តាមគណនេយ្យ)។ ក្នុងករណីនេះ តម្លៃលក់តូចជាងតម្លៃនៅសល់មិនទាន់រំលស់ (តាមគណនេយ្យ)។

**B39- ខាតពីការប្តូរប្រាក់សម្រេចបាន÷** គឺជាចំនួនទឹកប្រាក់ខាត ដែលកើតឡើងពីការប្តូររូបិយប័ណ្ណប្រតិបត្តិការ និងរូបិយវត្ថុកត់ត្រាក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់សហគ្រាស។

**B40- ខាតពីការប្តូរប្រាក់មិនទាន់សម្រេចបាន÷** គឺជាចំនួនទឹកប្រាក់ខាត ដែលកើតឡើងពីការប្តូររូបិយវត្ថុមិនទាន់សម្រេចបានចំពោះទ្រព្យសកម្មដែលគ្រប់គ្រងដោយសហគ្រាស ឬបំណុល ត្រូវទូទាត់ដោយសហគ្រាស។

**B41- ចំណាយផ្សេងៗ÷** រួមបញ្ចូលចំណាយផ្សេងៗដទៃទៀតទាំងអស់ នៅក្នុងរបាយការណ៍លទ្ធផលក្រៅពីចំណាយដែលបានបញ្ជាក់ខាងលើ។

**B42- ប្រាក់ចំណេញ/(ខាត)ពីប្រតិបត្តិការ÷** ប្រអប់នេះបញ្ជាក់អំពីលទ្ធផលគណនេយ្យ ដែលអ្នកជាប់ពន្ធសម្រេចបានចំណេញ ឬខាត ពីប្រតិបត្តិការអាជីវកម្មរបស់ខ្លួន នៅក្នុងការិយបរិច្ឆេទ។ តួលេខនេះត្រូវគណនាដោយយក **"B7: ចំណេញដុល"** បូក **"B8: ចំណូលបន្ទាប់បន្សំ"** បូក **"B12: ចំណូលផ្សេងៗ"** ដក **"B22: ចំណាយប្រតិបត្តិការ"**។

**B43- ចំណាយការប្រាក់បង់ឱ្យនិវាសនជន÷** ត្រូវកត់ត្រាចំណាយការប្រាក់ទាំងអស់ ដែលបានបង់ ឬត្រូវបង់ឱ្យនិវាសនជន។

**B44- ចំណាយការប្រាក់បង់ឱ្យអនិវាសនជន÷** ត្រូវកត់ត្រាចំណាយការប្រាក់ទាំងអស់ ដែលបានបង់ ឬត្រូវបង់ឱ្យអនិវាសនជន។

**B45- ចំណាយការប្រាក់សន្មត÷** ត្រូវកត់ត្រាចំណាយការប្រាក់មិនមានការទូទាត់ជាក់ស្តែង ដែលតម្រូវឱ្យកត់ត្រាតាមស្តង់ដារគណនេយ្យអន្តរជាតិនៃកម្ពុជា។

**ឧទាហរណ៍÷** ចំណាយការប្រាក់ដែលត្រូវកត់ត្រា តាមស្តង់ដារគណនេយ្យអន្តរជាតិនៃកម្ពុជាលើ ភតិសន្យា ...។

**B46- ប្រាក់ចំណេញ/(ខាត)មុនបង់ពន្ធ÷** ត្រូវគណនាដោយយកលទ្ធផលពី **"B42: ប្រាក់ចំណេញ/(ខាត)ពីប្រតិបត្តិការ"** ដក **"B43: ចំណាយការប្រាក់បង់ឱ្យនិវាសនជន"** ដក **"B44: ចំណាយការប្រាក់បង់ឱ្យអនិវាសនជន"** និងដក **"B45: ចំណាយការប្រាក់សន្មត"**។

**B47- ពន្ធលើប្រាក់ចំណូល÷** គឺជាចំណាយពន្ធលើប្រាក់ចំណូល តាមគោលការណ៍គណនេយ្យតែប៉ុណ្ណោះ។ ចំនួននេះអាចមិនស្មើចំនួននៅក្នុងប្រអប់ **"E59: ពន្ធលើប្រាក់ចំណូលត្រូវបង់ / ត្រូវយោងទៅឆ្នាំបន្ទាប់"** តាមច្បាប់និងបទប្បញ្ញត្តិស្តីពីពន្ធដារទេ។

**B48- ប្រាក់ចំណេញក្រោយបង់ពន្ធ÷** ប្រអប់នេះបង្ហាញលទ្ធផលចំណេញសុទ្ធក្រោយបង់ពន្ធ ដែលសហគ្រាសទទួលបានពីគ្រប់សកម្មភាពអាជីវកម្មក្នុងការិយបរិច្ឆេទ ហើយត្រូវបានគណនាដោយយក **"B46: ប្រាក់ចំណេញ/(ខាត)មុនបង់ពន្ធ"** ដកនឹង **"B47: ពន្ធលើប្រាក់ចំណូល"**។

## ទំព័រទី៧ (TOI 01/V)÷ ថ្លៃដើមផលិតផលបានលក់ (សហគ្រាសផលិតកម្ម)

តារាងនេះសម្រាប់គណនាថ្លៃដើមផលិតផលបានលក់ចំពោះសហគ្រាសផលិតកម្មតែប៉ុណ្ណោះ (មិនត្រូវប្រើប្រាស់ចំពោះសហគ្រាសពាណិជ្ជកម្ម និងសេវាកម្មទេ)។

| ខ្លឹមសារនៅក្នុងលិខិតប្រកាស | សេចក្តីពន្យល់ |
|---|---|
| **C1- ស្តុកវត្ថុធាតុដើម និងសម្ភារផ្គត់ផ្គង់ដើមគ្រា÷** | គឺជាតម្លៃវត្ថុធាតុដើម និងសម្ភារផ្គត់ផ្គង់សម្រាប់ប្រើប្រាស់ក្នុងផលិតកម្ម ដែលមាននៅក្នុងស្តុកនៅដើមការិយបរិច្ឆេទ ហើយចំនួននេះត្រូវស្មើនឹង **"A14: ស្តុកវត្ថុធាតុដើម និងសម្ភារផ្គត់ផ្គង់"** នៅដើមការិយបរិច្ឆេទដូចបានបង្ហាញក្នុងតារាងតុល្យការ (ក្ងឡោន N-1)។ |
| **C2- ចំណាយទិញវត្ថុធាតុដើម និងសម្ភារផ្គត់ផ្គង់ក្នុងគ្រា÷** | គឺជាចំណាយវត្ថុធាតុដើម និងសម្ភារផ្គត់ផ្គង់ដែលបានទិញនៅក្នុងការិយបរិច្ឆេទសម្រាប់ប្រើប្រាស់ក្នុងផលិតកម្ម។ |
| **C3- ចំណាយផ្សេងៗទាក់ទងដល់ការទិញវត្ថុធាតុដើម ឬសម្ភារផ្គត់ផ្គង់÷** | គឺជាចំណាយផ្សេងៗទៀត ដែលទាក់ទិនផ្ទាល់ទៅនឹងការទិញវត្ថុធាតុដើម និងសម្ភារផ្គត់ផ្គង់ផ្សេងៗដូចជា ថ្លៃដឹកជញ្ជូន ថ្លៃធានារ៉ាប់រង ថ្លៃលើកដាក់ កម្រៃជើងសា ពន្ធគយ ...។ |
| **C4- សរុបវត្ថុធាតុដើម និងសម្ភារផ្គត់ផ្គង់ដែលមានសម្រាប់ផលិត÷** | ត្រូវកត់ត្រាតម្លៃសរុបពីប្រអប់ **"C1: ស្តុកវត្ថុធាតុដើម និងសម្ភារផ្គត់ផ្គង់ដើមគ្រា"** ដល់ **"C3: ចំណាយផ្សេងៗទាក់ទងដល់ការទិញវត្ថុធាតុដើម ឬសម្ភារផ្គត់ផ្គង់"**។ |
| **C5- ស្តុកវត្ថុធាតុដើម និងសម្ភារផ្គត់ផ្គង់ចុងគ្រា÷** | គឺជាតម្លៃវត្ថុធាតុដើម និងសម្ភារផ្គត់ផ្គង់សម្រាប់ប្រើប្រាស់ក្នុងផលិតកម្ម ដែលនៅសល់ក្នុងស្តុកនៅចុងការិយបរិច្ឆេទ ហើយចំនួននេះត្រូវស្មើនឹង **"A14: ស្តុកវត្ថុធាតុដើម និងសម្ភារផ្គត់ផ្គង់"** នៅចុងការិយបរិច្ឆេទដូចបានបង្ហាញក្នុងតារាងតុល្យការ (ក្ងឡោន N)។ |
| **C6- ចំណាយថ្លៃវត្ថុធាតុដើម និងសម្ភារផ្គត់ផ្គង់ដែលបានប្រើប្រាស់÷** | គឺជាចំណាយថ្លៃវត្ថុធាតុដើម និងសម្ភារផ្គត់ផ្គង់ផ្សេងៗដែលបានប្រើប្រាស់សម្រាប់ផលិតកម្មក្នុងការិយបរិច្ឆេទ។ តួលេខនៅក្នុងប្រអប់នេះត្រូវគណនាដោយយក **"C4: សរុបវត្ថុធាតុដើម និងសម្ភារផ្គត់ផ្គង់ដែលមានសម្រាប់ផលិត"** ដកនឹង **"C5: ស្តុកវត្ថុធាតុដើម និងសម្ភារផ្គត់ផ្គង់ចុងគ្រា"**។ |
| **C7- ចំណាយផ្សេងៗក្នុងផលិតកម្ម÷** | គឺជាចំណាយសរុបពី **"C8: ប្រាក់បៀវត្សអ្នកគ្រប់គ្រង និងកម្មករសម្រាប់ការផលិត"** ដល់ **"C14: ចំណាយផ្សេងៗក្នុងផលិតកម្ម"**។ ចំណាយទាំងនេះ មិនរួមបញ្ចូលចំណាយប្រតិបត្តិការទេ។ |
| **C8- ប្រាក់បៀវត្សអ្នកគ្រប់គ្រង និងកម្មករសម្រាប់ផលិត÷** | គឺជាចំណាយបៀវត្សសរុបដែលបានទូទាត់ និងត្រូវទូទាត់ឱ្យដល់អ្នកគ្រប់គ្រង និងបុគ្គលិក-កម្មករ ដែលបម្រើការងារផ្ទាល់ផ្នែកផលិតកម្មឱ្យសហគ្រាសរួមទាំងចំណាយលើអត្ថប្រយោជន៍បន្ថែម។ |

| | |
|---|---|
| **C9-រំលស់ទ្រព្យសកម្មអរូបីរយៈពេលវែង ជាអាទិ៍មាន÷ មូលនិធិពាណិជ្ជកម្ម លិខិតអនុញ្ញាត ...÷** | គឺជារំលស់ក្នុងការិយបរិច្ឆេទនៃទ្រព្យសកម្មអរូបីរយៈពេលវែង ដែលបានប្រើប្រាស់សម្រាប់ការផលិតរួមមាន រូបមន្តសម្រាប់ការផលិត មូលនិធិពាណិជ្ជកម្ម ពាណិជ្ជសញ្ញា អាជ្ញាប័ណ្ណ (លិខិតអនុញ្ញាត)...។ |
| **C10-ប្រេងឥន្ធនៈ ទឹក និងថាមពល÷** | ត្រូវកត់ត្រាចំណាយថ្លៃប្រេងឥន្ធនៈ ទឹក និងថាមពលផ្សេងៗដែលបានប្រើប្រាស់សម្រាប់ផលិតកម្ម និងក្នុងទីកន្លែងផលិតកម្ម។ |
| **C11-ការវេចខ្ចប់÷** | ត្រូវកត់ត្រាចំណាយវេចខ្ចប់ទាំងអស់ ដែលបានកើតឡើងសម្រាប់ខ្សែចង្វាក់ផលិតកម្ម។ |
| **C12-រំលស់រោងចក្រ គ្រឿងម៉ាស៊ីន និងបរិក្ខារផ្សេងៗក្នុងផលិតកម្ម÷** | ត្រូវកត់ត្រាតែរំលស់ រោងចក្រ គ្រឿងម៉ាស៊ីន និងបរិក្ខារប្រើប្រាស់ក្នុងផលិតកម្មតែប៉ុណ្ណោះ។ |
| **C13-សេវាម៉ៅការបន្ត និងសេវាផលិតដោយសហគ្រាសដទៃ÷** | គឺជាចំណាយដែលបានបង់ឱ្យបុគ្គល និងសហគ្រាសដទៃសម្រាប់ធ្វើសេវាម៉ៅការបន្ត ឬការផ្គត់ផ្គង់សេវាផ្សេងៗទៀត សម្រាប់បំពេញបន្ថែមដល់ផលិតផលរបស់សហគ្រាស។ |
| **C14-ចំណាយផ្សេងៗក្នុងផលិតកម្ម÷** | គឺជាចំណាយផ្សេងៗដទៃទៀតក្រៅពី "**C8: ចំណាយប្រាក់បៀវត្សអ្នកគ្រប់គ្រង និងកម្មករសម្រាប់ការផលិត**" ដល់ "**C13: សេវាម៉ៅការបន្ត និងសេវាផលិតដោយសហគ្រាសដទៃ**"។ ចំណាយផលិតកម្មទាំងនេះដូចជា ថៃទាំ និងជួសជុលម៉ាស៊ីន ធានារ៉ាប់រង ជួលម៉ាស៊ីន ជួលរោងចក្រ សេវាត្រួតពិនិត្យគុណភាព ...។ |
| **C15-ការងារកំពុងដំណើរការ ឬស្តុកកំពុងផលិតនៅដើមគ្រា÷** | គឺជាតម្លៃការងារកំពុងដំណើរការ ឬស្តុកផលិតផលមិនទាន់សម្រេចនៅដើមគ្រា ហើយចំនួននេះត្រូវស្មើនឹង "**A17: ផលិតផលកំពុងផលិត**" នៅដើមការិយបរិច្ឆេទ ដូចបានបង្ហាញក្នុងតារាងតុល្យការ (ក្ងឡោន N-1)។ |
| **C16-ការងារកំពុងដំណើរការ ឬស្តុកកំពុងផលិតនៅចុងគ្រា÷** | គឺជាតម្លៃការងារកំពុងដំណើរការ ឬស្តុកផលិតផលមិនទាន់សម្រេចនៅចុងគ្រា ហើយចំនួននេះត្រូវស្មើនឹង "**A17: ផលិតផលកំពុងផលិត**" នៅចុងការិយបរិច្ឆេទ ដូចបានបង្ហាញក្នុងតារាងតុល្យការ (ក្ងឡោន N)។ |
| **C17-សរុបចំណាយថ្លៃដើមផលិតកម្ម÷** | គឺជាសរុបចំណាយថ្លៃដើមផលិតកម្មទាំងអស់នៅក្នុងការិយបរិច្ឆេទនេះ។ តួលេខក្នុងប្រអប់នេះស្មើនឹង "**C6: ចំណាយថ្លៃដើមវត្ថុធាតុដើម និងសម្ភារផ្គត់ផ្គង់ដែលបានប្រើប្រាស់**" បូក "**C7: ចំណាយផ្សេងៗក្នុងផលិតកម្ម**" បូក "**C15: ការងារកំពុងដំណើរការ ឬស្តុកកំពុងផលិតនៅដើមគ្រា**" ដក "**C16: ការងារកំពុងដំណើរការ ឬស្តុកកំពុងផលិតនៅចុងគ្រា**")។ |
| **C18-ស្តុកផលិតផលសម្រេចនៅដើមគ្រា÷** | គឺជាតម្លៃស្តុកផលិតផលសម្រេចរបស់សហគ្រាសនៅសល់នៅដើមគ្រា ហើយចំនួននេះត្រូវស្មើនឹង "**A16: ស្តុកផលិតផលសម្រេច**" នៅដើមការិយបរិច្ឆេទ ដូចបានបង្ហាញក្នុងតារាងតុល្យការ (ក្ងឡោន N-1)។ |

**C19- ស្តុកផលិតផលសម្រេចនៅចុងគ្រា÷** គឺជាតម្លៃស្តុកផលិតផលសម្រេចរបស់សហគ្រាសនៅសល់នៅចុងគ្រា ហើយចំនួននេះត្រូវស្មើនឹង **"A16: ស្តុកផលិតផលសម្រេច"** នៅចុងការិយបរិច្ឆេទ ដូចបានបង្ហាញក្នុងតារាងតុល្យការ (កូឡោន N)។

**C20- ថ្លៃដើមផលិតផលសម្រេចដែលបានលក់÷** គឺជាថ្លៃដើមផលិតផលបានលក់ឱ្យទៅអតិថិជនក្នុងការិយបរិច្ឆេទ។ តួលេខក្នុងប្រអប់នេះស្មើនឹង **"C17: សរុបចំណាយថ្លៃដើមផលិតកម្ម"** បូក **"C18: ស្តុកផលិតផលសម្រេចនៅដើមគ្រា"** ដក **"C19: ស្តុកផលិតផលសម្រេចនៅចុងគ្រា"**។

## ទំព័រទី៨ (TOI 01/VI)÷ ថ្លៃដើមទំនិញបានលក់ (សហគ្រាសក្រៅពីផលិតកម្ម)

តារាងនេះសម្រាប់គណនាថ្លៃដើមទំនិញបានលក់ចំពោះសហគ្រាសពាណិជ្ជកម្មតែប៉ុណ្ណោះ (មិនត្រូវប្រើប្រាស់ចំពោះសហគ្រាសផលិតកម្មទេ)។

| <u>**ខ្ទឹមសារនៅក្នុងលិខិតប្រកាស**</u> | <u>**សេចក្តីពន្យល់**</u> |
|---|---|
| **D1- ស្តុកទំនិញដើមគ្រា÷** | គឺជាតម្លៃទំនិញមានក្នុងស្តុកដើមការិយបរិច្ឆេទ "ស្តុកដើមគ្រា" ហើយចំនួននេះត្រូវស្មើនឹង **"A15: ស្តុកទំនិញ"** នៅដើមការិយបរិច្ឆេទដូចបានបង្ហាញក្នុងតារាងតុល្យការ (ក្ខឡោន N-1)។ |
| **D2- ចំណាយទិញទំនិញក្នុងគ្រា÷** | គឺជាតម្លៃទំនិញទាំងអស់ដែលបានទិញ សម្រាប់លក់ចេញទៅវិញនៅក្នុងការិយបរិច្ឆេទ។ |
| **D3- ចំណាយផ្សេងៗទាក់ទងដល់ការទិញទំនិញ÷** | ត្រូវបូកសរុបចាប់ពីប្រអប់ **"D4: ចំណាយដឹកជញ្ជូនចូល"** ដល់ **"D6: ចំណាយដទៃទៀតក្រៅពី D4 និង D5"**។ |
| **D4- ចំណាយដឹកជញ្ជូនចូល÷** | គឺជាថ្លៃដឹកជញ្ជូន សម្រាប់ការទិញទំនិញពីអ្នកផ្គត់ផ្គង់ទៅដល់ឃ្លាំងសហគ្រាស។ ប្រអប់នេះ មិនត្រូវបូកបញ្ចូលថ្លៃដឹកជញ្ជូនចេញ និងថ្លៃដឹកជញ្ជូនចូល ដែលកើតឡើងពីការទិញសម្ភារផ្គត់ផ្គង់សម្រាប់ប្រើប្រាស់គោលដៅរដ្ឋបាល។ |
| **D5- ចំណាយបង់ពន្ធគយនាំចូល និងពន្ធដទៃដែលជាបន្ទុករបស់សហគ្រាស÷** | គឺជាចំណាយពន្ធគយ និងពន្ធអាករដទៃទៀត ដែលជាបន្ទុករបស់សហគ្រាស និងបានបង់ជូនអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងអគ្គនាយកដ្ឋានពន្ធដារ ចំពោះទំនិញដែលបានទិញសម្រាប់លក់ចេញវិញ។ ប្រអប់នេះ មិនបូកបញ្ចូលចំណាយពន្ធ និងអាករផ្សេងៗ ដែលបានកត់ត្រានៅក្នុង TOI 01/IV ប្រអប់ **"B31: ចំណាយបង់ពន្ធ និងអាករផ្សេងៗ"**។ |
| **D6- ចំណាយដទៃទៀតក្រៅពី D4 និង D5÷** | គឺជាចំណាយផ្សេងៗទៀតក្រៅពី D4 និង D5 ដែលពាក់ព័ន្ធផ្ទាល់នឹងថ្លៃដើមទំនិញដែលបានទិញ។<br>**ឧទាហរណ៍÷** កម្រៃសេវាជើងសា ធានារ៉ាប់រង ការលើកឬដាក់ទំនិញ ជាដើម។ |
| **D7- សរុបចំណាយថ្លៃដើមទំនិញ÷** | ត្រូវគណនាដោយយក **"D1: ស្តុកទំនិញដើមគ្រា"** បូក **"D2: ចំណាយទិញទំនិញក្នុងគ្រា"** បូក **"D3: ចំណាយផ្សេងៗទាក់ទងដល់ការទិញទំនិញ"**។ |
| **D8- ស្តុកទំនិញនៅចុងគ្រា÷** | គឺជាតម្លៃទំនិញមានក្នុងស្តុកចុងការិយបរិច្ឆេទ ហើយចំនួននេះត្រូវស្មើនឹង **"A15: ស្តុកទំនិញ"** នៅចុងការិយបរិច្ឆេទដូចបានបង្ហាញក្នុងតារាងតុល្យការ (ក្ខឡោន N)។ |
| **D9- ថ្លៃដើមទំនិញដែលបានលក់÷** | គឺជាថ្លៃដើមទំនិញបានលក់ឱ្យទៅអតិថិជនក្នុងការិយបរិច្ឆេទ។ តួលេខក្នុងប្រអប់នេះស្មើនឹង **"D7- សរុបចំណាយថ្លៃដើមទំនិញ"** ដកនឹង **"D8- ស្តុកទំនិញនៅចុងគ្រា"**។ |

## ទំព័រទី៩ និងទី១០ (TOI 01/VII)÷ តារាងគណនាពន្ធលើប្រាក់ចំណូល

| ខ្លឹមសារនៅក្នុងលិខិតប្រកាស | សេចក្ដីពន្យល់ |
|---|---|
| **E1-ប្រាក់ចំណេញ/(ខាត) មុនបង់ពន្ធ/លទ្ធផលគណនេយ្យ ចំណេញ/(ខាត)÷** | ត្រូវកត់ត្រាដោយយកតួលេខពី TOI 01/IV ប្រអប់ **"B46: ប្រាក់ចំណេញ/(ខាត) មុនបង់ពន្ធ"**។ |
| **ចំណាយមិនអាចកាត់កងបាន÷** | គឺជាចំណាងជើងចំណាយមិនអាចកាត់កងបាន។ ចំណាយទាំងនេះជាចំណាយមិនអនុញ្ញាតឱ្យកាត់កងសម្រាប់គោលដៅពន្ធលើប្រាក់ចំណូល។ |
| **E2-ចំណាយរំលស់គណនេយ្យ÷** | គឺជាផលបូករំលស់គណនេយ្យយកចេញពី TOI 01/IV ត្រង់ប្រអប់ **"B36: ចំណាយរំលស់"** និង TOI 01/V ប្រអប់ **"C9: រំលស់ទ្រព្យសកម្មអរូបីរយៈពេលវែង"** និង **"C12: រំលស់រោងចក្រ គ្រឿងម៉ាស៊ីន និងបរិក្ខារផ្សេងៗក្នុងផលិតកម្ម"**។ |
| **E3-ចំណាយលើការកម្សាន្តសប្បាយ ការលំហែកម្សាន្ត និងការទទួលភ្ញៀវ÷** | ត្រូវកត់ត្រាសរុបចំណាយលើការកំសាន្តសប្បាយ ការលំហែកម្សាន្ត និងការទទួលភ្ញៀវដែលបង្ហាញក្នុង TOI 01/IV ប្រអប់ **"B29: ចំណាយលើការកម្សាន្តសប្បាយ"**។ |
| **E4-ការកើនឡើងនូវសំវិធានធន÷** | ត្រូវកត់ត្រាចំនួនកើនឡើងនូវសំវិធានធនពី TOI 01/IV ប្រអប់ **"B37: ការកើនឡើង/ថយចុះនូវសំវិធានធន"**។ |
| **E5-អំណោយ និងឧបត្ថម្ភកធនផ្សេងៗ÷** | ត្រូវបូកសរុបចំនួនទឹកប្រាក់អំណោយ និងឧបត្ថម្ភកធនផ្សេងៗទាំងអស់ដែលបង្ហាញក្នុង TOI 01/IV ប្រអប់ **"B32: ចំណាយលើអំណោយ"** វៀរលែងតែវិភាគទានសប្បុរសធម៌។ |
| **E6-ខាតពីការលក់ទ្រព្យសកម្មរយៈពេលវែង (ខាតតាមបញ្ជីគណនេយ្យ)÷** | ត្រូវកត់ត្រាតួលេខយកពី TOI 01/IV ប្រអប់ **"B38: ខាតពីការលក់ទ្រព្យសកម្មរយៈពេលវែង"**។ |
| **E7-ចំណាយមានលក្ខណៈស្ដុកស្ដម្ភហួសហេតុមិនអនុញ្ញាត÷** | គឺជាចំណាយទាំងឡាយដែលមានលក្ខណៈលេចធ្លោ ឬស្ដុកស្ដម្ភហួសហេតុដែលគ្មានប្រយោជន៍ ឬមានប្រយោជន៍តិចតួចពេកដល់អាជីវកម្មលើសពីតម្រូវការ ឬខ្ជះខ្ជាយហួសពីភាពសមហេតុផល ថ្លៃ ឬតម្លៃខ្ពស់មិនសមហេតុផល ឬលេចធ្លោហួសពេក។ |
| **E8-ចំណាយមិនបម្រើឱ្យសកម្មភាពអាជីវកម្ម÷** | ចំណាយទាំងនេះកើតឡើងក្នុងការិយបរិច្ឆេទ ប៉ុន្តែជាចំណាយមិនបម្រើឱ្យសកម្មភាពអាជីវកម្មមានជាអាទិ៍ ចំណាយលំនៅឋាន ពន្ធផ្ទាល់ខ្លួន ចំណាយលើយានជំនិះប្រើប្រាស់ជាឯកជន...។ |
| **E9-ខាតលើប្រតិបត្តិការជាមួយបុគ្គលជាប់ទាក់ទិន÷** | កត់ត្រាការខាតទាំងឡាយ ដែលកើតឡើងពីប្រតិបត្តិការជាមួយបុគ្គលជាប់ទាក់ទិនមានជាអាទិ៍ ខាតពីការលក់ទំនិញ ឬដោះដូរនូវទ្រព្យសកម្មរយៈពេលវែងជាមួយបុគ្គលជាប់ទាក់ទិន។ បុគ្គលជាប់ទាក់ទិនសំដៅដល់÷<br>ក- សមាជិកណាម្នាក់ក្នុងវង្សញាតិអ្នកជាប់ពន្ធ |

ខ-សហគ្រាសដែលគ្រប់គ្រងលើអ្នកជាប់ពន្ធ ឬសហគ្រាសត្រូវបានអ្នកជាប់ពន្ធគ្រប់គ្រង ឬក៏សហគ្រាសនោះនិងអ្នកជាប់ពន្ធស្ថិតនៅក្រោមការគ្រប់គ្រងរួមគ្នា។ ពាក្យ "គ្រប់គ្រង" មានន័យថាមានកម្មសិទ្ធិចាប់ពី ២០ ភាគរយឡើងទៅលើតម្លៃនៃភាគកម្មនៅក្នុងដើមទុនផ្ទាល់របស់សហគ្រាស ឬសិទ្ធិបោះឆ្នោតក្នុងក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុន។ ដើម្បីកំណត់ទំហំនៃការគ្រប់គ្រងរបស់អ្នកជាប់ពន្ធ ជារូបវន្តបុគ្គលណាម្នាក់ត្រូវគិតបញ្ចូលទាំងអស់នូវកម្មសិទ្ធិលើភាគកម្ម នៅក្នុងដើមទុនផ្ទាល់របស់រូបវន្តបុគ្គលនោះ និងកម្មសិទ្ធិផ្ទាល់ ឬប្រយោលរបស់សហព័ទ្ធអ្នកជាប់ពន្ធ។

**(ប្រកាសលេខ ៩៨៦ សហវ.ប្រក ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៧)**

**E10-ចំណាយលើការផាកពិន័យ និងទោសទណ្ឌផ្សេងៗ÷**

ត្រូវកត់ត្រាសរុបប្រាក់ពន្ធបន្ថែម ការប្រាក់យឺតយ៉ាវ ប្រាក់ពិន័យផ្សេងៗ និងទោសទណ្ឌគ្រប់ប្រភេទ ដែលសហគ្រាសបានទទួលរងដោយសារការល្មើសនឹងបទប្បញ្ញត្តិច្បាប់ផ្សេងៗ ដែលមានជាធរមាននៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**E11-ចំណាយនៃការិយបរិច្ឆេទមុន÷**

គឺជាចំណាយទាំងឡាយដែលបានកើតឡើងនៅការិយបរិច្ឆេទមុន ប៉ុន្តែត្រូវបានយកមកកត់ត្រាជាចំណាយនៅក្នុងការិយបរិច្ឆេទនេះ។

**E12-ចំណាយពន្ធអាករដែលមិនអាចកាត់កងបាន÷**

រួមមានចំណាយលើពន្ធលើប្រាក់ចំណូល ប្រាក់រំដោះពន្ធលើប្រាក់ចំណូល ពន្ធអប្បបរមា និងពន្ធអាករដទៃទៀត ដែលមិនមែនជាបន្ទុករបស់សហគ្រាស ប៉ុន្តែគឺជាបន្ទុករបស់អ្នកទទួលចំណូលដែលត្រូវជាប់ពន្ធ។ ដោយឡែក សម្រាប់ពន្ធកាត់ទុកដែលអ្នកទូទាត់ប្រាក់ត្រូវកាត់ទុកប្រាក់ពន្ធមុនពេលទូទាត់ ប៉ុន្តែមិនបានកាត់ទុកប្រាក់ពន្ធ ហើយដែលត្រូវបានរដ្ឋបាលសារពើពន្ធរំលឹកឱ្យបង់ពន្ធដែលត្រូវកាត់ទុកនេះ ពន្ធដែលរំលឹកឱ្យបង់ពីការខកខាននេះមិនអនុញ្ញាតឱ្យកាត់កងសម្រាប់គណនាប្រាក់ចំណូលជាប់ពន្ធទេ។

**E13-លាភការរបស់អាជីវករ និងគ្រួសារ÷**

ត្រូវកត់ត្រានូវលាភការទាំងអស់រួមបញ្ចូលទាំងប្រាក់បៀវត្ស លាភការផ្សេងៗ... ដែលបានបង់ឱ្យម្ចាស់សហគ្រាសឯកបុគ្គល ឬសមាជិក សហគ្រាសសហកម្មសិទ្ធិ។

**E14-ផលប្រយោជន៍របស់អាជីវករ និងគ្រួសារ÷**

ត្រូវកត់ត្រានូវផលប្រយោជន៍ សរុបទាំងអស់ដែលបានផ្តល់ឱ្យម្ចាស់សហគ្រាស និងគ្រួសារ។

**ឧទាហរណ៍÷** ចំណាយលើការប្រើប្រាស់ទឹកភ្លើង យានយន្ត ធានារ៉ាប់រង សម្រាប់ផលប្រយោជន៍ផ្ទាល់ខ្លួនរបស់ម្ចាស់សហគ្រាស និងគ្រួសារ ...។

**E15-ចំណាយបៀវត្សពីការបម្រើការងារដែលមិនទាន់បានបើកក្នុងរយៈពេល ១៨០ ថ្ងៃនៃឆ្នាំបន្ទាប់÷**

ត្រូវកត់ត្រាប្រាក់បៀវត្សសរុបដែលបានកត់ត្រា (កត់ត្រាជាចំណាយបង្គរ) ក្នុងឆ្នាំជាប់ពន្ធចរន្ត ប៉ុន្តែមិនទាន់បានបើកក្នុងរយៈពេល ១៨០ថ្ងៃ នៃឆ្នាំជាប់ពន្ធបន្ទាប់។

**ឧទាហរណ៍÷** ឆ្នាំជាប់ពន្ធចរន្តគឺចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០២០ ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០។ សហគ្រាសមួយបានកត់ត្រាគ្រោង

ចំណាយបង្គរលើប្រាក់បៀវត្ស ជាប្រាក់បៀវត្សត្រូវសងចំនួន ២០ ០០០ ០០០ រៀល នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០។

នៅថ្ងៃទី០៥ ខែសីហា ឆ្នាំ២០២១ ប្រាក់បៀវត្សត្រូវបើកឱ្យនិយោជិត ដូច្នេះការបើកប្រាក់នេះហួសរយៈពេល ១៨០ថ្ងៃ។

**E16-ចំណាយដល់បុគ្គលទាក់ទិនដែលមិនទាន់បានបើកក្នុងរយៈពេល ១៨០ ថ្ងៃ នៃឆ្នាំបន្ទាប់÷**

ត្រូវកត់ត្រាចំណាយបុគ្គលទាក់ទិនសរុបដែលបានកត់ត្រា (កត់ត្រាជាចំណាយបង្គរ) ក្នុងឆ្នាំជាប់ពន្ធចរន្ត លើកលែងចំណាយដែលអាចកាត់កងបាននៃសារពើភណ្ឌ ទ្រព្យជាមូលធន និងទ្រព្យដែលអាចរំលស់បាន ប៉ុន្តែមិនទាន់បានបើកក្រោយ ១៨០ថ្ងៃ នៃឆ្នាំជាប់ពន្ធបន្ទាប់។

**ឧទាហរណ៍÷** ឆ្នាំជាប់ពន្ធចរន្តគឺចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០២០ ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០។ សហគ្រាសមួយបានកត់ត្រាគ្រោងចំណាយបង្គរសេវាបច្ចេកទេសទៅបុគ្គលទាក់ទិនត្រូវសងចំនួន ៨០ ០០០ ០០០ រៀល នៅថ្ងៃ៣១ ខែធ្នូ ឆ្នាំ២០២០។

នៅថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០២១ ប្រាក់សេវាបច្ចេកទេសត្រូវបើកឱ្យបុគ្គលទាក់ទិន ដូច្នេះការបើកប្រាក់នេះហួសរយៈពេល ១៨០ថ្ងៃ។

**E17-ចំណាយផ្សេងៗមិនអនុញ្ញាតឱ្យកាត់កងបាន÷**

ត្រូវកត់ត្រាចំណាយផ្សេងៗដទៃទៀតដែលមិនអនុញ្ញាតឱ្យកាត់កងបាន។

**E18-សរុប÷**

ត្រូវកត់ត្រាទឹកប្រាក់សរុបពីប្រអប់ **"E2: ចំណាយរំលស់គណនេយ្យ"** ដល់ **"E17: ចំណាយផ្សេងៗមិនអនុញ្ញាតឱ្យកាត់កងបាន"**។

**ចំណូលជាប់ពន្ធតែមិនត្រូវបានកត់ត្រាក្នុងបញ្ជីគណនេយ្យ÷**

**E19-ការផ្គត់ផ្គង់ទំនិញ និងសេវាដោយឥតគិតថ្លៃ÷**

ចំណូលនេះ កើតមានឡើងតែក្នុងករណីសហគ្រាសធ្វើការផ្គត់ផ្គង់ទំនិញ និងសេវាដោយឥតគិតថ្លៃ។ ក្នុងករណីនេះ អ្នកជាប់ពន្ធមានកាតព្វកិច្ចត្រូវគណនាដោយខ្លួនឯងនូវតម្លៃនៃការផ្គត់ផ្គង់ទាំងនោះ ដោយយកបរិមាណ ទំនិញ ឬសេវាដែលបានផ្គត់ផ្គង់ជាក់ស្តែងទៅគុណ នឹងថ្លៃលក់ទីផ្សារ (តម្លៃទីផ្សារដូចថ្លៃលក់ឱ្យអតិថិជនទូទៅ)។

**E20-ការដាក់ទ្រព្យសកម្មរយៈពេលវែងឱ្យប្រើប្រាស់ដោយឥតគិតថ្លៃ÷**

ត្រូវកត់ត្រានូវថ្លៃជួលតាមតម្លៃទីផ្សារ ចំពោះទ្រព្យសកម្មរយៈពេលវែងដែលបានផ្តល់ឱ្យតតិយជន "ភាគីជាប់ទាក់ទិន ឬភាគីមិនជាប់ទាក់ទិន" ឬនិយោជិតប្រើប្រាស់ជាលក្ខណៈឯកជនដោយឥតគិតថ្លៃ (ការផ្តល់ទ្រព្យសកម្មរយៈពេលវែងឱ្យប្រើប្រាស់ដោយឥតគិតថ្លៃត្រូវចាត់ទុកថាបានចំណូលពីការជួលនូវទ្រព្យទាំងនោះតាមតម្លៃទីផ្សារ)។

**E21-ការកែលម្អទ្រព្យសកម្មរយៈពេលវែងដោយអ្នកជួលមិនគិតថ្លៃពីម្ចាស់÷** ត្រូវកត់ត្រាតម្លៃនៅសល់នៅក្នុងការិយបរិច្ឆេទដែលឈប់ជួល (ប្រគល់ទ្រព្យមកវិញ) ចំពោះថ្លៃកែលម្អទ្រព្យសកម្មរយៈពេលវែង ដែលធ្វើឡើងដោយអ្នកជួល ឬតតិយជនដទៃទៀត ហើយមិនបានគិតថ្លៃពីម្ចាស់ទ្រព្យ។

**E22-អំណោយ និងឧបត្ថម្ភកធនផ្សេងៗ មិនទទួលស្គាល់ក្នុងបញ្ជីគណនេយ្យ÷** ត្រូវកត់ត្រានូវអំណោយ និងឧបត្ថម្ភកធនផ្សេងៗទាំងអស់ដែលបានទទួលពីបុគ្គលដទៃ ហើយមិនបានកត់ត្រាជាចំណូលក្នុងបញ្ជិកាគណនេយ្យ។

**E23-ផលចំណេញ/តម្លៃលើសពីការលក់ទ្រព្យសកម្មរយៈពេលវែងតាមច្បាប់ស្ដីពីសារពើពន្ធ (TOI 01/XI)÷** ត្រូវកត់ត្រានូវផលចំណូលទាំងអស់យកពីប្រអប់ **"សរុបរួម"** ដែលបានគណនានៅក្នុង TOI 01/XI: តារាងតម្លៃលើស ឬខ្វះពីការដកចេញ ឬលក់នូវទ្រព្យសកម្មរយៈពេលវែងតាមច្បាប់ស្ដីពីសារពើពន្ធ ក្នុងករណីតម្លៃសរុបជាតម្លៃលើស (វិជ្ជមាន)។

**E24-ចំណូលផ្សេងៗទៀតដែលមិនបានកត់ត្រាក្នុងបញ្ជីគណនេយ្យ÷** ត្រូវកត់ត្រាចំណូលជាប់ពន្ធផ្សេងៗទៀត ដែលមិនបានកត់ត្រានៅក្នុងបញ្ជីគណនេយ្យ ដូចជា ចំណូលកត់មុន (Unearned Revenues) សាច់ប្រាក់ទទួលបានមុនពេលប្រគល់ទំនិញឬសេវា និយតកម្មចំណូលបន្ថែមផ្អែកតាមគោលការណ៍ជំហោងដៃ ...។

**E25-សរុប÷** ត្រូវដាក់បញ្ចូលនូវទឹកប្រាក់សរុបពីប្រអប់ **"E19: ការផ្គត់ផ្គង់ទំនិញនិងសេវាដោយឥតគិតថ្លៃ"** ដល់ប្រអប់ **"E24: ចំណូលផ្សេងៗទៀតដែលមិនបានកត់ត្រាក្នុងបញ្ជីគណនេយ្យ"**។

**ចំណាយមិនកត់ត្រាក្នុងបញ្ជីគណនេយ្យតែជាចំណាយកាត់កងបានក្នុងឆ្នាំ÷**

**E26-រំលស់អនុញ្ញាតតាមច្បាប់ស្ដីពីសារពើពន្ធ÷** ត្រូវកត់ត្រារំលស់តាមច្បាប់ស្ដីពីសារពើពន្ធ ដោយយកទឹកប្រាក់សរុបពីតារាងគណនា TOI 01/IX **"សរុបរួម រំលស់នៅក្នុងការិយបរិច្ឆេទ"** ដែលបានអនុញ្ញាតចំពោះទ្រព្យសកម្មរយៈពេលវែងរួមមាន រំលស់ទ្រព្យអរូបី រំលស់កសិកម្មនិងធនធានធម្មជាតិ និងរំលស់ទ្រព្យរូបីថ្នាក់១ ដល់ថ្នាក់៤។

**E27-រំលស់ពិសេសអនុញ្ញាតតាមច្បាប់ស្ដីពីសារពើពន្ធ÷** ត្រូវកត់ត្រារំលស់ពិសេសតាមច្បាប់ស្ដីពីសារពើពន្ធ ដោយយកទឹកប្រាក់សរុបពីតារាងគណនា TOI 01/X **"សរុបរួម រំលស់ពិសេសក្នុងការិយបរិច្ឆេទ"**។

**E28-ការថយចុះនូវសំវិធានធន÷** ត្រូវកត់ត្រាចំនួនថយចុះនូវសំវិធានធនពី TOI 01/IV ប្រអប់ **"B37: ការកើនឡើង/ថយចុះនូវសំវិធានធន"**។

**E29-ខាតពីការលក់ទ្រព្យសកម្មរយៈពេលវែងតាមច្បាប់ស្ដីពីសារពើពន្ធ÷** ត្រូវកត់ត្រានូវទឹកប្រាក់សរុបតម្លៃខ្វះដែលបានពីការគណនានៅក្នុង TOI 01/XI: តារាងតម្លៃលើស ឬខ្វះពីការដកចេញ ឬលក់នូវទ្រព្យសកម្មរយៈពេលវែងតាមច្បាប់ស្ដីពីសារពើពន្ធ ក្នុងករណីតម្លៃសរុបជាតម្លៃខ្វះ (អវិជ្ជមាន)។

**E30-ចំណាយផ្សេងៗទៀតអនុញ្ញាតឱ្យកាត់កងបាន÷** ត្រូវកត់ត្រាបញ្ចូលនូវចំណាយផ្សេងៗ ដែលត្រូវបានអនុញ្ញាតឱ្យកាត់កងតាមច្បាប់ស្ដីពីសារពើពន្ធដែលមិនបានកត់ត្រាក្នុងបញ្ជីគណនេយ្យ។

**ឧទាហរណ៍÷** ចំណាយលើអចលនទ្រព្យ ដែលដាក់ឱ្យនិយោជិតប្រើប្រាស់លក្ខណៈឯកជនដោយឥតគិតថ្លៃ, សំវិធានធនរបស់ធនាគារក្នុងស្រុក ដែលអាចកាត់កងបានតាមច្បាប់ស្តីពីសារពើពន្ធ ...។

**E31- សរុប÷** ត្រូវកត់ត្រាទឹកប្រាក់សរុបពីប្រអប់ **“E26: វិលស់អនុញ្ញាតតាមច្បាប់ស្តីពីសារពើពន្ធ”** ដល់ប្រអប់ **“E30: ចំណាយផ្សេងៗទៀតអនុញ្ញាតឱ្យកាត់កងបាន”**។

**ចំណូលបានកត់ត្រាក្នុងបញ្ជីគណនេយ្យតែជាចំណូលមិនត្រូវជាប់ពន្ធក្នុងឆ្នាំ÷**

**E32- ចំណូលលើភាគលាភទទួលបានពីអ្នកជាប់ពន្ធនិវាសនជន÷** ត្រូវកត់ត្រាចំណូលភាគលាភដែលបានបង់ពន្ធលើប្រាក់ចំណូល និងពន្ធទាក់ទងនឹងការបែងចែកភាគលាភរួច ដោយអ្នកជាប់ពន្ធនិវាសនជន។

**E33- ចំណេញពីការលក់ទ្រព្យសកម្មរយៈពេលវែងតាមបញ្ជីគណនេយ្យ÷** ត្រូវកត់ត្រាទឹកប្រាក់ចំណេញយកពី TOI 01/IV ប្រអប់ **“B16: ផលចំណេញ/តម្លៃលើសពីការលក់ទ្រព្យសកម្មរយៈពេលវែង”**។

**E34- ចំណូលផ្សេងៗបានកត់ត្រាក្នុងបញ្ជីគណនេយ្យតែជាចំណូលមិនត្រូវជាប់ពន្ធក្នុងឆ្នាំ÷** ជាចំណូលផ្សេងៗទៀតដែលមិនត្រូវជាប់ពន្ធតាមច្បាប់ស្តីពីសារពើពន្ធ។

**ឧទាហរណ៍÷** ចំណេញពីអត្រាប្តូរប្រាក់មិនទាន់សម្រេចបាន ចំណូលកត់មុនពីការិយបរិច្ឆេទមុន ចំណេញពីការវាយតម្លៃទ្រព្យសកម្មឡើងវិញតាមគណនេយ្យ...។

**E35- សរុប÷** ត្រូវកត់ត្រាទឹកប្រាក់សរុបពីប្រអប់ **“E32: ចំណូលលើភាគលាភទទួលបានពីអ្នកជាប់ពន្ធនិវាសនជន”** ដល់ប្រអប់ **“E34: ចំណូលផ្សេងៗបានកត់ត្រាក្នុងបញ្ជីគណនេយ្យតែជាចំណូលមិនត្រូវជាប់ពន្ធក្នុងឆ្នាំ”**។

**E36- ប្រាក់ចំណូលសុទ្ធ/(ខាត)ក្រោយនិយតកម្ម÷** គឺជាលទ្ធផលនៃការគណនាដោយយកទឹកប្រាក់ពីប្រអប់ **“E1: ប្រាក់ចំណេញ/(ខាត)មុនបង់ពន្ធ លទ្ធផលគណនេយ្យ ចំណេញ/ខាត”** បូក **“E18: សរុបចំណាយមិនអាចកាត់កងបាន”** បូក **“E25: សរុបចំណូលជាប់ពន្ធតែមិនត្រូវបានកត់ត្រាក្នុងបញ្ជីគណនេយ្យ”** ដក **“E31: សរុបចំណាយមិនកត់ត្រាក្នុងបញ្ជីគណនេយ្យតែជាចំណាយកាត់កងបានក្នុងឆ្នាំ”** ហើយដក **“E35: សរុបចំណូលបានកត់ត្រាក្នុងបញ្ជីគណនេយ្យតែជាចំណូលមិនត្រូវជាប់ពន្ធក្នុងឆ្នាំ”**។

**E37- ចំណាយសប្បុរសធម៌ដែលមិនអាចកាត់កង÷** ជាចំណាយសប្បុរសធម៌ដែលមិនអនុញ្ញាតកាត់កងក្នុងការិយបរិច្ឆេទ ដែលយកចេញពីប្រអប់ **“F6: ចំណាយសប្បុរសធម៌មិនអាចកាត់កងបានត្រូវបូកបញ្ចូលប្រាក់ចំណូល/(ខាត)ជាប់ពន្ធ”**។

**E38- ប្រាក់ចំណូលសុទ្ធ/(ខាត)មុននិយតកម្មលើការប្រាក់÷** ត្រូវកត់ត្រាទឹកប្រាក់បានពីលទ្ធផលគណនាដោយយកប្រអប់ **“E36: ប្រាក់ចំណូលសុទ្ធ/(ខាត) ក្រោយនិយតកម្ម”** បូកនឹងប្រអប់ **“E37: ចំណាយសប្បុរសធម៌ដែលមិនអាចកាត់កង”**។

**E39- និយតកម្មលើការប្រាក់÷** ត្រូវយកតួលេខពី “TOI 01/VIII, **G8: ចំនួនទឹកប្រាក់ដែលត្រូវបូកក្នុងប្រាក់ចំណូលសុទ្ធ/(ខាត) មុននិយតកម្មលើការប្រាក់**” (ជាចំនួនវិជ្ជមាន) ឬយកតួ

លេខសរុបពី "TOI 01/VIII, **G11: ចំនួនទឹកប្រាក់ដែលត្រូវដកចេញពីប្រាក់ចំណូលសុទ្ធ/(ខាត) មុននិយតកម្មលើការប្រាក់**" (ជាចំនួនអវិជ្ជមាន)។

**កំណត់សម្គាល់÷** ការប្រាក់អនុញ្ញាតឱ្យកាត់កងក្នុងឆ្នាំជាប់ពន្ធណាមួយ ត្រូវគណនាទូវដំណាច់ឆ្នាំជាប់ពន្ធនោះ។ ចំណាយការប្រាក់ដែលមិនត្រូវបានអនុញ្ញាតឱ្យកាត់កងក្នុងឆ្នាំជាប់ពន្ធចរន្ត អាចយោងជាចំណាយការប្រាក់សម្រាប់ឆ្នាំជាប់ពន្ធបន្តបន្ទាប់ទៀតនៅក្នុងកំហិតដូចគ្នារហូតដល់ឆ្នាំជាប់ពន្ធទី៥ ដោយគិតតាមលំដាប់ឆ្នាំដែលការប្រាក់បានកើតឡើង។

**E40- ប្រាក់ចំណូលសុទ្ធ/(ខាត)ក្នុងការិយបរិច្ឆេទ÷** គឺជាលទ្ធផលបានមកពីការគណនាដោយយកប្រអប់ "**E38: ប្រាក់ចំណូលសុទ្ធ/(ខាត)មុននិយតកម្មលើការប្រាក់**" បូកឬដក ប្រអប់ "**E39: និយតកម្មលើការប្រាក់**"។

**E41- ខាតយោងពីឆ្នាំមុនអនុញ្ញាត÷** គឺជាចំនួនទឹកប្រាក់ខាតសារពើពន្ធយោងពីការិយបរិច្ឆេទមុនៗដែលអនុញ្ញាតសម្រាប់កាត់កងប្រាក់ចំណូលសុទ្ធ/(ខាត) ក្នុងការិយបរិច្ឆេទ។

**កំណត់សម្គាល់÷** ក្នុងករណីដែលមានការខាតបង់នៅក្នុងឆ្នាំជាប់ពន្ធណាមួយ ការខាតបង់នោះត្រូវចាត់ទុកជាបន្ទុកសម្រាប់ឆ្នាំជាប់ពន្ធបន្ទាប់ ហើយត្រូវកាត់ចេញពីប្រាក់ចំណូលសុទ្ធសម្រេចបាននៅក្នុងឆ្នាំជាប់ពន្ធបន្ទាប់នោះ។ បើប្រាក់ចំណូលសុទ្ធនេះមិនគ្រប់គ្រាន់សម្រាប់ទូទាត់ជាស្ថាពរទេ ចំណែកនៃការខាតបង់ដែលនៅសេសសល់ ត្រូវយោងទៅឆ្នាំជាប់ពន្ធបន្តបន្ទាប់រហូតដល់ឆ្នាំជាប់ពន្ធទី៥។ នៅពេលណាដែលការខាតបង់មានលើសពីមួយឆ្នាំ ការយោងការខាតទៅមុខ ត្រូវអនុវត្តចំពោះការខាតបង់ទាំងឡាយតាមលំដាប់ ដែលការខាតបង់បានកើតឡើង។

**E42- ប្រាក់ចំណូល/(ខាត)ជាប់ពន្ធសម្រាប់គណនាពន្ធលើប្រាក់ចំណូល÷** ត្រូវគណនាដោយយកប្រអប់ "**E40: ប្រាក់ចំណូលសុទ្ធ/(ខាត) ក្នុងការិយបរិច្ឆេទ**" ដកនឹងប្រអប់ "**E41: ខាតយោងពីឆ្នាំមុនអនុញ្ញាត**"។

**E43- ពន្ធលើប្រាក់ចំណូលតាមអត្រា... ÷** ប្រអប់នេះបានមកពីការគណនាដោយយកប្រអប់ "**E42: ប្រាក់ចំណូល/(ខាត) ជាប់ពន្ធសម្រាប់គណនាពន្ធលើប្រាក់ចំណូល**" គុណនឹងអត្រាពន្ធដែលបានជ្រើសរើសសញ្ញា √ នៅទំព័រទី១ (អត្រាពន្ធលើប្រាក់ចំណូល)។

**E44- ពន្ធលើប្រាក់ចំណូលលើសកម្រិត÷** ត្រូវកត់ត្រាលទ្ធផលគណនាពន្ធលើប្រាក់ចំណូលលើសកម្រិត (X5) ក្នុងឧបសម្ព័ន្ធ ៤។

ត្រូវដាក់លេខសូន្យក្នុងប្រអប់នេះចំពោះសហគ្រាសដែលមានអាជីវកម្មក្រៅពីប្រតិបត្តិការធនធានរ៉ែ / ប្រេងកាត។

| | |
|---|---|
| **E45- សរុប÷** | សរុបប្រាក់ពន្ធលើប្រាក់ចំណូលដោយយកប្រអប់ **"E43: ពន្ធលើប្រាក់ចំណូលតាមអត្រា..."** បូកនឹងប្រអប់ **"E44: ពន្ធលើប្រាក់ចំណូលលើសកម្រិត"** ។ |
| **E46- ឥណទានពន្ធបរទេស÷** | ឥណទានពន្ធបរទេសអាចផ្តល់ឱ្យបាន លុះណាតែអ្នកជាប់ពន្ធនិវាសនជនបានបំពេញបែបបទ ព្រមទាំងផ្តល់ឯកសារនានាកំណត់ដោយរដ្ឋបាលសារពើពន្ធ ជាពិសេសសេចក្តីបញ្ជាក់របស់អ្នកទូទាត់ប្រាក់ពន្ធនៅបរទេសនិងរដ្ឋបាលសារពើពន្ធបរទេសនោះ។ |
| **E47- បំណុលពន្ធលើប្រាក់ចំណូលក្រោយដកឥណទានពន្ធបរទេស÷** | ត្រូវធ្វើការគណនាដោយយកប្រអប់ **"E45: ពន្ធលើប្រាក់ចំណូលសរុប"** ដកនឹងប្រអប់ **"E46: ឥណទានពន្ធបរទេស"** ។<br>- ប្រសិនបើលទ្ធផលវិជ្ជមាន ត្រូវដាក់តួលេខដែលបានគណនាក្នុងប្រអប់នេះ<br>- ប្រសិនបើលទ្ធផលអវិជ្ជមាន ត្រូវដាក់លេខសូន្យក្នុងប្រអប់នេះ។ |
| **E48- ពន្ធបង់មុនលើការបែងចែកភាគលាភបានបង់ក្នុងឆ្នាំ÷** | កត់ត្រាប្រាក់ពន្ធបង់មុនលើការបែងចែកភាគលាភដែលបានបង់ដោយសហគ្រាសក្នុងការិយបរិច្ឆេទ។ |
| **E49- ឥណទានពន្ធបង់មុនលើការបែងភាគលាភសម្រាប់កាត់កងពន្ធលើប្រាក់ចំណូលក្នុងឆ្នាំ÷** | គឺជាពន្ធបង់មុនលើការបែងចែកភាគលាភក្នុងឆ្នាំជាប់ពន្ធដែលអនុញ្ញាតជាឥណទានពន្ធដូចមានចែងក្នុងកថាខណ្ឌ២ នៃមាត្រា ២៣ ថ្មី (ពីរ) នៃច្បាប់ស្តីពីសារពើពន្ធ។ ប្រអប់ E49 ត្រូវយកតួលេខពីប្រអប់ **"E48: ពន្ធបង់មុនលើការបែងចែកភាគលាភបានបង់ក្នុងឆ្នាំ"** ឬប្រអប់ **"E47: បំណុលពន្ធលើប្រាក់ចំណូលក្រោយពីដកឥណទានពន្ធបរទេស"** មួយណាមានតម្លៃតូចជាងគេ។ |
| **E50- បំណុលពន្ធលើប្រាក់ចំណូល÷** | ត្រូវធ្វើការគណនាដោយយកពីប្រអប់ **"E47: បំណុលពន្ធលើប្រាក់ចំណូលក្រោយដកឥណទានពន្ធបរទេស"** ដកនឹងប្រអប់ **"E49: ឥណទានពន្ធបង់មុនលើការបែងចែកភាគលាភសម្រាប់កាត់កងពន្ធលើប្រាក់ចំណូលក្នុងឆ្នាំ"** ។<br>ប្រសិនបើលទ្ធផលអវិជ្ជមាន ត្រូវដាក់លេខសូន្យក្នុងប្រអប់នេះ។ |
| **E51- ពន្ធអប្បបរមា÷** | ត្រូវគណនាដោយយកផលរបរប្រចាំឆ្នាំមិនរួមបញ្ចូលអាករលើតម្លៃបន្ថែមពីចំណូលអាជីវកម្ម និងចំណូលបន្ទាប់បន្សំ គុណនឹងអត្រា ១ភាគរយ។ |
| **E52- បំណុលពន្ធលើប្រាក់ចំណូលត្រូវបង់÷** | ជាកំណត់សម្គាល់បំណុលពន្ធលើប្រាក់ចំណូលត្រូវបង់។ |
| **E53- សម្រាប់សហគ្រាសដែលកាន់បញ្ជិកាគណនេយ្យត្រឹមត្រូវ បំណុលពន្ធលើប្រាក់ចំណូល** | សម្រាប់សហគ្រាសដែលកាន់បញ្ជិកាគណនេយ្យត្រឹមត្រូវ បំណុលពន្ធលើប្រាក់ចំណូល ត្រូវស្មើប្រអប់ **"E50: បំណុលពន្ធលើប្រាក់ចំណូល"** ។ |
| **E54- សម្រាប់សហគ្រាសដែលកាន់បញ្ជិកាគណនេយ្យមិនត្រឹមត្រូវ បំណុលពន្ធលើប្រាក់ចំណូល÷** | សម្រាប់សហគ្រាសដែលកាន់បញ្ជិកាគណនេយ្យមិនត្រឹមត្រូវ បំណុលពន្ធលើប្រាក់ចំណូល ត្រូវស្មើនឹងប្រអប់ **"E50: បំណុលពន្ធលើប្រាក់ចំណូល"** ឬប្រអប់ **"E51: ពន្ធអប្បបរមា"** ណាមួយមានតម្លៃខ្ពស់ជាងគេ។ |

| | |
|---|---|
| **E55-ឥណទានពន្ធកាត់ទុកបានបង់ក្នុងឆ្នាំ÷** | ត្រូវកត់ត្រាឥណទានពន្ធកាត់ទុកសរុបដែលបានបង់ក្នុងឆ្នាំជាប់ពន្ធដូចជាពន្ធកាត់ទុកលើការប្រាក់ ឬសួយសារវរវាងអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសដូចគ្នា។ |
| **E56-ប្រាក់រំដោះពន្ធលើប្រាក់ចំណូលបានបង់ក្នុងឆ្នាំ÷** | ត្រូវកត់ត្រាប្រាក់រំដោះពន្ធលើប្រាក់ចំណូលបានបង់សរុបក្នុងការិយបរិច្ឆេទ។ |
| **E57-ឥណទានពន្ធបង់មុនលើការបែងចែកភាគលាភនៅសល់ក្នុងឆ្នាំ÷** | ជាសមតុល្យរវាងប្រអប់ **“E48: ពន្ធបង់មុនលើការបែងចែកភាគលាភបានបង់ក្នុងឆ្នាំ”** ដកនឹងប្រអប់ **“E49: ឥណទានពន្ធបង់មុនលើការបែងចែកភាគលាភសម្រាប់កាត់កងពន្ធលើប្រាក់ចំណូលក្នុងឆ្នាំ”**។ |
| **E58-ឥណទានពន្ធលើប្រាក់ចំណូលយោងពីឆ្នាំមុន÷** | ត្រូវបំពេញតួលេខពីប្រអប់ 18 ទំព័រទី១ នៃលិខិតប្រកាសពន្ធលើប្រាក់ចំណូលពីការិយបរិច្ឆេទមុន (N-1)។ |
| **E59-ពន្ធលើប្រាក់ចំណូលត្រូវបង់ / ត្រូវយោងទៅឆ្នាំបន្ទាប់÷** | ត្រូវគណនាពន្ធលើប្រាក់ចំណូលត្រូវបង់ ឬឥណទានត្រូវយោងទៅឆ្នាំបន្ទាប់÷<br>- សម្រាប់សហគ្រាសដែលកាន់បញ្ជិកាគណនេយ្យត្រឹមត្រូវ បំណុលពន្ធលើប្រាក់ចំណូល ត្រូវស្មើប្រអប់ **E53** ដក **E55** ដក **E56** ដក **E57** ដក **E58**។<br>- សម្រាប់សហគ្រាសដែលកាន់បញ្ជិកាគណនេយ្យមិនត្រឹមត្រូវ បំណុលពន្ធលើប្រាក់ចំណូល ត្រូវស្មើប្រអប់ **E54** ដក **E55** ដក **E56** ដក **E57** ដក **E58**។<br>**កំណត់សម្គាល់÷**<br>- ប្រសិនបើលទ្ធផលវិជ្ជមាន ពន្ធលើប្រាក់ចំណូលត្រូវបង់ (លទ្ធផលនេះដាក់ក្នុងប្រអប់លេខ 17 នៃទំព័រទី១)។<br>- ប្រសិនបើលទ្ធផលអវិជ្ជមាន ឥណទានពន្ធយោងទៅឆ្នាំបន្ទាប់ (លទ្ធផលនេះដាក់ក្នុងប្រអប់លេខ 18 នៃទំព័រទី១)។ |

# ទំព័រទី១១ និងទី១២ (TOI 01/VIII)÷ តារាងគណនាវិភាគទានសប្បុរសធម៌ ការប្រាក់អាចកាត់កងបាន និងឥណទានខាតយោងទៅមុខ

## ក- ការគណនាវិភាគទានសប្បុរសធម៌

- មិនចាំបាច់បំពេញទេ ប្រសិនបើមិនមានចំណាយវិភាគទានសប្បុរសធម៌ កើតឡើងក្នុងឆ្នាំជាប់ពន្ធ។
- ចាំបាច់ត្រូវបំពេញ ប្រសិនបើមានចំណាយវិភាគទានសប្បុរសធម៌ដូចខាងក្រោម÷
  - ចំណាយវិភាគទានសប្បុរសធម៌ត្រូវផ្តល់ឱ្យស្ថាប័នរដ្ឋាភិបាល ឬ
  - អង្គការដែលមិនស្វែងរកប្រាក់ចំណេញ ឬ
  - អង្គការ ឬស្ថាប័នដែលទទួលបានការលើកលែងពន្ធ ត្រូវតែមានការទទួលស្គាល់ និងមានឯកសារបញ្ជាក់ចេញដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

| ខ្លឹមសារនៅក្នុងលិខិតប្រកាស | សេចក្តីពន្យល់ |
|---|---|
| **F1- ប្រាក់ចំណូលសុទ្ធ/(ខាត) ក្រោយនិយតកម្ម÷** | ត្រូវកត់ត្រាតួលេខនៃ TOI 01/VII, "**E36: ប្រាក់ចំណូលសុទ្ធ/(ខាត) ក្រោយនិយតកម្ម**"។ |
| **F2- ចំណាយសប្បុរសធម៌÷** | ត្រូវកត់ត្រាចំណាយសប្បុរសធម៌ដែលបានកើតឡើងក្នុងឆ្នាំជាប់ពន្ធ។ |
| **F3- ប្រាក់ចំណូលសម្រាប់គណនាចំណាយសប្បុរសធម៌អតិបរមាអាចកាត់កងបាន÷** | ត្រូវគណនាដោយយក "**F1: ប្រាក់ចំណូលសុទ្ធ/(ខាត)ក្រោយនិយតកម្ម**" បូក "**F2: ចំណាយវិភាគទានសប្បុរសធម៌**"។<br>ត្រូវកត់ត្រាលេខសូន្យ ប្រសិនបើតួលេខនៅប្រអប់ F3 អវិជ្ជមាន។ |
| **F4- ចំណាយសប្បុរសធម៌អតិបរមាអាចកាត់កងបាន÷** | ត្រូវគណនាចំណាយសប្បុរសធម៌អតិបរមាអនុញ្ញាតសម្រាប់កាត់កងក្នុងឆ្នាំជាប់ពន្ធ។ ចំនួនទឹកប្រាក់នៅប្រអប់នេះ មិនមែនជាចំនួនទឹកប្រាក់ប្រើសម្រាប់កាត់កងនោះទេ។ ទឹកប្រាក់នេះត្រូវគណនាដោយយក "**F3: ប្រាក់ចំណូលសម្រាប់គណនាចំណាយសប្បុរសធម៌អតិបរមា ដែលអាចកាត់កងបាន**" គុណនឹង ៥%។ |
| **F5- ចំណាយសប្បុរសធម៌អាចកាត់កងបានក្នុងឆ្នាំ÷** | ត្រូវប្រៀបធៀបរវាងប្រអប់ "**F2: ចំណាយសប្បុរសធម៌**" និងប្រអប់ "**F4: ចំណាយសប្បុរសធម៌អតិបរមាអាចកាត់កងបាន**" បន្ទាប់មកត្រូវជ្រើសរើសយកតួលេខណាដែលតិចជាងគេ បំពេញក្នុងប្រអប់នេះ។ |
| **F6- ចំណាយសប្បុសធម៌មិនអាចកាត់កងបានត្រូវបូកបញ្ចូលប្រាក់ចំណូល/(ខាត)ជាប់ពន្ធ÷** | ត្រូវគណនាដោយយកប្រអប់ "**F2: ចំណាយសប្បុរសធម៌**" ដកនឹងប្រអប់ "**F5: ចំណាយសប្បុរសធម៌អាចកាត់កងបានក្នុងឆ្នាំ**"។ លទ្ធផលដែលគណនាឃើញក្នុងប្រអប់នេះ ត្រូវយកទៅកត់ត្រាក្នុងប្រអប់ "**E37: ចំណាយសប្បុរសធម៌ដែលមិនអាចកាត់កង**"។ |

## ខ- ការគណនាចំណាយការប្រាក់

- ❖ តារាងនេះ សម្រាប់គណនាចំណាយការប្រាក់ដែលត្រូវអនុញ្ញាតឱ្យកាត់កងក្នុងឆ្នាំជាប់ពន្ធ។
- ❖ មិនចាំបាច់បំពេញទេ ប្រសិនបើមិនមានចំណាយការប្រាក់កើតឡើងក្នុងឆ្នាំជាប់ពន្ធ និងចំណាយការប្រាក់យោងពីឆ្នាំជាប់ពន្ធមុនៗ។

| ខ្លឹមសារនៅក្នុងលិខិតប្រកាស | សេចក្ដីពន្យល់ |
|---|---|
| G1-ប្រាក់ចំណូលសុទ្ធ/ (ខាត)មុននិយតកម្មលើការប្រាក់÷ | ត្រូវកត់ត្រាតួលេខយកពី TOI 01/VII ប្រអប់ **"E38: ប្រាក់ចំណូលសុទ្ធ/ (ខាត) មុននិយតកម្មលើការប្រាក់"**។ |
| **G2-ចំណាយការប្រាក់ក្នុងការិយបរិច្ឆេទ÷** | ត្រូវកត់ត្រាចំណាយការប្រាក់ដែលបានទូទាត់ ឬត្រូវទូទាត់ក្នុងឆ្នាំជាប់ពន្ធ មិនរួមបញ្ចូល **"B45: ចំណាយការប្រាក់សន្មត (Unwinding Interest Expense)"** ទេ។ |
| **G3-ចំណូលការប្រាក់ក្នុងការិយបរិច្ឆេទ÷** | ត្រូវកត់ត្រាចំណូលការប្រាក់ដែលបានទទួល ឬត្រូវទទួលក្នុងឆ្នាំជាប់ពន្ធមិនរួមបញ្ចូល " ចំណូលការប្រាក់សន្មត (Unwinding Interest Income)" ទេ។ |
| G4-ប្រាក់ចំណូលសុទ្ធគ្មានការប្រាក់÷ | តួលេខក្នុងប្រអប់នេះ ត្រូវគណនាចំណូលសុទ្ធគ្មានការប្រាក់ដោយយក **"G1: ប្រាក់ចំណូលសុទ្ធ/(ខាត) មុននិយតកម្មលើការប្រាក់"** បូក **"G2: ចំណាយការប្រាក់ក្នុងការិយបរិច្ឆេទ"** ដក **"G3: ចំណូលការប្រាក់ក្នុងការិយបរិច្ឆេទ"**។ |
| G5-៥០% នៃប្រាក់ចំណូលសុទ្ធគ្មានការប្រាក់÷ | ត្រូវគណនាដោយយក **"G4: ប្រាក់ចំណូលសុទ្ធគ្មានការប្រាក់"** គុណនឹង៥០%។ |
| **G6-ចំណូលការប្រាក់ក្នុងការិយបរិច្ឆេទ÷** | តួលេខក្នុងប្រអប់នេះដូចគ្នានឹង **"G3: ចំណូលការប្រាក់ក្នុងការិយបរិច្ឆេទ"**។ |
| **G7-ចំណាយការប្រាក់អតិបរមាអនុញ្ញាតឱ្យកាត់កងបានក្នុងការិយបរិច្ឆេទ÷** | គឺជាការកំណត់នូវកម្រិតនៃចំណាយការប្រាក់អតិបរមា ដែលអនុញ្ញាតឱ្យកាត់កងបានក្នុងការិយបរិច្ឆេទ។<br>តួលេខនេះត្រូវគណនាដោយយក **"G5: ៥០% នៃប្រាក់ចំណូលសុទ្ធគ្មានការប្រាក់"** បូក **"G6: ចំណូលការប្រាក់ក្នុងការិយបរិច្ឆេទ"**។ |
| G8-ចំនួនទឹកប្រាក់ដែលត្រូវបូកក្នុងប្រាក់ចំណូលជាប់ពន្ធ÷ | ត្រូវយក **"G2: ចំណាយការប្រាក់ក្នុងការិយបរិច្ឆេទ"** ដក **"G7: ចំណាយការប្រាក់អតិបរមាអនុញ្ញាតឱ្យកាត់កងបានក្នុងការិយបរិច្ឆេទ"**÷<br>-បើ G7 តូចជាង G2 នោះ ចំនួនលម្អៀងនេះត្រូវយកទៅបូកបន្ថែមប្រាក់ចំណូលជាប់ពន្ធ ដោយបំពេញក្នុងប្រអប់ E39 និងបំពេញក្នុងប្រអប់ G10 នៃតារាង ខ.១ (តារាងតាមដានចំណាយការប្រាក់យោងទៅមុខ)នៅទំព័រទី១២។<br>-បើ G7 ធំជាង G2 នោះ ចំនួនលម្អៀងនេះត្រូវយកទៅបំពេញក្នុងប្រអប់ G9 នៃតារាង ខ.១ (តារាងតាមដានចំណាយការប្រាក់យោងទៅមុខ)នៅទំព័រទី១២។ |

## ខ.១- តារាងតាមដានចំណាយការប្រាក់យោងទៅមុខ

| ខ្លឹមសារនៅក្នុងលិខិតប្រកាស | សេចក្ដីពន្យល់ |
|---|---|
| **ការិយបរិច្ឆេទ÷** | គឺជាការិយបរិច្ឆេទនៃឆ្នាំជាប់ពន្ធ។ |
| **(G9)-ចំណាយការប្រាក់អតិបរមាដែលអាចកាត់កងជាមួយការប្រាក់យោងពីឆ្នាំមុន÷** | ត្រូវបំពេញប្រអប់នេះតែក្នុងករណី G7 ធំជាង G2 ប៉ុណ្ណោះ។ តួលេខ G9 ស្មើ **“G7: ចំណាយការប្រាក់អតិបរមាអនុញ្ញាតឱ្យកាត់កងបានក្នុងការិយបរិច្ឆេទ”** ដក **“G2: ចំណាយការប្រាក់ក្នុងការិយបរិច្ឆេទ”** ។ |
| **(G10)-និយតកម្មការប្រាក់មិនអាចកាត់កងក្នុងការិយបរិច្ឆេទ÷** | ត្រូវបំពេញប្រអប់នេះតែក្នុងករណី G7 តូចជាង G2 ប៉ុណ្ណោះ។ តួលេខ G10 ស្មើ **“G2: ចំណាយការប្រាក់ក្នុងការិយបរិច្ឆេទ”** ដក **“G7: ចំណាយការប្រាក់អតិបរមាអនុញ្ញាតឱ្យកាត់កងបានក្នុងការិយបរិច្ឆេទ”** ដែលកើតមាននៅក្នុងឆ្នាំនីមួយៗ។ |
| **(G11)-ការប្រាក់អនុញ្ញាតប្រើប្រាស់កាត់កងក្នុងការិយបរិច្ឆេទ÷** | គឺជាចំណាយការប្រាក់យោងពីឆ្នាំជាប់ពន្ធមុន ដែលអនុញ្ញាតប្រើប្រាស់កាត់កងក្នុងឆ្នាំជាប់ពន្ធចរន្តជាមួយ **“G9: ចំណាយការប្រាក់អតិបរមាអាចកាត់កងជាមួយការប្រាក់យោងពីឆ្នាំមុន”**។ តួលេខសរុបពី G11 គឺជាចំនួនទឹកប្រាក់ដែលត្រូវដកចេញពីប្រាក់ចំណូលសុទ្ធ/(ខាត) មុននិយតកម្មលើការប្រាក់ ក្នុងករណីនេះ **“E39: និយតកម្មលើការប្រាក់”** ជាចំនួនអវិជ្ជមាន។ |
| **(G12)-ការប្រាក់អនុញ្ញាតប្រើប្រាស់កាត់កងបូកបន្ត÷** | គឺជាចំណាយការប្រាក់សរុបដែលបានប្រើប្រាស់កាត់កងក្នុងឆ្នាំជាប់ពន្ធមុនៗ និងឆ្នាំជាប់ពន្ធចរន្ត។ |
| **(G13)-ការប្រាក់នៅសល់អនុញ្ញាតប្រើប្រាស់យោងទៅមុខ÷** | គឺជាសមតុល្យរវាង **“G10: និយតកម្មការប្រាក់មិនអាចកាត់កងក្នុងការិយបរិច្ឆេទ”** ដក **“G12: ការប្រាក់អនុញ្ញាតប្រើប្រាស់កាត់កងបូកបន្ត”** ។ |

**ឧទាហរណ៍÷**

**(ឯកតាជាពាន់រៀល)**

| ឆ្នាំ | ចំណាយការប្រាក់ក្នុងការិយបរិច្ឆេទ | ចំណាយការប្រាក់អតិបរមាអនុញ្ញាតឱ្យកាត់កងបានក្នុងការិយបរិច្ឆេទ | ចំណាយការប្រាក់អតិបរមាដែលអាចកាត់កងជាមួយការប្រាក់យោងពីឆ្នាំមុន | និយតកម្មការប្រាក់មិនអាចកាត់កងក្នុងការិយបរិច្ឆេទ |
|---|---|---|---|---|
| | (G2) | (G7) | (G9) = (G7) - (G2) | (G10) = (G2) - (G7) |
| 20X0-1 | 968,000 | 170,000 | | 798,000 |
| 20X0 | 215,000 | 201,000 | | 14,000 |
| 20X1 | 180,000 | 486,250 | 306,250 | |
| 20X2 | 305,000 | 162,000 | | 143,000 |
| 20X3 | 162,000 | 201,000 | 39,000 | |
| 20X4 | 205,000 | 328,000 | 123,000 | |
| 20X5 | 121,000 | 262,000 | 141,000 | |
| 20X6 | 205,000 | 163,000 | | 42,000 |
| 20X7 | 159,000 | 215,000 | 56,000 | |
| 20X8 | 91,000 | 132,000 | 41,000 | |
| 20X9 | 75,000 | 26,000 | | 49,000 |

## ខ.១- តារាងតាមដានចំណាយការប្រាក់យោងទៅមុខ

**(20X0)**

| ការិយបរិច្ឆេទ | ចំណាយការប្រាក់អតិបរមាដែលអាចកាត់កងជាមួយការប្រាក់យោងពីឆ្នាំមុន | និយតកម្មការប្រាក់មិនអាចកាត់កងក្នុងការិយបរិច្ឆេទ | ការប្រាក់អនុញ្ញាតប្រើប្រាស់កាត់កងក្នុងការិយបរិច្ឆេទ | ការប្រាក់អនុញ្ញាតប្រើប្រាស់កាត់កងបូកបន្ត | ការប្រាក់នៅសល់អនុញ្ញាតប្រើប្រាស់យោងទៅមុខ |
|---|---|---|---|---|---|
| | (G9) | (G10) | (G11)* | (G12) | (G13) = (G10) - (G12) |
| ឆ្នាំ N-5 | | | | | |
| ឆ្នាំ N-4 | | | | | |
| ឆ្នាំ N-3 | | | | | |
| ឆ្នាំ N-2 | | | | | |
| ឆ្នាំ N-1 | | 798,000 | | | 798,000 |
| ឆ្នាំ N | | 14,000 | | | 14,000 |

**(20X1)**

| ការិយបរិច្ឆេទ | ចំណាយការប្រាក់អតិបរមាដែលអាចកាត់កងជាមួយការប្រាក់យោងពីឆ្នាំមុន | និយតកម្មការប្រាក់មិនអាចកាត់កងក្នុងការិយបរិច្ឆេទ | ការប្រាក់អនុញ្ញាតប្រើប្រាស់កាត់កងក្នុងការិយបរិច្ឆេទ | ការប្រាក់អនុញ្ញាតប្រើប្រាស់កាត់កងបូកបន្ត | ការប្រាក់នៅសល់អនុញ្ញាតប្រើប្រាស់យោងទៅមុខ |
|---|---|---|---|---|---|
| | (G9) | (G10) | (G11)* | (G12) | (G13) = (G10) - (G12) |
| ឆ្នាំ N-5 | | | | | |
| ឆ្នាំ N-4 | | | | | |
| ឆ្នាំ N-3 | | | | | |
| ឆ្នាំ N-2 | | 798,000 | 306,250 | 306,250 | 491,750 |
| ឆ្នាំ N-1 | | 14,000 | | | 14,000 |
| ឆ្នាំ N | 306,250 | | | | |

**(20X2)**

| ការិយបរិច្ឆេទ | ចំណាយការប្រាក់អតិបរមាដែលអាចកាត់កងជាមួយការប្រាក់យោងពីឆ្នាំមុន | និយតកម្មការប្រាក់មិនអាចកាត់កងក្នុងការិយបរិច្ឆេទ | ការប្រាក់អនុញ្ញាតប្រើប្រាស់កាត់កងក្នុងការិយបរិច្ឆេទ | ការប្រាក់អនុញ្ញាតប្រើប្រាស់កាត់កងបូកបន្ត | ការប្រាក់នៅសល់អនុញ្ញាតប្រើប្រាស់យោងទៅមុខ |
|---|---|---|---|---|---|
| | (G9) | (G10) | (G11)* | (G12) | (G13) = (G10) - (G12) |
| ឆ្នាំ N-5 | | | | | |
| ឆ្នាំ N-4 | | | | | |
| ឆ្នាំ N-3 | | 798,000 | | 306,250 | 491,750 |
| ឆ្នាំ N-2 | | 14,000 | | | 14,000 |
| ឆ្នាំ N-1 | | | | | |
| ឆ្នាំ N | | 143,000 | | | 143,000 |

**(20X3)**

| ការិយបរិច្ឆេទ | ចំណាយការប្រាក់អតិបរមា ដែលអាចកាត់កងជាមួយ ការប្រាក់យោងពីឆ្នាំមុន | និយតកម្មការប្រាក់ មិនអាចកាត់កងក្នុង ការិយបរិច្ឆេទ | ការប្រាក់អនុញ្ញាត ប្រើប្រាស់កាត់កង ក្នុងការិយបរិច្ឆេទ | ការប្រាក់អនុញ្ញាត ប្រើប្រាស់កាត់កង បូកបន្ត | ការប្រាក់នៅសល់ អនុញ្ញាតប្រើប្រាស់យោង ទៅមុខ |
|---|---|---|---|---|---|
| | (G9) | (G10) | (G11)* | (G12) | (G13) = (G10) - (G12) |
| ឆ្នាំ N-5 | | | | | - |
| ឆ្នាំ N-4 | | 798,000 | 39,000 | 345,250 | 452,750 |
| ឆ្នាំ N-3 | | 14,000 | | | 14,000 |
| ឆ្នាំ N-2 | | | | | |
| ឆ្នាំ N-1 | | 143,000 | | | 143,000 |
| ឆ្នាំ N | 39,000 | | | | |

**(20X4)**

| ការិយបរិច្ឆេទ | ចំណាយការប្រាក់អតិបរមា ដែលអាចកាត់កងជាមួយ ការប្រាក់យោងពីឆ្នាំមុន | និយតកម្មការប្រាក់ មិនអាចកាត់កងក្នុង ការិយបរិច្ឆេទ | ការប្រាក់អនុញ្ញាត ប្រើប្រាស់កាត់កង ក្នុងការិយបរិច្ឆេទ | ការប្រាក់អនុញ្ញាត ប្រើប្រាស់កាត់កង បូកបន្ត | ការប្រាក់នៅសល់ អនុញ្ញាតប្រើប្រាស់យោង ទៅមុខ |
|---|---|---|---|---|---|
| | (G9) | (G10) | (G11)* | (G12) | (G13) = (G10) - (G12) |
| ឆ្នាំ N-5 | | 798,000 | 123,000 | 468,250 | 329,750 |
| ឆ្នាំ N-4 | | 14,000 | | | 14,000 |
| ឆ្នាំ N-3 | | | | | |
| ឆ្នាំ N-2 | | 143,000 | | | 143,000 |
| ឆ្នាំ N-1 | | | | | |
| ឆ្នាំ N | 123,000 | | | | |

**(20X5)**

| ការិយបរិច្ឆេទ | ចំណាយការប្រាក់អតិបរមា ដែលអាចកាត់កងជាមួយ ការប្រាក់យោងពីឆ្នាំមុន | និយតកម្មការប្រាក់ មិនអាចកាត់កងក្នុង ការិយបរិច្ឆេទ | ការប្រាក់អនុញ្ញាត ប្រើប្រាស់កាត់កង ក្នុងការិយបរិច្ឆេទ | ការប្រាក់អនុញ្ញាត ប្រើប្រាស់កាត់កង បូកបន្ត | ការប្រាក់នៅសល់ អនុញ្ញាតប្រើប្រាស់យោង ទៅមុខ |
|---|---|---|---|---|---|
| | (G9) | (G10) | (G11)* | (G12) | (G13) = (G10) - (G12) |
| ឆ្នាំ N-5 | | 14,000 | 14,000 | 14,000 | - |
| ឆ្នាំ N-4 | | | | | |
| ឆ្នាំ N-3 | | 143,000 | 127,000 | 127,000 | 16,000 |
| ឆ្នាំ N-2 | | | | | |
| ឆ្នាំ N-1 | | | | | |
| ឆ្នាំ N | 141,000 | | | | |

* សរុបចំនួនទឹកប្រាក់កូឡោន (G11) ត្រូវយកទៅដកចេញពីប្រាក់ចំណូលជាប់ពន្ធ (E39) = (141,000)

**(20X6)**

| ការិយបរិច្ឆេទ | ចំណាយការប្រាក់អតិបរមា ដែលអាចកាត់កងជាមួយ ការប្រាក់យោងពីឆ្នាំមុន | និយតកម្មការប្រាក់ មិនអាចកាត់កងក្នុង ការិយបរិច្ឆេទ | ការប្រាក់អនុញ្ញាត ប្រើប្រាស់កាត់កង ក្នុងការិយបរិច្ឆេទ | ការប្រាក់អនុញ្ញាត ប្រើប្រាស់កាត់កង បូកបន្ត | ការប្រាក់នៅសល់ អនុញ្ញាតប្រើប្រាស់យោង ទៅមុខ |
|---|---|---|---|---|---|
| | (G9) | (G10) | (G11)* | (G12) | (G13) = (G10) - (G12) |
| ឆ្នាំ N-5 | | | | | |
| ឆ្នាំ N-4 | | 143,000 | | 127,000 | 16,000 |
| ឆ្នាំ N-3 | | | | | |
| ឆ្នាំ N-2 | | | | | |
| ឆ្នាំ N-1 | | | | | |
| ឆ្នាំ N | | 42,000 | | | 42,000 |

**(20X7)**

| ការិយបរិច្ឆេទ | ចំណាយការប្រាក់អតិបរមា ដែលអាចកាត់កងជាមួយ ការប្រាក់យោងពីឆ្នាំមុន | និយតកម្មការប្រាក់ មិនអាចកាត់កងក្នុង ការិយបរិច្ឆេទ | ការប្រាក់អនុញ្ញាត ប្រើប្រាស់កាត់កង ក្នុងការិយបរិច្ឆេទ | ការប្រាក់អនុញ្ញាត ប្រើប្រាស់កាត់កង បូកបន្ត | ការប្រាក់នៅសល់ អនុញ្ញាតប្រើប្រាស់យោង ទៅមុខ |
|---|---|---|---|---|---|
| | (G9) | (G10) | (G11)* | (G12) | (G13) = (G10) - (G12) |
| ឆ្នាំ N-5 | | 143,000 | 16,000 | 143,000 | - |
| ឆ្នាំ N-4 | | | | | |
| ឆ្នាំ N-3 | | | | | |
| ឆ្នាំ N-2 | | | | | |
| ឆ្នាំ N-1 | | 42,000 | 40,000 | 40,000 | 2,000 |
| ឆ្នាំ N | 56,000 | | | | |

**(20X8)**

| ការិយបរិច្ឆេទ | ចំណាយការប្រាក់អតិបរមា ដែលអាចកាត់កងជាមួយ ការប្រាក់យោងពីឆ្នាំមុន | និយតកម្មការប្រាក់ មិនអាចកាត់កងក្នុង ការិយបរិច្ឆេទ | ការប្រាក់អនុញ្ញាត ប្រើប្រាស់កាត់កង ក្នុងការិយបរិច្ឆេទ | ការប្រាក់អនុញ្ញាត ប្រើប្រាស់កាត់កង បូកបន្ត | ការប្រាក់នៅសល់ អនុញ្ញាតប្រើប្រាស់យោង ទៅមុខ |
|---|---|---|---|---|---|
| | (G9) | (G10) | (G11)* | (G12) | (G13) = (G10) - (G12) |
| ឆ្នាំ N-5 | | | | | |
| ឆ្នាំ N-4 | | | | | |
| ឆ្នាំ N-3 | | | | | |
| ឆ្នាំ N-2 | | 42,000 | 2,000 | 42,000 | - |
| ឆ្នាំ N-1 | | | | | |
| ឆ្នាំ N | 41,000 | | | | |

**(20X9)**

| ការិយបរិច្ឆេទ | ចំណាយការប្រាក់អតិបរមាដែលអាចកាត់កងជាមួយការប្រាក់យោងពីឆ្នាំមុន | និយតកម្មការប្រាក់មិនអាចកាត់កងក្នុងការិយបរិច្ឆេទ | ការប្រាក់អនុញ្ញាតប្រើប្រាស់កាត់កងក្នុងការិយបរិច្ឆេទ | ការប្រាក់អនុញ្ញាតប្រើប្រាស់កាត់កងបូកបន្ត | ការប្រាក់នៅសល់អនុញ្ញាតប្រើប្រាស់យោងទៅមុខ |
|---|---|---|---|---|---|
| | (G9) | (G10) | (G11)* | (G12) | (G13) = (G10) - (G12) |
| ឆ្នាំ N-5 | | | | | |
| ឆ្នាំ N-4 | | | | | |
| ឆ្នាំ N-3 | | | | | |
| ឆ្នាំ N-2 | | | | | |
| ឆ្នាំ N-1 | | | | | |
| ឆ្នាំ N | | 49,000 | | | 49,000 |

## គ- តារាងតាមដានលទ្ធផលសារពើពន្ធខាតយោងទៅមុខ

តារាងនេះ សម្រាប់គណនាលទ្ធផលសារពើពន្ធខាតយោងទៅមុខពីការិយបរិច្ឆេទមុនៗដែលការខាតទាំងនោះអាចប្រើប្រាស់សម្រាប់កាត់កងប្រាក់ចំណូលជាប់ពន្ធក្នុងការិយបរិច្ឆេទ ហើយការខាតបង់ដែលនៅសល់ត្រូវយោងទៅឆ្នាំជាប់ពន្ធបន្ទាប់។

លទ្ធផលខាតសារពើពន្ធក្នុងឆ្នាំជាប់ពន្ធ ត្រូវចាត់ទុកថាជាបន្ទុកសម្រាប់ឆ្នាំជាប់ពន្ធបន្ទាប់ ហើយត្រូវកាត់ចេញពីប្រាក់ចំណូលជាប់ពន្ធសម្រេចបាននៅក្នុងឆ្នាំបន្ទាប់នោះ។ បើប្រាក់ចំណូលនេះមិនគ្រប់គ្រាន់សម្រាប់ទូទាត់ ចំណែកនៃការខាតបង់ដែលនៅសេសសល់ ត្រូវយោងទៅឆ្នាំជាប់ពន្ធបន្តបន្ទាប់រហូតដល់ឆ្នាំជាប់ពន្ធទី៥។

| ខ្លឹមសារនៅក្នុងលិខិតប្រកាស | សេចក្ដីពន្យល់ |
|---|---|
| **ការិយបរិច្ឆេទ÷** | គឺជាការិយបរិច្ឆេទនៃឆ្នាំជាប់ពន្ធ។ |
| **(1)- លទ្ធផលចំណេញសារពើពន្ធ÷** | គឺជាចំនួនទឹកប្រាក់ចំណូលសុទ្ធ ដែលជាលទ្ធផលសារពើពន្ធកើតមានក្នុងឆ្នាំនីមួយៗ ដែលយកចេញពីប្រអប់ **"E40: ប្រាក់ចំណូលសុទ្ធ/(ខាត) ក្នុងការិយបរិច្ឆេទ"**។ |
| **(2)- លទ្ធផលខាតសារពើពន្ធក្នុងការិយបរិច្ឆេទ÷** | គឺជាចំនួនទឹកប្រាក់ខាត ដែលជាលទ្ធផលសារពើពន្ធកើតមានក្នុងឆ្នាំនីមួយៗ ដែលយកចេញពីប្រអប់ **"E40: ប្រាក់ចំណូលសុទ្ធ/(ខាត) ក្នុងការិយបរិច្ឆេទ"**។ |
| **(3)- ខាតអនុញ្ញាតប្រើប្រាស់កាត់កងក្នុងការិយបរិច្ឆេទ÷** | គឺជាការខាតសារពើពន្ធ ដែលអនុញ្ញាតឱ្យប្រើប្រាស់កាត់កងជាមួយប្រាក់ចំណូលជាប់ពន្ធក្នុងឆ្នាំជាប់ពន្ធចរន្ត។ |
| **(4)- ខាតអនុញ្ញាតប្រើប្រាស់កាត់កងបូកបន្ត÷** | គឺជាការខាតសារពើពន្ធសរុប បានប្រើប្រាស់កាត់កងជាមួយប្រាក់ចំណូលជាប់ពន្ធក្នុងឆ្នាំជាប់ពន្ធមុនៗ និងឆ្នាំជាប់ពន្ធចរន្ត។ |
| **(5)- ខាតនៅសល់អនុញ្ញាតប្រើប្រាស់យោងទៅមុខ ÷** | គឺជាសមតុល្យរវាង **"(2) លទ្ធផលខាតសារពើពន្ធក្នុងការិយបរិច្ឆេទ"** ដក **"(4) ខាតអនុញ្ញាតប្រើប្រាស់កាត់កងបូកបន្ត"**។<br>**កំណត់សម្គាល់÷** ក្ងឡោននេះគឺជាចំនួនទឹកប្រាក់ខាតសុទ្ធយោងទៅមុខសម្រាប់ឆ្នាំជាប់ពន្ធនីមួយៗ ប៉ុន្តែមិនមែនជាចំនួនទឹកប្រាក់ខាតសរុបបូកយោងទេ។ |

**ឧទាហរណ៍÷**

សហគ្រាស ក គឺជាអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស។ ចាប់តាំងពីឆ្នាំ២០១៤ សហគ្រាសនេះមានព័ត៌មាននៃលទ្ធផលសារពើពន្ធខាត និងចំណេញ សង្ខេបដូចខាងក្រោម:

| កាលបរិច្ឆេទ | លទ្ធផលខាតសារពើពន្ធ | លទ្ធផលចំណេញសារពើពន្ធ |
|---|---|---|
| 31-12-2014 | 3,000,000 | - |
| 31-12-2015 | - | 350,000 |
| 31-12-2016 | 250,000 | - |
| 31-12-2017 | - | 90,000 |
| 31-12-2018 | 50,000 | - |
| 31-12-2019 | - | 120,000 |
| 31-12-2020 | - | 2,000,000 |

*ការិយបរិច្ឆេទសារពើពន្ធគិតពីថ្ងៃទី០១ ខែមករា ដល់ថ្ងៃទី៣១ ខែធ្នូ សហគ្រាសអាចប្រើប្រាស់តារាងខាងក្រោមនេះសម្រាប់គណនា និងកត់ត្រាតាមដានលទ្ធផលខាតសារពើពន្ធយោង÷

## ១- គណនាលទ្ធផលសារពើពន្ធខាតយោងឆ្នាំ២០១៥

| ការិយបរិច្ឆេទ | លទ្ធផលចំណេញសារពើពន្ធ | លទ្ធផលខាតសារពើពន្ធក្នុងការិយបរិច្ឆេទ | ខាតអនុញ្ញាតប្រើប្រាស់កាត់កងក្នុងការិយបរិច្ឆេទ | ខាតអនុញ្ញាតប្រើប្រាស់កាត់កងបូកបន្ត | ខាតនៅសល់អនុញ្ញាតប្រើប្រាស់យោងទៅមុខ |
|---|---|---|---|---|---|
| | (1) | (2) | (3) | (4) | (5) = (2) - (4) |
| ឆ្នាំ N-1 (2014) | - | 3,000,000 | 350,000 | 350,000 | 2,650,000 |
| ឆ្នាំ N (2015) | 350,000 | - | - | - | - |

## ២- គណនាលទ្ធផលសារពើពន្ធខាតយោងឆ្នាំ២០១៦

| ការិយបរិច្ឆេទ | លទ្ធផលចំណេញសារពើពន្ធ | លទ្ធផលខាតសារពើពន្ធក្នុងការិយបរិច្ឆេទ | ខាតអនុញ្ញាតប្រើប្រាស់កាត់កងក្នុងការិយបរិច្ឆេទ | ខាតអនុញ្ញាតប្រើប្រាស់កាត់កងបូកបន្ត | ខាតនៅសល់អនុញ្ញាតប្រើប្រាស់យោងទៅមុខ |
|---|---|---|---|---|---|
| | (1) | (2) | (3) | (4) | (5) = (2) - (4) |
| ឆ្នាំ N-2 (2014) | - | 3,000,000 | - | 350,000 | 2,650,000 |
| ឆ្នាំ N-1 (2015) | 350,000 | - | - | - | - |
| ឆ្នាំ N (2016) | - | 250,000 | - | - | 250,000 |

## ៣- គណនាលទ្ធផលសារពើពន្ធខាតយោងឆ្នាំ២០១៧

| ការិយបរិច្ឆេទ | លទ្ធផលចំណេញសារពើពន្ធ | លទ្ធផលខាតសារពើពន្ធក្នុងការិយបរិច្ឆេទ | ខាតអនុញ្ញាតប្រើប្រាស់កាត់កងក្នុងការិយបរិច្ឆេទ | ខាតអនុញ្ញាតប្រើប្រាស់កាត់កងបូកបន្ត | ខាតនៅសល់អនុញ្ញាតប្រើប្រាស់យោងទៅមុខ |
|---|---|---|---|---|---|
| | (1) | (2) | (3) | (4) | (5) = (2) - (4) |
| ឆ្នាំ N-3 (2014) | - | 3,000,000 | 90,000 | 440,000 | 2,560,000 |
| ឆ្នាំ N-2 (2015) | 350,000 | - | - | - | - |
| ឆ្នាំ N-1 (2016) | - | 250,000 | - | - | 250,000 |
| ឆ្នាំ N (2017) | 90,000 | - | - | - | - |

## ៤- គណនាលទ្ធផលសារពើពន្ធខាតយោងឆ្នាំ២០១៨

| ការិយបរិច្ឆេទ | លទ្ធផលចំណេញសារពើពន្ធ | លទ្ធផលខាតសារពើពន្ធក្នុងការិយបរិច្ឆេទ | ខាតអនុញ្ញាតប្រើប្រាស់កាត់កងក្នុងការិយបរិច្ឆេទ | ខាតអនុញ្ញាតប្រើប្រាស់កាត់កងបូកបន្ត | ខាតនៅសល់អនុញ្ញាតប្រើប្រាស់យោងទៅមុខ |
|---|---|---|---|---|---|
| | (1) | (2) | (3) | (4) | (5) = (2) - (4) |
| ឆ្នាំ N-4 (2014) | - | 3,000,000 | - | 440,000 | 2,560,000 |
| ឆ្នាំ N-3 (2015) | 350,000 | - | - | - | - |
| ឆ្នាំ N-2 (2016) | - | 250,000 | - | - | 250,000 |
| ឆ្នាំ N-1 (2017) | 90,000 | - | - | - | - |
| ឆ្នាំ N (2018) | - | 50,000 | - | - | 50,000 |

## ៥- គណនាលទ្ធផលសារពើពន្ធខាតយោងឆ្នាំ២០១៩

| ការិយបរិច្ឆេទ | លទ្ធផល ចំណេញសារពើពន្ធ | លទ្ធផលខាត សារពើពន្ធក្នុង ការិយបរិច្ឆេទ | ខាតអនុញ្ញាត ប្រើប្រាស់កាត់កងក្នុង ការិយបរិច្ឆេទ | ខាតអនុញ្ញាតប្រើ ប្រាស់កាត់កង បូកបន្ត | ខាតនៅសល់ អនុញ្ញាតប្រើប្រាស់ យោងទៅមុខ |
|---|---|---|---|---|---|
| | (1) | (2) | (3) | (4) | (5) = (2) - (4) |
| ឆ្នាំ N-5 (2014) | - | 3,000,000 | 120,000 | 560,000 | 2,440,000 |
| ឆ្នាំ N-4 (2015) | 350,000 | - | - | - | - |
| ឆ្នាំ N-3 (2016) | - | 250,000 | - | | 250,000 |
| ឆ្នាំ N-2 (2017) | 90,000 | - | - | - | - |
| ឆ្នាំ N-1 (2018) | - | 50,000 | - | - | 50,000 |
| ឆ្នាំ N (2019) | 120,000 | - | - | - | - |

## ៦- គណនាលទ្ធផលសារពើពន្ធខាតយោងឆ្នាំ២០២០

| ការិយបរិច្ឆេទ | លទ្ធផល ចំណេញសារពើពន្ធ | លទ្ធផលខាត សារពើពន្ធក្នុង ការិយបរិច្ឆេទ | ខាតអនុញ្ញាត ប្រើប្រាស់កាត់កងក្នុង ការិយបរិច្ឆេទ | ខាតអនុញ្ញាតប្រើ ប្រាស់កាត់កង បូកបន្ត | ខាតនៅសល់ អនុញ្ញាតប្រើប្រាស់ យោងទៅមុខ |
|---|---|---|---|---|---|
| | (1) | (2) | (3) | (4) | (5) = (2) - (4) |
| ~~ឆ្នាំ N-6 (2014)~~ | - | ~~3,000,000~~ | - | ~~560,000~~ | ~~2,440,000~~ |
| ឆ្នាំ N-5 (2015) | 350,000 | - | - | - | - |
| ឆ្នាំ N-4 (2016) | - | 250,000 | 250,000 | 250,000 | - |
| ឆ្នាំ N-3 (2017) | 90,000 | - | - | - | - |
| ឆ្នាំ N-2 (2018) | - | 50,000 | 50,000 | 50,000 | - |
| ឆ្នាំ N-1 (2019) | - | 1,800,000 | 1,700,000 | 1,700,000 | 100,000 |
| ឆ្នាំ N (2020) | 2,000,000 | - | - | - | - |

### កំណត់សម្គាល់÷

- ខាតសារពើពន្ធចំនួន 2,440,000 រៀល ហួសសុពលភាពមិនអាចអនុញ្ញាតឱ្យកាត់កងហើយត្រូវដកចេញពីតារាង។
- ខាតសារពើពន្ធអាចយោងបានតែរយៈពេល ៥ឆ្នាំ តែប៉ុណ្ណោះ។

តារាងតាមដានលទ្ធផលសារពើពន្ធខាតយោងទៅមុខ នៅក្នុងលិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០។

| ការិយបរិច្ឆេទ | លទ្ធផល ចំណេញសារពើពន្ធ | លទ្ធផលខាត សារពើពន្ធក្នុង ការិយបរិច្ឆេទ | ខាតអនុញ្ញាត ប្រើប្រាស់កាត់កងក្នុង ការិយបរិច្ឆេទ | ខាតអនុញ្ញាតប្រើ ប្រាស់កាត់កង បូកបន្ត | ខាតនៅសល់ អនុញ្ញាតប្រើប្រាស់ យោងទៅមុខ |
|---|---|---|---|---|---|
| | (1) | (2) | (3) | (4) | (5) = (2) - (4) |
| ឆ្នាំ N-5 (2015) | 350,000 | - | - | - | - |
| ឆ្នាំ N-4 (2016) | - | 250,000 | 250,000 | 250,000 | - |
| ឆ្នាំ N-3 (2017) | 90,000 | - | - | - | - |
| ឆ្នាំ N-2 (2018) | - | 50,000 | 50,000 | 50,000 | - |
| ឆ្នាំ N-1 (2019) | - | 1,800,000 | 1,700,000 | 1,700,000 | 100,000 |
| ឆ្នាំ N (2020) | 2,000,000 | - | - | - | - |

## ទំព័រទី១៣ (TOI 01/IX)÷ តារាងគណនារំលស់តាមច្បាប់ស្តីពីសារពើពន្ធ

តារាងរំលស់តាមច្បាប់ស្តីពីសារពើពន្ធប្រើប្រាស់សម្រាប់គោលដៅគណនាពន្ធលើប្រាក់ចំណូល។ ទ្រព្យសកម្មរយៈពេលវែងអនុញ្ញាតឱ្យធ្វើរំលស់តាមវិធានដែលមានចែងក្នុងច្បាប់ស្តីពីសារពើពន្ធ។

**ខ្លឹមសារនៅក្នុងលិខិតប្រកាស** — **សេចក្តីពន្យល់**

**ទ្រព្យសកម្មរយៈពេលវែង÷**

ទ្រព្យសកម្មដែលបំពេញបានលក្ខណវិនិច្ឆ័យខាងក្រោមនេះ ត្រូវចាត់ថ្នាក់ជាទ្រព្យសកម្មរយៈពេលវែង÷

១- ទ្រព្យសកម្មរូបី ឬទ្រព្យសកម្មអរូបីដែលមិនទុកសម្រាប់បំលែង ឬសម្រាប់លក់បន្ត។

២- អាយុកាលប្រើប្រាស់ត្រូវលើសពី ១ ឆ្នាំ ដោយគិតចាប់ពីពេលដាក់ប្រើប្រាស់ដំបូង។

**ទ្រព្យអរូបី÷**

រួមមាន ចំណាយបង្កើតសហគ្រាស ចំណាយស្រាវជ្រាវនិងអភិវឌ្ឍន៍ ប្រកាសនីយបត្រ ពាណិជ្ជសញ្ញា អាជ្ញាប័ណ្ណ សម្បទាន កម្មវិធីកុំព្យូទ័រ (ចំណែកដែលមានច្បាប់ការពារ) មូលនិធិពាណិជ្ជកម្ម សិទ្ធិធ្វើអាជីវកម្ម ទ្រព្យសកម្មរយៈពេលវែងអរូបីផ្សេងទៀត។

ទ្រព្យសកម្មអរូបីនីមួយៗត្រូវធ្វើរំលស់តាមវិធីរំលស់ស្មើភាគ ទៅតាមអាយុកាលប្រើប្រាស់នៃទ្រព្យ ឬតាមអត្រា ១០ ភាគរយក្នុងមួយឆ្នាំប្រសិនបើមិនអាចកំណត់អាយុកាលប្រើប្រាស់បាន។

**កសិកម្មរយៈពេលវែង÷**

រួមមាន ដំណាំកសិកម្ម និងការចិញ្ចឹមសត្វ ដែលត្រូវរួមបញ្ចូលនូវចំណាយក្នុងការអភិវឌ្ឍ ចំណាយពាក់ព័ន្ធផ្ទាល់ជាមួយការដាំដុះ ឬចិញ្ចឹមសត្វ ចំណាយការប្រាក់ទាក់ទិននឹងការអភិវឌ្ឍ និងហេដ្ឋារចនាសម្ព័ន្ធដែលបម្រើឱ្យការដាំដុះ ឬចិញ្ចឹមសត្វ។

**ដំណាំកៅស៊ូ÷** អនុញ្ញាតឱ្យធ្វើរំលស់ក្នុងរយៈពេល ២០ឆ្នាំទៅតាមអត្រាកំណត់ដូចខាងក្រោម÷

| ឆ្នាំទទួលផល | អត្រារំលស់ |
|---|---|
| ឆ្នាំទី១ និងទី២ | ៣% |
| ឆ្នាំទី៣ និងទី៤ | ៤% |
| ឆ្នាំទី៥ ដល់ឆ្នាំទី១០ | ៥% |
| ឆ្នាំទី១១ និងទី១២ | ៧% |
| ឆ្នាំទី១៣ ដល់ឆ្នាំទី១៥ | ៦% |
| ឆ្នាំទី១៦ ដល់ឆ្នាំទី១៩ | ៥% |
| ឆ្នាំទី២០ | សមតុល្យនៅសល់ |

**ដំណាំកសិកម្មក្រៅពីកៅស៊ូ÷** អនុញ្ញាតឱ្យធ្វើរំលស់ស្មើភាគតាមអាយុកាលនៃការទទួលផល ឬ ៥ ភាគរយ ក្នុងមួយឆ្នាំ ដោយយកជ្រើសរើសជម្រើសណាមួយដែលឆាប់ជាង។

**ការចិញ្ចឹមសត្វ÷** អនុញ្ញាតឱ្យធ្វើរំលស់ស្មើភាគតាមអាយុកាលនៃការទទួលផល ឬ ១០ ភាគរយ ក្នុងមួយឆ្នាំ ដោយយកជ្រើសរើសជម្រើសណាមួយដែលឆាប់ជាង។

**ធនធានធម្មជាតិ÷**

- សម្រាប់ធនធានធម្មជាតិ ក្រៅពីប្រេងកាត និងរ៉ែ ត្រូវរួមបញ្ចូលនូវចំណាយនានាក្នុងការស្វែងរុករកនិងអភិវឌ្ឍន៍ រួមទាំងចំណាយការប្រាក់ទាក់ទិននឹងការស្វែងរុករកនិងអភិវឌ្ឍន៍។

  ទឹកប្រាក់រំលស់ដែលត្រូវបានអនុញ្ញាតឱ្យកាត់កងក្នុងឆ្នាំជាប់ពន្ធណាមួយ ត្រូវបានគណនាដោយយកសមតុល្យនៃគណនីធនធានធម្មជាតិ ទៅគុណនឹង ផលចែករវាងបរិមាណដែលផលិតបាននៅក្នុងឆ្នាំជាប់ពន្ធ និងចំនួនប៉ាន់ស្មាននៃផលិតផលសរុបដែលអាចទាញយកបានពីធនធាននោះ។

- សម្រាប់ធនធានរ៉ែ ត្រូវអនុវត្តតាមប្រកាសលេខ ៤៥៣ សហវ.ប្រក ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២០ ស្តីពីការណែនាំអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធលើប្រតិបត្តិការធនធានរ៉ែ។

- សម្រាប់ប្រេងកាត ត្រូវអនុវត្តតាមប្រកាសលេខ ៥៣៦ សហវ.ប្រក ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៨ ស្តីពីការណែនាំអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធលើប្រតិបត្តិការប្រេងកាត។

**ទ្រព្យរូបីថ្នាក់១÷** រួមមានសំណង់នានា រួមបញ្ចូលទាំងអគារ រចនាសម្ព័ន្ធអគារ និងសំណង់ដែលជាសមាសភាគនៃអគារ ផ្លូវថ្នល់ នានា។

**ទ្រព្យរូបីថ្នាក់១** ត្រូវធ្វើរំលស់ដោយឡែកពីគ្នាតាមវិធីរំលស់ស្មើភាគតាមអត្រា ៥ ភាគរយក្នុងមួយឆ្នាំនៃ បរិយាទានលទ្ធកម្ម(ថ្លៃដើម)។ ចំពោះអគារមិនមែនបេតុង ត្រូវធ្វើរំលស់ស្មើភាគតាមអត្រា ១០ ភាគរយក្នុងមួយឆ្នាំ។

**ទ្រព្យរូបីថ្នាក់២÷** រួមមាន កុំព្យូទ័រ ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ឧបករណ៍អេឡិចត្រូនិក និងបរិក្ខារទុកដាក់ទិន្នន័យ។

**ទ្រព្យរូបីថ្នាក់២** ត្រូវធ្វើរំលស់តាមវិធីរំលស់ថយចុះ ជាលំដាប់តាមអត្រា ៥០ ភាគរយ នៃមូលដ្ឋានរំលស់ក្នុងមួយឆ្នាំ។

**ទ្រព្យរូបីថ្នាក់៣÷** រួមមាន រថយន្ត រថយន្តដឹកទំនិញ គ្រឿងសង្ហារឹម និងបរិក្ខារការិយាល័យ។

**ទ្រព្យរូបីថ្នាក់៣** ត្រូវធ្វើរំលស់តាមវិធីរំលស់ថយចុះជាលំដាប់តាមអត្រា ២៥ ភាគរយ នៃមូលដ្ឋានរំលស់ក្នុងមួយឆ្នាំ ។

**ទ្រព្យរូបីថ្នាក់៤÷** រួមមាន រាល់គ្រប់ប្រភេទនៃទ្រព្យសកម្មរូបីដទៃផ្សេងៗទៀតក្រៅពីថ្នាក់ទី១ ទី២ និងទី៣។

**ទ្រព្យរូបីថ្នាក់៤** ត្រូវធ្វើរំលស់តាមវិធីរំលស់ថយចុះជាលំដាប់តាមអត្រា២០ ភាគរយ នៃមូលដ្ឋានរំលស់ក្នុងមួយឆ្នាំ ។

**វិធីសាស្ត្ររំលស់ស្មើភាគ÷** រំលស់តាមវិធីសាស្ត្រស្មើភាគ ត្រូវកាត់បន្ថយដាក់ជាចំណាយនូវតម្លៃនៃ ទ្រព្យសកម្មរយៈពេលវែងក្នុងចំនួនស្មើនិងអាយុកាលប្រើប្រាស់នៃទ្រព្យសកម្មរយៈពេលវែងនោះ ។

**ឧទាហរណ៍:** ប្រសិនបើ ទ្រព្យសកម្មរយៈពេលវែងមួយមានអាយុកាលប្រើប្រាស់រយៈពេល ២០ឆ្នាំតម្លៃនៃទ្រព្យសកម្មរយៈពេលវែងនោះត្រូវកាត់បន្ថយដាក់ជាចំណាយក្នុងចំនួនសរុបស្មើរយៈពេល ២០ឆ្នាំ។

រំលស់ត្រូវគណនាដោយយក“**តម្លៃនៃទ្រព្យសកម្មរយៈពេលវែង**” គុណនឹងអត្រារំលស់សម្រាប់ទ្រព្យសកម្មនោះ ។

**វិធីសាស្ត្ររំលស់ថយចុះជាលំដាប់÷** រំលស់ត្រូវគណនាដោយយក“**តម្លៃនៅសល់មិនទាន់រំលស់ (NBV) ដែលគណនាតាមច្បាប់ស្តីពីសារពើពន្ធ**” គុណនឹង“**អត្រារំលស់សម្រាប់ទ្រព្យសកម្មនោះ**”។

**ទ្រព្យសកម្មរយៈពេលវែងអរូបី កសិកម្មរយៈពេលវែង ធនធានធម្មជាតិចំពោះប្រេងកាត និងធនធានរ៉ែ និងទ្រព្យរូបីថ្នាក់១ (រំលស់តាមវិធីសាស្ត្រស្មើភាគ)÷**

**ថ្លៃដើមប្រវត្តិសាស្ត្រដើមគ្រា÷** គឺជាថ្លៃដើមទ្រព្យសកម្មនៅកាលបរិច្ឆេទទិញ បង្វែរចូល បង្កើត ឬដាក់បន្ថែម។ ថ្លៃដើមនៃទ្រព្យសកម្ម មិនត្រូវធ្វើនិយតកម្មដើម្បីផ្លាស់ប្តូរឱ្យទៅជាថ្លៃដើមចរន្តនៅកាលបរិច្ឆេទនៃការវាយតម្លៃពិសេសណាមួយនោះទេ។

**លទ្ធកម្ម បង្វែរចូល ការបង្កើត ឬដាក់បន្ថែមក្នុងការិយបរិច្ឆេទ÷** គឺជាថ្លៃដើមនៃទ្រព្យដែលបានទិញ ឬដែលមានសម្រាប់ប្រើប្រាស់ក្នុងឆ្នាំដោយរួមបញ្ចូលផងដែរនូវថ្លៃដើម នៃទ្រព្យសកម្មក្រោយពីដករំលស់ពិសេស (ចំពោះសហគ្រាស **គ.ល.ត** មិនជ្រើសរើសយករយៈពេលលើកលែងពន្ធលើប្រាក់ចំណូល)។

**ថ្លៃដើមទ្រព្យសកម្មដកចេញ ឬលក់ក្នុងក្នុងការិយបរិច្ឆេទ÷** គឺជាថ្លៃដើមនៃទ្រព្យដែលបានដកចេញ។ ថ្លៃដើមនេះត្រូវតែស្មើនឹងថ្លៃដើមប្រវត្តិសាស្ត្រនៅពេលទ្រព្យនោះត្រូវបានទិញ ឬថ្លៃដើមនៃទ្រព្យសកម្មត្រូវបានរំលស់ទាំងស្រុង។

**តម្លៃមូលដ្ឋានគិតរំលស់ក្នុងការិយបរិច្ឆេទ÷** គឺជាតម្លៃសម្រាប់គណនារំលស់អនុញ្ញាតជាចំណាយសម្រាប់ការិយបរិច្ឆេទ។ តម្លៃនៅក្នុងប្រអប់នេះត្រូវគណនាដោយយក“**ថ្លៃដើមប្រវត្តិសាស្ត្រ**” បូក“**ថ្លៃ**

| | |
|---|---|
| | **ដើមនៃទ្រព្យថ្មីដែលបានពីលទ្ធកម្ម បង្វែរចូល ការបង្កើត ឬដាក់បន្ថែម" ដក "ថ្លៃដើមនៃទ្រព្យសកម្ម ទ្រព្យដកចេញ ឬលក់ក្នុងការិយបរិច្ឆេទ"** (៤=១+២-៣)។ |
| **អត្រារំលស់÷** | គឺជាអត្រាសម្រាប់គណនារំលស់តាមច្បាប់ស្តីពីសារពើពន្ធ ដូចបានបញ្ជាក់ខាងលើ។ |
| **រំលស់សម្រាប់ការិយបរិច្ឆេទ÷** | គឺជាចំណាយរំលស់ដែលអនុញ្ញាតឱ្យកាត់កងក្នុងការិយបរិច្ឆេទ (៦=៤*៥) ដែលត្រូវយកទៅបំពេញក្នុងប្រអប់ **"E26: រំលស់អនុញ្ញាតតាមច្បាប់ស្តីពីសារពើពន្ធ"**។ |
| **តម្លៃរំលស់បូកយោងពីការិយបរិច្ឆេទមុន÷** | គឺជាចំណាយរំលស់បូកយោងសរុប ដែលបានគណនាគិតចាប់ពីពេលទទួលបាន ឬប្រើប្រាស់ទ្រព្យសកម្មរយៈពេលវែងរហូតដល់ចុងគ្រានៃឆ្នាំជាប់ពន្ធមុន (N-1) ។ |
| **រំលស់បូកយោងទ្រព្យដែលបានលក់-ដកចេញ÷** | គឺជាចំណាយរំលស់បូកយោងសរុបនៃទ្រព្យសកម្មដែលបានលក់ ឬដកចេញនោះ ដោយគណនា គិតចាប់ពីពេលទទួលបាន ឬប្រើប្រាស់ទ្រព្យសកម្ម រហូតដល់ឆ្នាំដែលទ្រព្យសកម្មត្រូវបានដកចេញ។<br>**កំណត់សម្គាល់÷** មិនត្រូវគណនាចំណាយរំលស់ក្នុងការិយបរិច្ឆេទចំពោះទ្រព្យសកម្មដែលត្រូវបានបញ្ចេញចោលក្នុងការិយបរិច្ឆេទនោះ។ |
| **តម្លៃរំលស់បូកយោងនៅចុងការិយបរិច្ឆេទ÷** | គឺជាតម្លៃនៃរំលស់បូកយោងសរុបបានគណនាចាប់ពីពេលទទួលបាន ឬប្រើប្រាស់ទ្រព្យសកម្មរយៈពេលវែងរហូតដល់ចុងឆ្នាំជាប់ពន្ធចរន្ត (ឆ្នាំ N) "ចុងឆ្នាំចរន្ត" (៩=៦+៧-៨)។ |
| **តម្លៃនៅសល់មិនទាន់រំលស់នៅចុងការិយបរិច្ឆេទ÷** | គឺជាតម្លៃនៅសល់មិនទាន់រំលស់ (Net Book Value) តាមច្បាប់ស្តីពីសារពើពន្ធនៅចុងការិយបរិច្ឆេទ (១០=៤-៩)។ |

**ទ្រព្យរូបីថ្នាក់២ ដល់ថ្នាក់៤ (រំលស់ថយចាលំដាប់)÷**

| | |
|---|---|
| **ថ្លៃដើមប្រវត្តិសាស្ត្រ÷** | គឺជាថ្លៃដើមទ្រព្យសកម្មនៅកាលបរិច្ឆេទមុន ហើយរួមបញ្ចូលទាំងទ្រព្យសកម្មបានទិញ បង្វែរចូល បង្កើត ឬដាក់បន្ថែម ហើយដកចេញនូវថ្លៃដើមទ្រព្យសកម្មដែលបានលក់ ឬដកចេញ។ ថ្លៃដើមនៃទ្រព្យសកម្មមិនត្រូវធ្វើនិយតកម្មដើម្បីផ្លាស់ប្តូរឱ្យទៅជាថ្លៃដើមចរន្ត នៅកាលបរិច្ឆេទនៃការវាយតម្លៃពិសេសណាមួយនោះទេ។ |
| **តម្លៃនៅសល់មិនទាន់រំលស់នៅដើមនៅដើមការិយបរិច្ឆេទ÷** | គឺជាតម្លៃនៅសល់មិនទាន់រំលស់ (NBV) តាមច្បាប់ស្តីពីសារពើពន្ធនៅដើមការិយបរិច្ឆេទ ឬតម្លៃនៅសល់មិនទាន់រំលស់នៅចុងការិយបរិច្ឆេទឆ្នាំ (N-1)។ |
| **លទ្ធកម្ម បង្វែរចូល ការបង្កើត ឬដាក់បន្ថែមក្នុងការិយបរិច្ឆេទ÷** | គឺជាថ្លៃដើមនៃទ្រព្យដែលបានទិញ ឬដែលមានសម្រាប់ប្រើប្រាស់ក្នុងឆ្នាំដោយរួមបញ្ចូលផងដែរនូវថ្លៃដើមនៃទ្រព្យសកម្មក្រោយពីដករំលស់ពិសេស។ |

| | |
|---|---|
| **ការដកចេញ ឬលក់ក្នុងការិយបរិច្ឆេទ÷** | ត្រូវកត់ត្រាចំនួនទឹកប្រាក់ដែលបានទទួលពីការលក់ ឬដកចេញនៃទ្រព្យសកម្ម។ វិធីសាស្ត្រនេះ ទ្រព្យសកម្មត្រូវដាក់ចូលតាមថ្នាក់ (Pool Assets)។ |
| **តម្លៃមូលដ្ឋានគិតរំលស់ក្នុងការិយបរិច្ឆេទ÷** | គឺជាតម្លៃសម្រាប់គណនារំលស់ ដែលអនុញ្ញាតឱ្យកាត់កងក្នុងការិយបរិច្ឆេទ។ ទ្រព្យរូបីថ្នាក់ទី២ ទី៣ និងទី៤ តម្លៃនៅក្នុងប្រអប់នេះត្រូវគណនាដោយយក **"តម្លៃនៅសល់មិនទាន់រំលស់នៅដើមការិយបរិច្ឆេទ"** បូក **"ថ្លៃដើមនៃទ្រព្យសកម្មថ្មីទទួលបាន"** ដក **"ផលពីការលក់ ឬដកចេញទ្រព្យសកម្ម"** (៥=២+៣-៤)។ |
| **អត្រារំលស់÷** | គឺជាអត្រាសម្រាប់គណនារំលស់តាមច្បាប់ស្តីពីសារពើពន្ធក្នុងនោះ÷<br>- ទ្រព្យរូបីថ្នាក់ ២ រំលស់តាមអត្រា ៥០ ភាគរយ។<br>- ទ្រព្យរូបីថ្នាក់ ៣ រំលស់តាមអត្រា ២៥ ភាគរយ។<br>- ទ្រព្យរូបីថ្នាក់ ៤ រំលស់តាមអត្រា ២០ ភាគរយ។ |
| **ទឹកប្រាក់រំលស់សម្រាប់ការិយបរិច្ឆេទ÷** | គឺជាចំណាយរំលស់ដែលអនុញ្ញាតឱ្យកាត់កងក្នុងការិយបរិច្ឆេទ (៧=៥*៦)។ |
| **តម្លៃនៅសល់មិនទាន់រំលស់នៅចុងការិយបរិច្ឆេទ÷** | គឺជាតម្លៃនៅសល់មិនទាន់រំលស់តាមច្បាប់ស្តីពីសារពើពន្ធ នៅចុងការិយបរិច្ឆេទ (៨=៥-៧)។ |

## ទំព័រទី១៤ (TOI 01/X)÷ តារាងគណនារំលស់ពិសេសតាមច្បាប់ស្តីពីសារពើពន្ធ

| ខ្លឹមសារនៅក្នុងលិខិតប្រកាស | សេចក្តីពន្យល់ |
|---|---|
| ទ្រព្យសកម្មរូបីរយៈពេលវែង<br>ទ្រព្យរូបីថ្នាក់ ១<br>ទ្រព្យរូបីថ្នាក់ ២<br>ទ្រព្យរូបីថ្នាក់ ៣<br>ទ្រព្យរូបីថ្នាក់ ៤ | សូមមើលសេចក្តីពន្យល់នៅក្នុងទំព័រ ៤៤-៤៦ |
| **ប្រភេទនៃទ្រព្យរូបីរយៈពេលវែង÷** | ត្រូវកត់ត្រាទ្រព្យសកម្មរយៈពេលវែងទាំងអស់ក្នុងថ្នាក់នីមួយៗឱ្យបានត្រឹមត្រូវ។ |
| **ថ្លៃដើមទ្រព្យសកម្មរយៈពេលវែងគ្រាដំបូង÷** | មានន័យដូចគ្នា **"ថ្លៃដើមប្រវត្តិសាស្ត្រ"**។ សូមមើលសេចក្តីពន្យល់នៅក្នុង (ទំព័រ ៤៧)។ |
| **រំលស់ពិសេសក្នុងការិយបរិច្ឆេទតាមអត្រា 40%÷** | គឺជារំលស់ដែលអាចកាត់កងបានតែក្នុងឆ្នាំទីមួយ នៃទ្រព្យសកម្មដែលទទួលបាន/ទិញ ឬទ្រព្យសកម្មកំពុងប្រើប្រាស់។<br><br>រំលស់ពិសេសនេះត្រូវគណនាដោយយក "ថ្លៃដើមនៃទ្រព្យសកម្ម" គុណនឹង "អត្រា ៤០ ភាគរយ"។<br><br>**កំណត់សម្គាល់÷** រំលស់ពិសេសអនុញ្ញាតបានចំពោះតែ÷<br>- **គ.ល.គ.** ដែលមិនបានជ្រើសរើសយកសិទ្ធិទទួលបានការលើកលែងពន្ធលើប្រាក់ចំណូល។<br>- តម្លៃមូលធននៃទ្រព្យរូបីថ្មី ឬទ្រព្យរូបីប្រើប្រាស់រួចដែលបានដាក់ប្រើប្រាស់ក្នុងផលិតកម្ម និងការកែច្នៃ។ |
| **តម្លៃនៅសល់មិនទាន់រំលស់នៅចុងការិយបរិច្ឆេទផ្ទេរទៅ TOI 01/IX÷** | គឺជាតម្លៃនៅសល់មិនទាន់រំលស់នៅចុងការិយបរិច្ឆេទ។ តម្លៃនៅសល់មិនទាន់រំលស់នៅចុងការិយបរិច្ឆេទនេះត្រូវផ្ទេរទៅដាក់នៅក្នុង TOI 01/IX ឆ្នាំជាប់ពន្ធបន្ទាប់។ |

# ទំព័រទី១៥ (TOI 01/XI)÷ តារាងតម្លៃលើសឬខ្វះពីការលក់ ឬដកចេញនូវទ្រព្យសកម្មរយៈពេលវែងតាមច្បាប់ស្តីពីសារពើពន្ធ

| ខ្លឹមសារនៅក្នុងលិខិតប្រកាស | សេចក្តីពន្យល់ |
|---|---|
| **កាលបរិច្ឆេទទិញ/ លទ្ធកម្ម÷** | កាលបរិច្ឆេទជាក់ស្តែងនៃការទិញ/ ទទួលបាននូវទ្រព្យសកម្ម។ ជាធម្មតា កាលបរិច្ឆេទនេះគឺជាថ្ងៃមានដាក់នៅក្នុងវិក្កយបត្រទិញ។ |
| **កាលបរិច្ឆេទលក់/ ដកចេញ÷** | ត្រូវកត់ត្រាកាលបរិច្ឆេទជាក់ស្តែងនៃការលក់/ ដកចេញទ្រព្យសកម្ម។ |
| **ថ្ងៃដើមប្រវត្តិសាស្ត្រ÷** | សូមមើលក្នុង TOI 01/IX (ទំព័រ៤៧) |
| **រំលស់បូកយោង÷** | គឺជាចំណាយរំលស់បូកយោងសរុបបានគណនា គិតចាប់ពីពេលទទួលបានទ្រព្យសកម្មរយៈពេលវែងរហូតដល់ចុងនៃការិយបរិច្ឆេទ។ |
| **តម្លៃនៅសល់÷** | គឺជាតម្លៃនៅសល់មិនទាន់រំលស់តាមច្បាប់ស្តីពីសារពើពន្ធ។ |
| **ផលពីការដកចេញ ឬលក់÷** | គឺជាចំនួនទឹកប្រាក់បានទទួល ឬត្រូវទទួលពីការដកចេញ ឬលក់ទ្រព្យសកម្មរយៈពេលវែង។ |
| **តម្លៃលើសឬខ្វះ÷** | គឺជាតម្លៃលម្អៀងរវាង “**តម្លៃនៅសល់មិនទាន់រំលស់តាមច្បាប់ស្តីពីសារពើពន្ធ**” និង “**តម្លៃនៃការលក់ទ្រព្យសកម្ម**”។<br>- ប្រសិនបើ “**តម្លៃនៅសល់មិនទាន់រំលស់តាមច្បាប់ស្តីពីសារពើពន្ធ**” ធំជាង “**តម្លៃនៃការលក់ទ្រព្យសកម្ម**” ខាតពីការលក់ទ្រព្យសកម្មរយៈពេលវែងនឹងកើតមានឡើង។<br>- ប្រសិនបើ “**តម្លៃនៅសល់មិនទាន់រំលស់តាមច្បាប់ស្តីពីសារពើពន្ធ**” តូចជាង “**តម្លៃនៃការលក់ទ្រព្យសកម្ម**” ចំណេញពីការលក់ទ្រព្យសកម្មរយៈពេលវែងនឹងកើតមានឡើង។ |
| **ដីធ្លី÷** | គឺជាដីធ្លីដែលជាកម្មសិទ្ធិរបស់សហគ្រាស។ |
| ទ្រព្យសកម្មអរូបី<br>កសិកម្ម និងធនធានធម្មជាតិ<br>ទ្រព្យរូបីថ្នាក់ ១<br>ទ្រព្យរូបីថ្នាក់ ២<br>ទ្រព្យរូបីថ្នាក់ ៣<br>ទ្រព្យរូបីថ្នាក់ ៤ | សូមមើលក្នុង TOI 01/IX (ទំព័រ ៤៤-៤៦) |

## ទំព័រទី១៦ (TOI 01/XII)៖ តារាងគណនាសំវិធានធន

| ខ្លឹមសារនៅក្នុងលិខិតប្រកាស | សេចក្តីពន្យល់ |
|---|---|
| **ប្រភេទសំវិធានធន "បញ្ជាក់ប្រភេទសំវិធានធនមួយៗ"៖** | ត្រូវរាយលម្អិតប្រភេទនីមួយៗនៃសំវិធានធន។ |
| **សំវិធានធននៅដើមការិយបរិច្ឆេទ៖** | ត្រូវកត់ត្រាចំនួនទឹកប្រាក់ "**សំវិធានធននៅដើមការិយបរិច្ឆេទ**" សម្រាប់ប្រភេទនីមួយៗនៃសំវិធានធន។ |
| **ការកើនឡើងនូវសំវិធានធនក្នុងការិយបរិច្ឆេទ៖** | ត្រូវកត់ត្រាចំនួនទឹកប្រាក់នៃសំវិធានធនដែលបានបន្ថែមក្នុងឆ្នាំជាប់ពន្ធ។ |
| **ការថយចុះនូវសំវិធានធនក្នុងការិយបរិច្ឆេទ៖** | ត្រូវកត់ត្រាចំនួនទឹកប្រាក់នៃសំវិធានធនដែលថយចុះក្នុងឆ្នាំជាប់ពន្ធ។ |
| **សមតុល្យនៃសំវិធានចុងការិយបរិច្ឆេទ៖** | ត្រូវគណនាដោយយក "**សមតុល្យនៃសំវិធានដើមការិយបរិច្ឆេទ**" បូក "**ការកើនឡើងនូវសំវិធានធនក្នុងការិយបរិច្ឆេទ**" ដក "**ការថយចុះនូវសំវិធានធនក្នុងការិយបរិច្ឆេទ**"។ |

**កំណត់សម្គាល់៖** ចំនួនទឹកប្រាក់សុទ្ធបានមកពីការទូទាត់រវាងការកើនឡើង និងការថយចុះនូវសំវិធានធននៅក្នុងការិយបរិច្ឆេទ ត្រូវស្មើនឹងទឹកប្រាក់នៅក្នុងប្រអប់ "**B37: ការកើនឡើង/ថយចុះនូវសំវិធានធន**" ក្នុង TOI 01/IV។

# ឧបសម្ព័ន្ធ ១÷ តារាងប្រតិបត្តិការជាមួយបុគ្គលទាក់ទិន

យោងតាមប្រការ ១៨ កថាខណ្ឌ ៣ នៃប្រកាសលេខ ៩៨៦ សហវ.ប្រក ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៧ ស្តីពីវិធាន និងនីតិវិធីសម្រាប់បែងចែកចំណូលនិងចំណាយក្នុងចំណោមបុគ្គលទាក់ទិន អ្នកជាប់ពន្ធត្រូវបានឱ្យបំពេញក្នុងលិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ អំពីព័ត៌មានមួយចំនួនពាក់ព័ន្ធនឹងប្រតិបត្តិការក្នុងចំណោមបុគ្គលទាក់ទិន។

| ខ្លឹមសារនៅក្នុងលិខិតប្រកាស | សេចក្តីពន្យល់ |
|---|---|
| **ការិយបរិច្ឆេទ÷** | ការិយបរិច្ឆេទ គឺជាឆ្នាំជាប់ពន្ធ (ដូចគ្នាទៅនឹងឆ្នាំដាក់លិខិតប្រកាសពន្ធប្រចាំឆ្នាំ) |
| **ឈ្មោះសហគ្រាស÷** | គឺជាឈ្មោះរបស់សហគ្រាស ដែលបង្ហាញនៅលើវិញ្ញាបនបត្រចុះបញ្ជីពន្ធដារ ចេញដោយរដ្ឋបាលសារពើពន្ធ។ |
| **ឈ្មោះអក្សរឡាតាំង÷** | គឺជាឈ្មោះរបស់សហគ្រាសជាអក្សរឡាតាំង ដែលបង្ហាញនៅលើវិញ្ញាបនបត្រចុះបញ្ជីពន្ធដារ។ |
| **លេខអត្តសញ្ញាណកម្មសារពើពន្ធ÷** | គឺជាលេខអត្តសញ្ញាណកម្មសារពើពន្ធ របស់សហគ្រាសដែលមាននៅវិញ្ញាបនបត្រចុះបញ្ជីពន្ធដារ។ |
| **ល.រ÷** | គឺជាលេខរៀងសម្គាល់លំដាប់។ |
| **ឈ្មោះបុគ្គលទាក់ទិន÷** | ត្រូវកត់ត្រារាយលម្អិតឈ្មោះបុគ្គលទាក់ទិន។ |
| **ប្រទេសដែលបុគ្គលទាក់ទិនបានចុះបញ្ជី÷** | គឺជាប្រទេស/ដែនដី ដែលបុគ្គលទាក់ទិនបានចុះបញ្ជី ឬជានិវាសនជន។ |
| **បរិយាយពីលក្ខណៈនិងប្រភេទប្រតិបត្តិការ÷** | គឺជាការបរិយាយដោយសង្ខេបពីលក្ខណៈ នៃទំនាក់ទំនងរវាងសហគ្រាសនិងបុគ្គលទាក់ទិន និងប្រភេទប្រតិបត្តិការដែលមានជាមួយបុគ្គលទាក់ទិនក្នុងឆ្នាំ ដោយធ្វើការញែករវាង÷<br>ក. ប្រតិបត្តិការចំណូល/លក់<br>ខ. ប្រតិបត្តិការចំណាយ/ទិញ<br>គ. កម្ចីផ្តល់ឱ្យបុគ្គលទាក់ទិន<br>ឃ. កម្ចីទទួលពីបុគ្គលទាក់ទិន |
| **ចំនួនទឹកប្រាក់ (រៀល)÷** | គឺជាចំនួនទឹកប្រាក់នៃប្រតិបត្តិការជាមួយបុគ្គលទាក់ទិនតាមប្រភេទប្រតិបត្តិការនីមួយៗ។ |
| **អត្រាការប្រាក់ (%)÷** | គឺជាអត្រាការប្រាក់សម្រាប់កម្ចីដែលផ្តល់ឱ្យ ឬទទួលពីបុគ្គលទាក់ទិន។ |
| **ឯកសារផ្ទេរថ្លៃ÷** | ប្រសិនបើសហគ្រាសបាន ឬមិនបានរៀបចំ និងរក្សាទុកឯកសារផ្ទេរថ្លៃសូមគូស √ នៅក្នុងប្រអប់ □បាន / ប្រអប់ □មិនបាន។ |

# ឧបសម្ព័ន្ធ ២៖ បញ្ជីឈ្មោះនៃទ្រព្យសកម្មរយៈពេលវែង

| ខ្លឹមសារនៅក្នុងលិខិតប្រកាស | សេចក្ដីពន្យល់ |
|---|---|
| **លេខអត្តសញ្ញាណកម្មសារពើពន្ធ៖** | គឺជាលេខអត្តសញ្ញាណកម្មសារពើពន្ធ របស់សហគ្រាសដែលមាននៅវិញ្ញាបនបត្រចុះបញ្ជីពន្ធដារ។ |
| **ឈ្មោះសហគ្រាស៖** | គឺជាឈ្មោះរបស់សហគ្រាស ដែលបង្ហាញនៅលើវិញ្ញាបនបត្រចុះបញ្ជីពន្ធដារចេញដោយរដ្ឋបាលសារពើពន្ធ។ |
| **ឆ្នាំជាប់ពន្ធ៖** | ឆ្នាំជាប់ពន្ធ (ដូចគ្នាទៅនឹងឆ្នាំដាក់លិខិតប្រកាសពន្ធប្រចាំឆ្នាំ)។ |
| **ទីស្នាក់ការកណ្ដាល៖** | ត្រូវកត់ត្រាទ្រព្យសកម្មដែលស្ថិតនៅ និងប្រើប្រាស់នៅទីស្នាក់ការកណ្ដាល។ |
| **សាខាសហគ្រាស៖** | ត្រូវកត់ត្រាទ្រព្យសកម្មដែលស្ថិតនៅ និងប្រើប្រាស់នៅសាខានីមួយៗដាច់ដោយឡែកពីគ្នាតាមលេខបារកូដសម្គាល់សាខា (ប្រសិនបើមាន)។ |
| **ថ្ងៃ ខែ ឆ្នាំ ទិញ៖** | គឺជាកាលបរិច្ឆេទនៃការទិញ/បង្វែរចូលទ្រព្យសកម្មរយៈពេលវែង។ |
| **ប្រភេទទ្រព្យសកម្មរយៈពេលវែង៖** | គឺជាការបរិយាយឈ្មោះទ្រព្យសកម្មរយៈពេលវែងនីមួយៗ។ |
| **ថ្លៃដើមប្រវត្តិសាស្ត្រនៅដើមគ្រា៖** | គឺជាតម្លៃប្រវត្តិសាស្ត្រដែលបានកត់ត្រា ចំពោះទ្រព្យសកម្មនីមួយៗដែលបានទិញ/បង្វែរចូលពីការិយបរិច្ឆេទមុនៗ។ |
| **លទ្ធកម្ម បង្វែរចូល បង្កើត ឬដាក់បន្ថែមក្នុងការិយបរិច្ឆេទ៖** | គឺជាថ្លៃដើមនៃទ្រព្យដែលបានទិញ ឬដែលមានសម្រាប់ប្រើប្រាស់ក្នុងឆ្នាំ។ |
| **ថ្លៃដើមទ្រព្យដកចេញ ឬលក់ក្នុងការិយបរិច្ឆេទ៖** | គឺជាថ្លៃដើមនៃទ្រព្យដែលបានដកចេញ។ ថ្លៃដើមនេះត្រូវតែស្មើនឹងថ្លៃដើមប្រវត្តិសាស្ត្រនៅពេលទ្រព្យនោះត្រូវបានទិញ ឬថ្លៃដើមនៃទ្រព្យសកម្មត្រូវបានរំលស់ទាំងស្រុង។ |
| **តម្លៃមូលដ្ឋានគិតរំលស់ ក្នុងការិយបរិច្ឆេទ៖** | គឺជាតម្លៃសម្រាប់គណនារំលស់ក្នុងការិយបរិច្ឆេទ។ តម្លៃនៅក្នុង ប្រអប់នេះត្រូវគណនាដោយយក “**(1): ថ្លៃដើមប្រវត្តិសាស្ត្រនៅដើមគ្រា**” បូក “**(2): លទ្ធកម្ម បង្វែរចូល បង្កើត ឬដាក់បន្ថែមក្នុងការិយបរិច្ឆេទ**” ដក “**(3): ថ្លៃដើមទ្រព្យដកចេញ ឬលក់ក្នុងការិយបរិច្ឆេទ**” (4=1+2-3)។ |

# ឧបសម្ព័ន្ធ ៣៖ ឧបសម្ព័ន្ធភ្ជាប់ជាមួយលិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ (សាខាសហគ្រាសក្នុងស្រុក)

| ខ្លឹមសារនៅក្នុងលិខិតប្រកាស | សេចក្តីពន្យល់ |
|---|---|
| **ការិយបរិច្ឆេទសារពើពន្ធ (ចំនួនខែ)៖** | សូមមើលសេចក្តីពន្យល់នៅក្នុងទំព័រ ៥។ |
| **១-លេខអត្តសញ្ញាណកម្មសារពើពន្ធ៖** | គឺជាលេខអត្តសញ្ញាណកម្មសារពើពន្ធ (TIN) ដែលមានបញ្ជាក់នៅលើវិញ្ញាបនបត្រចុះបញ្ជីពន្ធដារ។ |
| **២-លេខបារកូដសម្គាល់សាខា៖** | គឺជាលេខបារកូដសម្គាល់របស់សាខាសហគ្រាស ដែលបង្ហាញនៅលើលិខិតបញ្ជាក់សាខាសហគ្រាស ចេញដោយរដ្ឋបាលសារពើពន្ធ។ |
| **៣-ឈ្មោះសាខាសហគ្រាស៖** | គឺជាឈ្មោះរបស់សាខាសហគ្រាស ដែលបង្ហាញនៅលើលិខិតបញ្ជាក់សាខាសហគ្រាស ចេញដោយរដ្ឋបាលសារពើពន្ធ។ |
| **៤-ឈ្មោះសហគ្រាស (ការិយាល័យកណ្តាល)៖** | គឺជាឈ្មោះរបស់សហគ្រាស (ការិយាល័យកណ្តាល) ដែលបង្ហាញនៅលើលិខិតបញ្ជាក់សាខាសហគ្រាស ចេញដោយរដ្ឋបាលសារពើពន្ធ។ |
| **៥-ថ្ងៃខែឆ្នាំចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធជាសាខា៖** | គឺជាកាលបរិច្ឆេទ ដែលបង្ហាញនៅលើលិខិតបញ្ជាក់សាខាសហគ្រាសចេញដោយរដ្ឋបាលសារពើពន្ធ។ |
| **-ថ្ងៃខែឆ្នាំសុពលភាព លិខិតបញ្ជាក់សាខា៖** | គឺជាកាលបរិច្ឆេទសុពលភាព ដែលបង្ហាញនៅលើលិខិតបញ្ជាក់សាខាសហគ្រាស ចេញដោយរដ្ឋបាលសារពើពន្ធ។ |
| **៦-ឈ្មោះនាយកសាខាសហគ្រាស៖** | គឺជាឈ្មោះនៃអ្នកគ្រប់គ្រងរបស់សាខាសហគ្រាស ដែលបង្ហាញលើលិខិតបញ្ជាក់សាខាសហគ្រាស។ |
| **៧-សកម្មភាពអាជីវកម្មចម្បងរបស់សាខា៖** | គឺជាសកម្មភាពអាជីវកម្មចម្បងរបស់សាខាសហគ្រាស ដែលមានក្នុងលិខិតបញ្ជាក់សាខាសហគ្រាស។ |
| **៨-អាសយដ្ឋានសាខាបច្ចុប្បន្ន៖** | គឺជាអាសយដ្ឋានបច្ចុប្បន្ន ដែលមានក្នុងលិខិតបញ្ជាក់សាខាសហគ្រាស។ |
| **៩-អាសយដ្ឋានឃ្លាំងស្តុកវត្ថុធាតុដើម៖** | គឺជាអាសយដ្ឋានឃ្លាំងស្តុកវត្ថុធាតុដើម ឬទំនិញសំខាន់ៗរបស់សាខាសហគ្រាស។ |
| **១០-ការកត់ត្រាបញ្ជិកាគណនេយ្យ៖** | បើសាខាសហគ្រាសប្រើប្រាស់កម្មវិធីគណនេយ្យកុំព្យូទ័រ សូមគូស √ នៅក្នុងប្រអប់ □ **"ប្រើប្រាស់កម្មវិធីគណនេយ្យកុំព្យូទ័រ"** ដោយបញ្ជាក់ឈ្មោះកម្មវិធីគណនេយ្យកុំព្យូទ័រនៅក្នុងប្រអប់វែងខាងស្តាំ។ បើសាខាសហគ្រាសមិនបានប្រើប្រាស់កម្មវិធីគណនេយ្យកុំព្យូទ័រសូមគូស √ នៅក្នុងប្រអប់ □ **"មិនប្រើប្រាស់កម្មវិធីគណនេយ្យកុំព្យូទ័រ"**។ |
| **ឈ្មោះអ្នកគ្រប់គ្រង/ថ្នាក់ដឹកនាំសាខា៖** | ត្រូវកត់ត្រាឈ្មោះអ្នកគ្រប់គ្រងទាំងអស់ ដែលមានមុខងារជាថ្នាក់ដឹកនាំនៅក្នុងសាខាសហគ្រាស ។ |

| | |
|---|---|
| **សរុបបុគ្គលិក-កម្មករ÷** | ត្រូវកត់ត្រាចំនួនបុគ្គលិក-កម្មករសរុប ដែលមិនមានមុខងារជាអ្នកគ្រប់គ្រង នៅក្នុងសាខាសហគ្រាស។ |
| **បុគ្គលិក-កម្មករជាប់ពន្ធលើប្រាក់បៀវត្ស÷** | ត្រូវកត់ត្រាចំនួនបុគ្គលិក-កម្មករ ដែលមិនមានមុខងារជាអ្នកគ្រប់គ្រងនៅក្នុងសាខាសហគ្រាស ហើយដែលមានប្រាក់បៀវត្សប្រចាំខែដល់កម្រិតត្រូវជាប់ពន្ធលើប្រាក់បៀវត្សក្នុងឆ្នាំជាប់ពន្ធ។ |
| **តួនាទី÷** | កត់ត្រានូវមុខងាររបស់អ្នកគ្រប់គ្រងម្នាក់ៗដែលបានរាយលម្អិតនៅចំណុច ១ (ឈ្មោះអ្នកគ្រប់គ្រង/ថ្នាក់ដឹកនាំសាខា)។ |
| **ចំនួន÷** | - ចំពោះ "**បុគ្គលិក-កម្មករជាប់ពន្ធលើប្រាក់បៀវត្ស**" ត្រូវកត់ត្រាចំនួនសរុបបុគ្គលិកទាំងអស់ដែលមិនមែនជាអ្នកគ្រប់គ្រង នៅក្នុងសាខាសហគ្រាស ហើយដែលមានប្រាក់បៀវត្សត្រូវជាប់ពន្ធលើប្រាក់បៀវត្សក្នុងឆ្នាំជាប់ពន្ធ។<br>- ចំពោះ "**សរុបបុគ្គលិក-កម្មករ**" ត្រូវកត់ត្រាចំនួនបុគ្គលិក-កម្មករ ទាំងអស់ដែលមានមុខងារមិនមែនជាអ្នកគ្រប់គ្រងនៅក្នុងសាខាសហគ្រាស ហើយដែលមានប្រាក់បៀវត្សជាប់ពន្ធ និងមិនត្រូវជាប់ពន្ធលើប្រាក់បៀវត្ស។ |
| **ប្រាក់បៀវត្សក្រៅពីអត្ថប្រយោជន៍បន្ថែម÷** | - ចំពោះ "**អ្នកគ្រប់គ្រង/ថ្នាក់ដឹកនាំសាខា**" ត្រូវកត់ត្រាចំនួនទឹកប្រាក់សរុបដែលបានបើកឱ្យអ្នកគ្រប់គ្រងម្នាក់ៗ។<br>- ចំពោះ "**សរុបបុគ្គលិក-កម្មករ**" ត្រូវកត់ត្រាចូលចំនួនទឹកប្រាក់បៀវត្សសរុបបានបើកឱ្យបុគ្គលិក-កម្មករទាំងអស់ ដែលមានមុខងារមិនមែនជាអ្នកគ្រប់គ្រងនៅក្នុងសាខាសហគ្រាស។<br>- ចំពោះ "**បុគ្គលិក-កម្មករជាប់ពន្ធលើប្រាក់បៀវត្ស**" ត្រូវកត់ត្រាចូលចំនួនទឹកប្រាក់បៀវត្សសរុបបានបើកឱ្យបុគ្គលិកទាំងអស់ ដែលមិនមែនជាអ្នកគ្រប់គ្រងនៅក្នុងសាខាសហគ្រាស ហើយដែលមានប្រាក់បៀវត្សត្រូវជាប់ពន្ធលើប្រាក់បៀវត្សក្នុងឆ្នាំជាប់ពន្ធ។ |
| **អត្ថប្រយោជន៍បន្ថែម÷** | - ចំពោះ "**អ្នកគ្រប់គ្រង/ថ្នាក់ដឹកនាំសាខា**" ត្រូវកត់ត្រាចូលអត្ថប្រយោជន៍បន្ថែម ដែលបានផ្តល់ជូនអ្នកគ្រប់គ្រងម្នាក់ៗនៅក្នុងឆ្នាំជាប់ពន្ធ។<br>- ចំពោះ "**សរុបបុគ្គលិក-កម្មករ**" ត្រូវកត់ត្រាអត្ថប្រយោជន៍បន្ថែមសរុបដែលបានបើកឱ្យបុគ្គលិក-កម្មករ ទាំងអស់ដែលមានមុខងារមិនមែនជាអ្នកគ្រប់គ្រងនៅក្នុងសាខាសហគ្រាស។<br>- ចំពោះ "**បុគ្គលិក-កម្មករជាប់ពន្ធលើប្រាក់បៀវត្ស**" ត្រូវកត់ត្រាអត្ថប្រយោជន៍បន្ថែមសរុបដែលបានបើកឱ្យបុគ្គលិក-កម្មករទាំងអស់ ដែលមិនមែនជាអ្នកគ្រប់គ្រងនៅក្នុងសាខាសហគ្រាស ហើយដែលមានប្រាក់បៀវត្សត្រូវជាប់ពន្ធលើប្រាក់បៀវត្សក្នុងឆ្នាំជាប់ពន្ធ។ |

# ឧបសម្ព័ន្ធ ៣ (ត)÷ បញ្ជីឈ្មោះនៃគណនីចំណូល និងចំណាយ

| ខ្លឹមសារនៅក្នុងលិខិតប្រកាស | សេចក្តីពន្យល់ |
|---|---|
| **ការិយបរិច្ឆេទនេះ (N)÷** | ត្រូវកត់ត្រាចំនួនទឹកប្រាក់ក្នុងការិយបរិច្ឆេទចរន្ត។ |
| **ការិយបរិច្ឆេទមុន (N-1)÷** | ត្រូវកត់ត្រាចំនួនទឹកប្រាក់ក្នុងការិយបរិច្ឆេទមុន។ |
| **H0- ចំណូលប្រតិបត្តិការ÷** | គឺជាចំនួនសរុបនៃចំណូលប្រតិបត្តិការពីប្រអប់ "**H1: ការលក់ផលិតផល**" ដល់ប្រអប់ "**H4: ចំណូលដទៃទៀត**"។ |
| **H1- ការលក់ផលិតផល÷** | ត្រូវកត់ត្រាចំណូលសរុបពីការលក់ផលិតផលសម្រេច។ |
| **H2- ការលក់ទំនិញ÷** | ត្រូវកត់ត្រាចំណូលសរុបពីការលក់ទំនិញ។ |
| **H3- ការផ្គត់ផ្គង់សេវា÷** | គឺជាតម្លៃសរុបនៃការផ្គត់ផ្គង់សេវាជូនអតិថិជន។ |
| **H4- ចំណូលដទៃទៀត÷** | គឺជាតម្លៃសរុបនៃចំណូលផ្សេងៗទៀតក្រៅពីចំណូលនៅក្នុង **H1, H2,** និង **H3** ដែលសាខាសហគ្រាសទទួលបាន។ |
| **H5- ចំណាយប្រតិបត្តិការ÷** | ត្រូវកត់ត្រាតម្លៃសរុបនៃចំណាយប្រតិបត្តិការពីប្រអប់ "**H6: ចំណាយបៀវត្ស**" ដល់ប្រអប់ "**H16: ចំណាយផ្សេងៗ**"។ |
| **H6- ចំណាយបៀវត្ស÷** | គឺជាចំណាយបៀវត្សសរុបដែលបានទូទាត់ និងត្រូវទូទាត់ឱ្យដល់បុគ្គលិកបម្រើការងារឱ្យសាខាសហគ្រាស រួមទាំងចំណាយលើអត្ថប្រយោជន៍បន្ថែម។ |
| **H7- ចំណាយប្រេង ឧស្ម័ន អគ្គិសនី និងទឹក÷** | ត្រូវកត់ត្រាចំណាយថ្លៃប្រេង ឧស្ម័ន អគ្គិសនី ថាមពលផ្សេងៗ និងទឹក ដែលបានប្រើប្រាស់នៅក្នុងសាខាសហគ្រាស។ |
| **H8- ចំណាយធ្វើដំណើរ និងចំណាយស្នាក់នៅ÷** | ត្រូវកត់ត្រាចំណាយការធ្វើដំណើរ និងចំណាយស្នាក់នៅដែលសាខាសហគ្រាសបានចំណាយក្នុងសកម្មភាពបម្រើការងារ ដើម្បីជាប្រយោជន៍សាខាសហគ្រាស។ |
| **H9- ចំណាយដឹកជញ្ជូន÷** | ត្រូវកត់ត្រាចំណាយដឹកជញ្ជូនទាំងអស់ សម្រាប់សាខាសហគ្រាសដែលបានកើតឡើងក្នុងការិយបរិច្ឆេទ។ |
| **H10- ចំណាយលើការជួល÷** | ត្រូវកត់ត្រាចំណាយជួលទ្រព្យសកម្មទាំងអស់ ដែលកើតមានឡើងសម្រាប់សាខាសហគ្រាស ក្នុងការិយបរិច្ឆេទ។ |
| **H11- ចំណាយលើការថែទាំ និងជួសជុល÷** | ត្រូវកត់ត្រាចំណាយថែទាំ និងជួសជុលទាំងអស់ដែលកើតមានឡើងសម្រាប់សាខាសហគ្រាសក្នុងការិយបរិច្ឆេទ។ ចំណាយទាំងនេះរួមបញ្ចូលទាំងសម្ភារបន្ទាប់បន្សំគ្រឿងបន្លាស់ និងសេវាកម្មផ្សេងៗ។ |
| **H12- ចំណាយលើការកម្សាន្តសប្បាយ÷** | ត្រូវកត់ត្រាចំណាយទទួលភ្ញៀវ កម្សាន្តសប្បាយ សម្រាកលំហែផ្សេងៗទាំងអស់ ដែលកើតមានឡើងសម្រាប់សាខាសហគ្រាសក្នុងការិយបរិច្ឆេទ។ |

| | |
|---|---|
| **H13- ចំណាយកម្រៃជើងសា ផ្សាយពាណិជ្ជកម្ម និងចំណាយលើការលក់÷** | ត្រូវកត់ត្រាចំណាយទាំងឡាយ ដែលកើតមានឡើងសម្រាប់គោលដៅ បង្កើនកម្រិតនៃការលក់ផលិតផល/ទំនិញ និងសេវារបស់សាខាសហគ្រាស។ |
| **H14- ចំណាយសេវាគ្រប់គ្រង ពិគ្រោះយោបល់ បច្ចេកទេស និងសេវាប្រហាក់ប្រហែល÷** | ត្រូវកត់ត្រាចំណាយទាំងអស់ ដែលបានផ្តល់ទៅឱ្យទីប្រឹក្សាពិគ្រោះយោបល់ បច្ចេកទេស សេវាគ្រប់គ្រង និងសេវាប្រហាក់ប្រហែល ។ល។ ដែលកើតមានឡើងសម្រាប់សាខាសហគ្រាសនៅក្នុងការិយបរិច្ឆេទ។ |
| **H15- ចំណាយលើបំណុលទារមិនបាន÷** | ត្រូវកត់ត្រាបំណុលទារមិនបានពិតប្រាកដ ដែលបានលុបចេញពីបញ្ជីគណនេយ្យរបស់សាខាសហគ្រាស។ ប្រអប់នេះ មិនត្រូវកត់ត្រាការកើនឡើងសំវិធានធនបំណុលទារមិនបានទេ។ |
| **H16- ចំណាយផ្សេងៗ÷** | ត្រូវកត់ត្រាចំណាយផ្សេងៗដទៃទៀតទាំងអស់ នៅក្នុងរបាយការណ៍លទ្ធផលក្រៅពីចំណាយដែលបានបញ្ជាក់ខាងលើ។ |

# ឧបសម្ព័ន្ធ ៤÷ ពន្ធលើប្រាក់ចំណូលលើសកម្រិតលើប្រតិបត្តិការធនធានរ៉ែ / ប្រេងកាត

| ខ្លឹមសារនៅក្នុងលិខិតប្រកាស | សេចក្តីពន្យល់ |
|---|---|
| **X1- ប្រាក់ចំណូលជាប់ពន្ធ (E42) ÷** | ត្រូវកត់ត្រាដោយយកតួលេខពី TOI 01/VII **"E42: ប្រាក់ចំណូល/(ខាត) ជាប់ពន្ធសម្រាប់គណនាពន្ធលើប្រាក់ចំណូល"**។ |
| **X2- ចំណូលបង្គរ (ចំណូលប្តូកបន្ត) ÷** | ចំណូលបូកយោងដែលទទួលបានតាំងពីឆ្នាំជាប់ពន្ធដំបូង រហូតដល់ឆ្នាំជាប់ពន្ធចរន្តក្នុងបញ្ជីគណនេយ្យ។ |
| **X3- ចំណាយបង្គរ (ចំណាយប្តូកបន្ត) ÷** | ចំណាយបូកយោងបានកើតឡើងតាំងពីឆ្នាំជាប់ពន្ធដំបូង រហូតដល់ឆ្នាំជាប់ពន្ធចរន្តក្នុងបញ្ជីគណនេយ្យ។ |
| **X4- សមាមាត្រនៃប្រាក់ចំណូលលើសកម្រិត (X4=X2/X3) ÷** | សមាមាត្រនៃប្រាក់ចំណូលលើសកម្រិតនៃឆ្នាំជាប់ពន្ធចរន្តណាមួយ (X4) គឺជាផលចែកនៃទឹកប្រាក់បូកបង្គរនៃចំណូល (X2) និងទឹកប្រាក់បូកបង្គរនៃចំណាយ (X3) ពីប្រតិបត្តិការធនធានរ៉ែ ឬប្រេងកាតមកទល់នឹងឆ្នាំជាប់ពន្ធចរន្តនោះ។ |

**X5- ពន្ធលើប្រាក់ចំណូលលើសកម្រិត* ÷**

អនុលោមតាមមាត្រា ១៤៣ នៃច្បាប់ស្តីពីសារពើពន្ធ÷

១- អ្នកជាប់ពន្ធដែលធ្វើប្រតិបត្តិការធនធានរ៉ែ និងប្រេងកាត ដូចមានចែងក្នុងមាត្រា ១៤២ នៃច្បាប់ស្តីពីសារពើពន្ធ ត្រូវជាប់ពន្ធលើប្រាក់ចំណូលតាមអត្រា ៣០ ភាគរយ នៃប្រាក់ចំណូលជាប់ពន្ធក្នុងឆ្នាំជាប់ពន្ធ។

២- បន្ថែមលើអត្រាពន្ធដូចមានចែងក្នុងចំណុច១ខាងលើ ប្រសិនបើអ្នកជាប់ពន្ធមានប្រាក់ចំណូលលើសកម្រិត តាមអត្រាកំណើនតាមថ្នាក់ដោយផ្អែកលើសមាមាត្រនៃប្រាក់ចំណូលលើសកម្រិត ដូចក្នុងតារាងខាងក្រោម÷

| ថ្នាក់ | សមាមាត្រនៃប្រាក់ចំណូលលើសកម្រិត | អត្រាពន្ធលើប្រាក់ចំណូលលើសកម្រិត |
|---|---|---|
| ១ | ដល់ ១,៣ | 0% |
| ២ | លើសពី ១,៣ ដល់ ១,៦ | ១0% |
| ៣ | លើសពី ១,៦ ដល់ ២ | ២0% |
| ៤ | លើសពី ២ | ៣0% |

*ពន្ធលើប្រាក់ចំណូលលើសកម្រិត÷

- បើ **"X4: សមាមាត្រនៃប្រាក់ចំណូលលើសកម្រិត"** នៅចន្លោះពី 0 ដល់ ១,៣ អត្រាពន្ធគឺ 0% ដូចនេះ **"X5: ពន្ធលើប្រាក់ចំណូលលើសកម្រិត"** ស្មើ 0។
- **បើ X4 លើសពី ១,៣ ដល់ ១,៦ អត្រាពន្ធគឺ ១0%** ដូចនេះ

$$X5 = X1 * \left(\frac{X4-1.3}{X4}\right) * 10\%$$

❖ **បើ X4 លើសពី ១,៦ ដល់ ២ អត្រាពន្ធគឺ ២០%** ដូចនេះ

$$X5 = X1 * \left(\frac{1.6-1.3}{1.6}\right) * 10\% + X1 * \left(\frac{X4-1.6}{X4}\right) * 20\%$$

❖ **បើ X4 លើសពី ២ អត្រាពន្ធគឺ ៣០%** ដូចនេះ

$$X5 = X1 * \left(\frac{1.6-1.3}{1.6}\right) * 10\% + X1 * \left(\frac{2-1.6}{2}\right) * 20\% + X1 * \left(\frac{X4-2}{X4}\right) * 30\%$$

**ឧទាហរណ៍÷**

អ្នកជាប់ពន្ធមានស្ថានភាពចំណូលចំណាយ ដែលគណនាជាសមាមាត្រនៃប្រាក់ចំណូលលើសកម្រិត (សចលក.) ដូចខាងក្រោម÷

| ឆ្នាំជាប់ពន្ធ | ចំណូល | | ចំណាយ | | ប្រាក់ចំណូលជាប់ពន្ធ | សចលក. |
|---|---|---|---|---|---|---|
| | ក្នុងឆ្នាំ | បង្គរ | ក្នុងឆ្នាំ | បង្គរ | | |
| | (a) | (X2) | (c) | (X3) | X1=(a)-(c) | X4=(X2)/(X3) |
| 20X0 | 9,000,000 | 9,000,000 | 8,000,000 | 8,000,000 | 1,000,000 | 1.13 |
| 20X1 | 11,000,000 | 20,000,000 | 5,000,000 | 13,000,000 | 6,000,000 | 1.54 |
| 20X2 | 12,000,000 | 32,000,000 | 4,000,000 | 17,000,000 | 8,000,000 | 1.88 |
| 20X3 | 14,000,000 | 46,000,000 | 3,000,000 | 20,000,000 | 11,000,000 | 2.30 |

ការគណនាពន្ធលើប្រាក់ចំណូល និងពន្ធលើប្រាក់ចំណូលលើសកម្រិត (ពចលក.)÷

### 1. ឆ្នាំជាប់ពន្ធ 20X0÷

អ្នកជាប់ពន្ធមានចំណូល 9,000,000 និងចំណាយ 8,000,000 គណនាជាសមាមាត្រនៃប្រាក់ចំណូលលើសកម្រិតស្មើនឹង 1.13។ ប្រាក់ចំណូលជាប់ពន្ធគឺ 1,000,000 ត្រូវជាប់ពន្ធលើប្រាក់ចំណូល និងពន្ធលើប្រាក់ចំណូលលើសកម្រិតតាមអត្រា 0%។

ពន្ធលើប្រាក់ចំណូលត្រូវបង់សរុប = ពន្ធលើប្រាក់ចំណូល + ពន្ធលើប្រាក់ចំណូលលើសកម្រិត
= (1,000,000 x 30%) + 0
= 300,000

### 2. ឆ្នាំជាប់ពន្ធ 20X1÷

អ្នកជាប់ពន្ធមានចំណូលបង្គរ 20,000,000 និងចំណាយបង្គរ 13,000,000 គណនាជាសមាមាត្រនៃប្រាក់ចំណូលលើសកម្រិតស្មើនឹង 1.54។ ដូចនេះ ប្រាក់ចំណូលជាប់ពន្ធ 6,000,000 ត្រូវជាប់ពន្ធលើប្រាក់ចំណូល និងពន្ធលើប្រាក់ចំណូលលើសកម្រិតតាមអត្រា 10%។

មូលដ្ឋានគិត **ពចលក.** តាមអត្រា 10% = 6,000,000 x [(1.54 - 1.3)/1.54] = 935,065

**ពចលក.** តាមអត្រា 10% = មូលដ្ឋានគិត ពចលក. x អត្រា ពចលក. 10%
= 935,065 x 10% = 93,506

ពន្ធលើប្រាក់ចំណូលត្រូវបង់សរុប = ពន្ធលើប្រាក់ចំណូល + ពន្ធលើប្រាក់ចំណូលលើសកម្រិត
= (6,000,000 x 30%) + 93,506
= 1,893,506

### 3. ឆ្នាំជាប់ពន្ធ 20X2 ÷

អ្នកជាប់ពន្ធមានចំណូលបង្គរ 32,000,000 និងចំណាយបង្គរ 17,000,000 គណនាជាសមាមាត្រនៃប្រាក់ចំណូលលើសកម្រិតស្មើនឹង 1.88។ ដូចនេះ ប្រាក់ចំណូលជាប់ពន្ធ 8,000,000 ត្រូវជាប់ពន្ធលើប្រាក់ចំណូល និងពន្ធលើប្រាក់ចំណូលលើសកម្រិតតាមអត្រា 10% និង 20%។

មូលដ្ឋានគិត **ពចលក.** តាមអត្រា 10% = 8,000,000 x [(1.6 - 1.3)/1.6] = 1,500,000

**ពចលក.** តាមអត្រា 10% = មូលដ្ឋានគិត ពចលក. x អត្រា ពចលក. 10%
= 1,500,000 x 10% = 150,000

មូលដ្ឋានគិត **ចពលក.** តាមអត្រា 20% = 8,000,000 x [(1.88 - 1.6)/1.88] = 1,191,489

**ពចលក.** តាមអត្រា 20% = មូលដ្ឋានគិត ពចលក. x អត្រា ពចលក. 20%
= 1,191,489 x 20% = 238,298

ពន្ធលើប្រាក់ចំណូលត្រូវបង់សរុប = ពន្ធលើប្រាក់ចំណូល + ពន្ធលើប្រាក់ចំណូលលើសកម្រិត
= (8,000,000 x 30%) + (150,000+ 238,298)
= <u>2,788,298</u>

### 4. ឆ្នាំជាប់ពន្ធ 20X3 ÷

អ្នកជាប់ពន្ធមានចំណូលបង្គរ 46,000,000 និងចំណាយបង្គរ 20,000,000 គណនាជាសមាមាត្រនៃប្រាក់ចំណូលលើសកម្រិតស្មើនឹង 2.30។ ដូចនេះ ប្រាក់ចំណូលជាប់ពន្ធ 11,000,000 ត្រូវជាប់ពន្ធលើប្រាក់ចំណូល និងពន្ធលើប្រាក់ចំណូលលើសកម្រិតតាមអត្រា 10%, 20% និង 30%។

មូលដ្ឋានគិត **ពចលក.** តាមអត្រា 10% = 11,000,000 x [(1.6 - 1.3)/1.6] = 2,062,500

**ពចលក.** តាមអត្រា 10% = មូលដ្ឋានគិត ពចលក. x អត្រា ពចលក. 10%
= 2,062,500 x 10% = 206,250

មូលដ្ឋានគិត **ពចលក.** តាមអត្រា 20% = 11,000,000 x [(2 - 1.6)/2] = 2,200,000

**ពចលក.** តាមអត្រា 20% = មូលដ្ឋានគិត ពចលក. x អត្រា ពចលក. 20%
= 2,200,000 x 20% = 440,000

មូលដ្ឋានគិត **ពចលក.** តាមអត្រា 30% = 11,000,000 x [(2.30 - 2)/2.30] = 1,434,783

**ពចលក.** តាមអត្រា 30% = មូលដ្ឋានគិត ពចលក. x អត្រា ពចលក. 30%
= 1,434,783 x 30% = 430,435

ពន្ធលើប្រាក់ចំណូលត្រូវបង់សរុប = ពន្ធលើប្រាក់ចំណូល + ពន្ធលើប្រាក់ចំណូលលើសកម្រិត
= (11,000,000 x 30%) + (206,250 + 440,000 + 430,435)
= <u>4,376,685</u>

# ការប្រើប្រាស់អត្រាប្តូរប្រាក់ក្នុងការរៀបចំលិខិតប្រកាស ពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ

ចំពោះអ្នកជាប់ពន្ធដែលរៀបចំរបាយការណ៍ហិរញ្ញវត្ថុប្រើប្រាស់រូបិយប័ណ្ណប្រតិបត្តិការ (Functional Currency) ណាមួយជាគោលក្រៅពីប្រាក់រៀល ត្រូវអនុវត្តការបំពេញលិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំដូចខាងក្រោម÷

១). អ្នកជាប់ពន្ធត្រូវប្តូរសមតុល្យគណនីទាំងអស់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ (រួមទាំងសមតុល្យដើមគ្រានៅក្នុងតារាងសំវិធានធន) ទៅជាប្រាក់រៀលដោយគុណនឹង **អត្រាប្តូរប្រាក់ប្រចាំឆ្នាំ** សម្រាប់រៀបចំលិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំក្នុងឆ្នាំជាប់ពន្ធចរន្ត (N)។ ម្យ៉ាងទៀត ចំពោះសមតុល្យគណនីឆ្នាំជាប់ពន្ធមុន (N-1) អ្នកជាប់ពន្ធគ្រាន់តែចម្លងតួលេខជាប្រាក់រៀលពីលិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ ពីឆ្នាំជាប់ពន្ធមុនមកបំពេញតែប៉ុណ្ណោះ។

**ឧទាហរណ៍÷** ក្នុងរបាយការណ៍ហិរញ្ញវត្ថុមានសមតុល្យគណនីកម្ចី ១០០ ០០០ ដុល្លារ និងសមតុល្យគណនីសាច់ប្រាក់ក្នុងធនាគារចំនួន ៥០ ០០០ ដុល្លារ ដែលក្នុងឆ្នាំប្រតិបត្តិការកើតឡើងនោះ (N-1) អត្រាប្តូរប្រាក់ ១ ដុល្លារ ស្មើនឹង ៤ ០០០ រៀល ដូចនេះក្នុងលិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ (N-1) សមតុល្យគណនីកម្ចីមានចំនួន ៤០០ ០០០ ០០០ រៀល និងសមតុល្យគណនីសាច់ប្រាក់ក្នុងធនាគារមានចំនួន ២០០ ០០០ ០០០ រៀល។ ឧបមាថាក្នុងឆ្នាំជាប់ពន្ធចរន្ត (N) អត្រាប្តូរប្រាក់ ១ ដុល្លារ ស្មើនឹង ៤ ១០០ ដូចនេះអ្នកជាប់ពន្ធត្រូវកត់ត្រាសមតុល្យគណនីកម្ចីចំនួន ៤១០ ០០០ ០០០ រៀល និងសមតុល្យគណនីសាច់ប្រាក់ក្នុងធនាគារចំនួន ២០៥ ០០០ ០០០ រៀល ដោយមិនមានលម្អៀងពីអត្រាប្តូរប្រាក់ចំពោះគណនីទាំងពីរនេះដែលត្រូវកត់ត្រាក្នុងលិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំចរន្ត (N) នោះទេ។

| **បរិយាយ** | **ការិយបរិច្ឆេទនេះ (N)** | **ការិយបរិច្ឆេទមុន (N-1)** | **ការិយបរិច្ឆេទនេះ (N)** | **ការិយបរិច្ឆេទមុន (N-1)** |
|---|---|---|---|---|
| | **USD** | **USD** | **KHR** | **KHR** |
| គណនីកម្ចី | 100,000 | 100,000 | 410,000,000 | 400,000,000 |
| សាច់ប្រាក់ក្នុងធនាគារ | 50,000 | 50,000 | 205,000,000 | 200,000,000 |

២. ដោយឡែក ចំពោះការកែតម្រូវក្រៅគណនេយ្យតាមច្បាប់ស្តីពីសារពើពន្ធ អ្នកជាប់ពន្ធត្រូវស្រង់តួលេខចេញពីលិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ ពីឆ្នាំជាប់ពន្ធមុន (N-1) ជាប្រាក់រៀល មកបំពេញត្រង់សមតុល្យដើមគ្រាក្នុង ***តារាងគណនាវិលស់តាមច្បាប់ស្តីពីសារពើពន្ធ តារាងតាមដានចំណាយការប្រាក់យោងទៅមុខ*** និង ***តារាងតាមដានលទ្ធផលសារពើពន្ធយោងទៅមុខ*** សម្រាប់គណនាពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំចរន្ត (N)។

## កំណត់សម្គាល់÷

- ចំពោះអ្នកជាប់ពន្ធដែលអនុវត្តឆ្នាំជាប់ពន្ធខុសពីឆ្នាំប្រតិទិន ត្រូវប្រើប្រាស់អត្រាប្តូរប្រាក់ខែចុងក្រោយសម្រាប់រៀបចំលិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ។
- ចំពោះអ្នកជាប់ពន្ធដែលធ្វើការបិទអាជីវកម្មជាស្ថាពរ ត្រូវប្រើប្រាស់អត្រាប្តូរប្រាក់ខែចុងក្រោយសម្រាប់រៀបចំលិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ។